00711825



**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

Extraordinary Chambers in the Courts of Cambodia

Chambres Extraordinaires au sein des Tribunaux Cambodgiens

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

---

**អង្គជំនុំជម្រះសាលាដំបូង**

Trial Chamber

Chambre de Premiere instance

**ឯកសារដើម**

**ORIGINAL/ORIGINAL**

ថ្ងៃ ខែ ឆ្នាំ (Date): 05-Jul-2011, 11:42

CMS/CFO: Kauv Keoratanak

# <u>កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តីលើ</u>

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក/អជសដ

**<u>សាធារណៈ</u>**

**ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១១**

**សវនាការបឋម**

**ម៉ោង ០៩:០៣ នាទី**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍

*(Judge Silvia Carwright)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍

*(Judge Jean-Marc Lavegne)*

ចៅក្រម ធូ មណី

ចៅក្រម យូរ ឧត្តរា

ចៅក្រម ក្លូឌា ហ្វេនស៍

*(Judge Claudia Fenz)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

លោក ឌុច ផារី

កញ្ញា ហ្វៃហ្សា ហ្សូអាគ្រី *(Ms Faiza Zouakri)*

លោក ម៉ាតូ គ្រីបប៉ា *(Mr. Matteo Crippa)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក សេង ប៊ុនឃាង

លោក អាន់ឌ្រូ ខេលី *(Mr. Andrew Cayley)*

លោក វេង ហ៊ត់

លោក ថារីក អាល់ឌុលឡាក់

*(Mr. Tarik Abdulhak)*

លោក វាំងសង់ វ៉ាយដ៍ ដេស្តាឯល*(Mr.Vincent de wilde d'estmael)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

លោក អៀង សារី

លោកស្រី អៀង ធីរិទ្ធ

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក ម៉ៃខល ផេសមិន
*(Mr. Michiel PESTMAN)*

លោក វ៉ិចទ័រ កូប៉េ*(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក ស ស្វវាន

**មេធាវីការពារជនជាប់ចោទ អៀង ធីរិទ្ធ៖**

លោក ផាត់ ពៅស៊ាង

លោកស្រី កាលីង វ៉ាន់ដឺវូត
*(Ms.Karlijn Van der Voort)*

**មេធាវីការពារជនជាប់ចោទ អៀង សារី៖**

លោក អាង ឧត្តម

លោក ម៉ៃខល កាណាវាស
*(Mr.Michael KARNAVAS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ូនណូហ្វត
*(Ms. Elisabeth SIMONNEAU-FORT)*

លោកស្រី ម៉ាទីន ហ្សាកកាំង
*(Ms. Martine Jaquin)*

លោក ប៉ាស្កាល់ អូប៊ីង *(Mr. Pascal Aubouin)*

លោកស្រី គ្រីស្ទីន ម៉ាទីណូ
*(Mrs. Chritine Martinau)*

លោក សំ សុគង់

លោក ឡោ ជុនធី

កញ្ញា លី ម៉ាញៀន *(Ms.Lyma Nguyen)*

កញ្ញា ហ្វីលីពីន ស៊ុតហ្ស៍ *(Ms.Phillipine Sutz)*

លោក អេម៉ានូអ៊ែល ហ្សាកូមី
*(Ms.Emanuel Jacomy)*

លោកស្រី ជេត វណ្ណលី

លោក គឹម ម៉េងឃី

លោក វេង ពៅ

លោកស្រី ស៊ិន ស៊ីវន

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក កូវ កែវរតនៈ

# បញ្ជីឈ្មោះអ្នកនិយាយ៖

## ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក ពេជ អង្គ | ខ្មែរ |
| លោកស្រី កាលីង វ៉ាន់ដឺវូត | អង់គ្លេស |
| លោក សំ សុគង់ | ខ្មែរ |
| កញ្ញា លី ម៉ាញៀន | អង់គ្លេស |
| លោក ប៉ាស្កាល់ អូប៊ីង | អង់គ្លេស |
| លោក ម៉ៃខល កាណាវាស | អង់គ្លេស |
| លោក ផាត់ ពៅស៊ាង | ខ្មែរ |
| លោក ម៉ៃខល ផេសមិន | អង់គ្លេស |
| លោក អាង ឧត្តម | ខ្មែរ |
| លោក ម៉ៃខល កាណាវាស | អង់គ្លេស |
| លោក ស សូវាន | ខ្មែរ |
| លោក សេង ប៊ុនឃាង | ខ្មែរ |
| លោក វាំងសង់ វ៉ាយដ៏ ដេស្នាឯល | បារាំង |
| លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត | បារាំង |
| លោក នួន ជា | ខ្មែរ |
| លោក ឡៅ ជុនធី | ខ្មែរ |
| លោក គីម ម៉េងឃី | ខ្មែរ |
| លោកស្រី ជេត វណ្ណលី | ខ្មែរ |
| លោកស្រី សែ កុលវុឌ្ឍី | ខ្មែរ |

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០៣:២០]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអស់លោក លោកស្រីអង្គុយចុះ!

អង្គជំនុំជម្រះសាលាដំបូងប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការបឋម។ កាលពីម្សិលមិញ កិច្ចដំណើរការនៃធ្វើនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់អំពីអញ្ញត្រកម្ម អាជ្ញាយុកាលទាក់ទងនឹងការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ត្រូវបានធ្វើ ហើយនិងបានស្តាប់ដល់ដំណាក់កាលនៃការឆ្លើយតបរបស់សហព្រះរាជអាជ្ញារួចហើយ។

ហើយជាកិច្ចបន្ត គឺអង្គជំនុំជម្រះប្រគល់វេទិកាទៅសហមេធាវីនាំមុខតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីដើម្បីធ្វើថ្លែងការណ៍តប។ សូមអញ្ជើញ!

**លោក ពេជ អង្គ៖**

សូមគោរពលោកចៅក្រមប្រធាន!

សូមគោរពលោក លោកស្រីចៅក្រម ដែលមានវត្តមានទីនេះ!

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោក នួន ជា!

**លោក នួន ជា៖**

ខ្ញុំ នួន ជា សូមគោរពតុលាការ សូមគោរពលោកប្រធាន សូមគោរពបងប្អូនរួមជាតិ។

ដោយអង្គសវនាការថ្ងៃនេះ នៅដដែកករណីលោក អៀង សារី នៅឡើយ។ ខ្ញុំ នួន ជា សូមលោកប្រធានអនុញ្ញាតឲ្យខ្ញុំត្រឡប់ទៅមន្ទីរឃុំឃាំងវិញដោយអនុគ្រោះ។ ពេលវេលាណាដែល តុលាការយកករណីខ្ញុំមកពិចារណានៅតុលាការ ពេលនោះខ្ញុំនឹងមកសហការជាមួយតុលាការយ៉ាងសកម្មវិញ ដើម្បីស្វែងរកការពិត ដោយគោរព។

[០៩:០៦:០៤]

**ប្រធានអង្គជំនុំ៖**

ដោយបានស្តាប់នូវសំណើសុំរបស់ជនជាប់ចោទ នួន ជា ដែលបានបង្ហាញអំពីចេតនាក្នុងការ

លះបង់សិទ្ធិចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធីសវនាការបឋមសម្រាប់ថ្ងៃនេះ ហើយសំណើនេះមានចែងច្បាស់លាស់នៅក្នុងវិធាន៨១(៤) ដែលជាសំណើសមស្រប។ ហេតុដូច្នេះ អង្គជំនុំជម្រះយល់ព្រមអនុញ្ញាតឱ្យជនជាប់ចោទ នួន ជា ដកខ្លួនចេញពីកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។ អនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទឈ្មោះ នួន ជា ទៅកាន់មន្ទីរឃុំឃាំងវិញចុះ!

ជាបន្តសូមអញ្ជើញសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីជាតិឡើងចាប់អារម្មណ៍។

បាទ, សូមអញ្ជើញ!

**លោកស្រី កាលីង វ៉ាន់ដឺវូត៖**

លោកចៅក្រម កាលពីម្សិលមិញគឺសវនាការជម្រាបថា សវនាការនឹងបន្តរហូតទៅដល់ថ្ងៃសុក្រ។ ប៉ុន្តែនៅពេលនេះ គឺខ្ញុំមិនដឹងថាតើខ្ញុំត្រូវទៅអឺរ៉ុបវិញនៅថ្ងៃណានោះទេ ប្រហែលជានៅស្អែកពេលល្ងាច។ ដូច្នេះ ខ្ញុំស្នើសុំឱ្យអង្គសវនាការកំណត់កាលបរិច្ឆេទសវនាការដោយនៅថ្ងៃស្អែកនេះ គួរតែពិចារណាទៅលើបញ្ហាពាក់ព័ន្ធទៅនឹងបញ្ជីសាក្សីសិនទៅ។

[០៩:០៨:១៣]

**ប្រធានអង្គជំនុំ៖**

អរគុណច្រើនន្ធូវចំណាប់អារម្មណ៍របស់លោកស្រីមេធាវី ប៉ុន្តែ អង្គជំនុំជម្រះសូមជម្រាបថាកាលពីម្សិលមិញគឺជាការប្រមើលមើលរបស់អង្គជំនុំជម្រះ ក្រោយពីបានត្រួតពិនិត្យនូវរបៀបវារៈដែលបានគ្រោងទុក ហើយបានធ្វើសវនាការរួចហើយក្នុងរយៈពេលពីរថ្ងៃ ធៀបជាមួយនឹងរបៀបវារៈដែលនៅសល់ដែលបានគ្រោង ឃើញថាវាដំណើរការមានការយឺត ដែលយើងអាចប្រមើលមើលថា ក្រែងលោវាមានការយឺតយ៉ាវមិនបានតាមរបៀបវារៈដែលបានគ្រោងទុក។ ហើយនិងគ្រោងថា ប្រសិនបើយើងធ្វើមិនចប់ទេ យើងនឹងអាចបន្តទៅថ្ងៃសុក្រដើម្បីចប់ យើងមិនអាចទៅលើកទៅពេលណាមួយបានទេ វាកាន់តែរំខានដល់ភាគី ជាពិសេស គឺអស់លោក លោកស្រីជាមេធាវី ដែលអញ្ជើញមកពីបរទេសនោះទៀតហើយ។ ដោយឡែកប្រសិនបើវាមានហេតុផលផ្សេងនោះគឺ លោកស្រីបានលើកសំណើអម្បាញ់មិញនេះ អង្គជំនុំជម្រះនឹងពិចារណាលើស្ថានភាពនេះ ថាតើគួរតែអាចកែ-- ប្រែប្រួលយ៉ាងដូចម្ដេចខ្លះនៅពេល ក្រោយពេលឈប់សម្រាក? ចាំអង្គជំនុំជម្រះពិចារណាអំពីបញ្ហានេះ។ ប៉ុន្តែលទ្ធភាពប្រឹងប្រែងរបស់អង្គជំនុំជម្រះ គឺនឹងប្រឹងប្រែង ក្នុងជំរុញធ្វើយ៉ាងណាឲ្យទៅតាមពេលវេលាដែលបានគ្រោងទុក។

សូមអញ្ជើញលោក ពេជ អង្គ!

[០៩:០៩:៣៥]

**លោក ពេជ អង្គ៖**

សូមគោរពសាជាថ្មីដល់លោកចៅក្រមប្រធាន លោក លោកស្រី ដែលជាចៅក្រមអង្គសវនាការទាំងមូល។ ពាក់ព័ន្ធនឹងប្រធានបទដែលបានលើកពីម្សិលមិញនេះ ថ្ងៃនេះមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីមានការឆ្លើយតប ហើយមេធាវីនាំមុខសូមអនុញ្ញាតលោកចៅក្រមប្រធាន អនុញ្ញាតឲ្យមេធាវីចំនួនបីរូបដើម្បីធ្វើបទអន្តរាគមន៍ឆ្លើយតប។

[០៩:១០:០៨]

ទីមួយ គឺអនុញ្ញាតជូនលោកមេធាវី សំ សុគង់។ ទីពីរ គឺលោកស្រីមេធាវី លី ម៉ាញឿន

ទីបី គឺជូនទៅលោកមេធាវី ប៉ាស្កាល់ អូប៉ឺង។ សូមអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត តាមការស្នើសុំរបស់សហមេធាវីនាំមុខជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្នុងការប្រគល់សិទ្ធិទៅមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទាំងបីរូប ដើម្បីធ្វើសេចក្តីថ្លែងការណ៍តបនេះ។ អង្គជំនុំជម្រះសូមជម្រាបថា រយៈពេលសរុប ដែលមេធាវីទាំងបីមាន គឺ៣០នាទី។

សូមអញ្ជើញ!

[០៩:១០:៥៨]

**លោក សំ សុគង់៖**

ជាបឋមខ្ញុំបាទសូមគោរពប្រធានក្រុមប្រឹក្សា និងគោរពក្រុមប្រឹក្សា និងសូមគោរពអង្គសវនាការទាំងមូល។ ខ្ញុំបាទ មេធាវី សំ សុគង់ ជាមេធាវីការពារតំណាងអាណត្តិឲ្យដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០២ នៅចំពោះមុខ អ.វ.ត.ក។ ខ្ញុំនឹងលើកឡើងនូវទឡ្ហីករណ៍ឆ្លើយតបទៅនឹងមេធាវីការពារក្តីឲ្យលោក អៀង សារី ដែលបានលើកឡើងអំពីអាជ្ញាយុកាលចំពោះការបំពារបំពានធ្ងន់ធ្ងរកាលពីថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១១ ត្រង់មាត្រា៦ នៃច្បាប់បង្កើត អ.វ.ត.ក និងគោលបំណងរបស់ច្បាប់នេះ។

[០៩:១១:៣៥]

នៅក្នុងប្រធានបទនេះដែរ ខ្ញុំមានសហមេធាវីអន្តរជាតិពីររូប ក្នុងនោះមានលោកស្រី លី ម៉ាញឿន និងលោក ប៉ាស្កាល់ អូប៉ឺង នឹងលើកនូវទឡ្ហីករណ៍ជាបន្ទាប់ដែលមេធាវីទាំងពីររូបនេះនឹងលើកពីអាជ្ញាបញ្ញា ឬអាជ្ញាព្រឹត្ត នៃអាជ្ញាព្រឹត្ត នៃការអនុវត្តអាជ្ញាយុកាលចំពោះការបំពារបំពានធ្ងន់ធ្ងរនៃ

អនុសញ្ញានៃទីក្រុងហ្សឺណែវនេះ។

[០៩:១២:០០]

កាលពីម្សិលមិញ ក្រោយពីបានសិក្សាសំណុំរឿងបន្ថែម ក៏ដូចជាបានស្ដាប់ការលើកឡើងនូវទឡ្ហីករណ៍ឆ្លើយតបទៅមេធាវីការពារ របស់សហព្រះរាជអាជ្ញា កាលពីថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១១ ខ្ញុំបាទមេធាវី សំ សុគង់ សូមធ្វើការឯកភាពចំពោះការលើកឡើងរបស់សហព្រះរាជអាជ្ញាដោយមេធាវី- - ទៅមេធាវីការពារក្ដី ដោយខ្ញុំបាទមានចំណុចបន្ថែមមួយចំនួនដើម្បីលើកឡើងសម្រាប់ឲ្យលោកប្រធាន និងក្រុមប្រឹក្សាធ្វើការពិចារណាដូចខាងក្រោម។

បើយើងពិនិត្យទៅលើច្បាប់បង្កើត អ.វ.ត.ក យើងឃើញថាមុននឹងបង្កើតចេញនូវច្បាប់ អ.វ.ត.ក រាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ បានចរចាគ្នាជាច្រើនលើកជាច្រើនសា ទើបរដ្ឋសភាប្រជុំអនុម័តឲ្យចេញនូវច្បាប់នេះឡើងដោយមានការជជែកដេញដោល ជាច្រើនលើកជាច្រើនសា ដោយលើកយកទាំងច្បាប់ជាតិ និងច្បាប់អន្តរជាតិយកមកពិភាក្សាផងដែរ។

[០៩:១៣:០៨]

នៅក្នុងនោះ យើងឃើញមាននៅក្នុងមាត្រាទី១ បានចែងអំពីគោលបំណងនៃច្បាប់នេះ និងមាត្រា ២ បានចែងអំពីសមត្ថកិច្ច ឬយុត្តាធិការនៃច្បាប់នេះ គឺក្នុងមាត្រាទាំងពីរនេះ គឺតុលាការ អ.វ.ត.ក នេះមានសមត្ថកិច្ចទៅលើច្បាប់អន្តរជាតិ ក៏ដូចជាច្បាប់ជាតិផ្សេងៗទៀត។ ហើយយើងក៏ឃើញមានចែងនៅក្នុងមាត្រា៣ ដល់មាត្រា៥ បានចែងអំពីបទល្មើសទាំងជាតិ និងបទល្មើសទាំងអន្តរជាតិ ហើយនៅក្នុងមាត្រាទី៣ គឺមានការពន្លាតសមត្ថកិច្ច ឬក៏ពន្លាតអាជ្ញាយុកាលនៃបទល្មើសជាតិផងដែរ។

[០៩:១៣:៥២]

ផ្ទុយទៅវិញក្នុងមាត្រា៦នៃច្បាប់នេះបានចែងថា អ.វ.ត.ក មានអំណាចវិនិច្ឆ័យទោសជនសង្ស័យដែលបានប្រព្រឹត្ត និងបានបញ្ជាឲ្យប្រព្រឹត្ត ការបំពារបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩។ បើយោងទៅលើអត្ថន័យ និងស្មារតីរបស់ច្បាប់នេះ និងគោលបំណងរបស់អ្នកធ្វើច្បាប់ឃើញថា អាជ្ញាយុកាលរបស់ក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ មិនអាចយកមកអនុវត្តនៅក្នុងមាត្រា៦នៃច្បាប់បង្កើត អ.វ.ត.ក នេះបានទេ ពីព្រោះប្រសិនបើច្បាប់ក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ អាចយកមកអនុវត្តទៅលើមាត្រា៦ នៃច្បាប់នេះបាន អ្នកធ្វើច្បាប់មិនចាំបាច់ចែងមាត្រា៣ និងមាត្រា៦ នៃច្បាប់នេះឲ្យដាច់ពីគ្នានោះទេ គឺគេបញ្ចូលទៅក្នុងមាត្រា៣ តែមួយបានហើយ។

[០៩:១៥:០៣]

ចំណុចមួយទៀត គឺត្រង់ថា មេធាវីការពារក្ដីបានលើកឡើងនៅក្នុងបទប្បញ្ញត្តិក្នុងមាត្រា៤ និងមាត្រា៥ នៃច្បាប់បង្កើត អ.វ.ត.ក ដែលបានចែងថា “អាជ្ញាយុកាលមិនអនុវត្តចំពោះអំពើប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ”។

មេធាវីការពារក្ដីទាំងនោះ បានអះអាងទៀតថា អាជ្ញាយុកាលនៅក្នុងមាត្រា១០៩ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ អាចអនុវត្តបានគ្រប់បទល្មើសទាំងអស់ដែលនៅក្នុងប្រទេសកម្ពុជាក្នុងពេលវាដែលពាក់ព័ន្ធ។ បន្ទាប់មកមេធាវីការពារក្ដីបានសន្និដ្ឋានថា ការមិនលើកឡើងនៅក្នុងមាត្រា៦ ទាក់ទិននឹងអាជ្ញាយុកាលមានន័យថា អ្នកធ្វើច្បាប់មានចេតនាថា អាជ្ញាយុកាលអាចយកមកអនុវត្តចំពោះការបំពារបំពានធ្ងន់ធ្ងរនោះដែរ។

[០៩:១៥:៥៥]

ខ្ញុំសូមឆ្លើយតបទៅនឹងការលើកឡើងរបស់មេធាវីការពារក្ដី ការយល់ឃើញរបស់មេធាវីការពារក្ដីមានការភ័ន្តច្រឡំទៅលើស្មារតីនៃមាត្រា៦ នៃច្បាប់បង្កើត អ.វ.ត.ក ពីព្រោះ បើសិនអាជ្ញាយុកាលនៃច្បាប់ឆ្នាំ១៩៥៦ អនុវត្តចំពោះការបំពារបំពានធ្ងន់ធ្ងរនោះដែរ អ្នកធ្វើច្បាប់មិនចាំបាច់ដាក់បញ្ចូលទៅក្នុងមាត្រា ៦ នៃច្បាប់បង្កើត អ.វ.ត.ក នោះទេ និងគ្មានបទល្មើសណាមួយពិតជាអាចត្រូវបានយកមកជំនុំជម្រះ នៅចំពោះមុខតុលាការអន្តរជាតួបនីយកម្ម ដែលហៅកាត់ថា អ.វ.ត.ក នោះដែរ។ ដោយសារតែអាជ្ញាយុកាលបានកន្លងផុតតាំងពីឆ្នាំ១៩៨៩មកម្ល៉េះ។

[០៩:១៦:៤៥]

ចំពោះក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ វិញអនុវត្តតែចំពោះបុគ្គលណាដែលបានប្រព្រឹត្តបទឧក្រិដ្ឋដែលមានចែងនៅក្នុងច្បាប់នេះតែប៉ុណ្ណោះ។ បទល្មើសដែលបំពារបំពានធ្ងន់ធ្ងរ មិនមែនជាផ្នែកមួយនៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ នោះទេ។ ហើយក៏មិនមែន មិនអាចត្រូវបានចាត់ទុកថាជាបទឧក្រិដ្ឋដែលបានចែងនៅក្នុងមាត្រា១០៩ នោះដែរ។ ដូច្នេះ អាជ្ញាយុកាលដែលត្រូវលើកឡើងនៅក្នុងច្បាប់ក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ មិនអាចអនុវត្តចំពោះការបំពារបំពានធ្ងន់ធ្ងរនោះបានដែរ។

[០៩:១៧:២២]

ច្បាស់ណាស់ថា នៅពេលដែលច្បាប់បង្កើត អ.វ.ត.ក ត្រូវបានធ្វើសេចក្ដីព្រាង ការប៉ះពាល់ធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ បានទទួលឋានៈជាបទដ្ឋានអាជ្ញាព្រឹត្ត ឬគេហៅថា បទដ្ឋានអាជ្ញា

បញ្ហា នៃច្បាប់អន្តរជាតិទៅហើយ ខុសពីឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងអំពើប្រល័យពូជសាសន៍ ពីព្រោះអនុសញ្ញាទីក្រុងហ្សឺណែវ បានមានឋានៈមួយច្បាស់លាស់ជាច្បាប់អន្តរជាតិ ពីព្រោះមានរដ្ឋជាសមាជិកចំនួន១៣៣ នៅក្នុង បានចុះហត្ថលេខានៅក្នុងឆ្នាំ១៩៧៥។

គ្រង់ចំណុចនេះ វាមិនចាំបាច់ត្រូវបានលើកឡើង ជាពិសេសអំពីការមិនអនុវត្តអាជ្ញាយុកាលនោះទេ ពីព្រោះបើការលើកឡើងបែបនេះ វាជាការលើកឡើងច្រំដែល និងមិនចាំបាច់ទាល់តែសោះ។

[០៩:១៨:២២]

នៅក្នុងការពិភាក្សាក្នុងពេលធ្វើសេចក្តីព្រាងច្បាប់ស្តីអំពីការបង្កើត អ.វ.ត.ក សភាជាតិកម្ពុជាក៏បានសម្រេចពន្លាតអាជ្ញាយុកាលសម្រាប់បទល្មើសនានានៅក្នុងមាត្រា៣ ដែរ តែមិនបានពិភាក្សាពីការកំហិតបែបនេះសម្រាប់បទល្មើសអន្តរជាតិ នៅក្នុងមាត្រា៤ និងមាត្រា៦ ឬក៏មាត្រា៣-- មាត្រា៤នោះទេ។ ប្រការនេះបង្ហាញយ៉ាងច្បាស់ថា អាជ្ញាយុកាលមិនអាចអនុវត្តបានចំពោះមាត្រា៦នោះទេ។ លើសពីនេះទៅទៀត របាយការណ៍របស់ក្រុមអ្នកជំនាញបានគាំទ្រចំពោះអង្គហេតុដែលថា ក្រុមអ្នកធ្វើ ច្បាប់បានពិចារណាពិតប្រាកដ អំពីការប៉ះពាល់ដែលអាចនឹងកើតមាននៃអាជ្ញាយុកាលចំពោះបទល្មើសមួយចំនួនដែលគេចង់អនុវត្ត គឺបទល្មើសថ្នាក់ជាតិ តាមមាត្រា៣។

[០៩:១៩:១៦]

បើយើងយោងទៅលើសំណុំរឿង០០១ យើងឃើញថា អង្គជំនុំជម្រះសាលាដំបូងបានសម្រេចឲ្យជនជាប់ចោទលោក កាំង ហ្កេកអ៊ាវ ហៅ ឌុច ចំពោះបទល្មើសចំនួនបី៖

ទីមួយ គឺបទល្មើសឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ។ ទីពីរ បទល្មើសឧក្រិដ្ឋកម្មប្រល័យពូជ-សាសន៍ និងទីបី បទល្មើសការបំពារបំពានធ្ងន់ធ្ងរដូចមានចែងក្នុងមាត្រា៦។

[០៩:១៩:៤៥]

នៅក្នុងសំណុំរឿងនេះអង្គជំនុំជម្រះសាលាដំបូងបានលើកឡើងថា បទប្បញ្ញត្តិនីមួយៗនៃការបំពារបំពានយ៉ាងធ្ងន់ធ្ងរចែងពីបទល្មើសមួយចំនួន ដែលមាននៅក្នុងយុត្តាធិការចាំបាច់ជាសកលលើបទល្មើសរបស់រដ្ឋភាគីនៃអនុសញ្ញានេះរួចហើយ។ ជាងនេះទៅទៀតនៅក្នុងសំណុំរឿង០០១ អាជ្ញាយុកាលត្រូវបានតុលាការយកមកពិចារណាយ៉ាងទូលំទូលាយដែរ តែពាក់ព័ន្ធនឹងមាត្រា៣ តែប៉ុណ្ណោះ។

ប្រការនេះនាំឲ្យមានការសន្និដ្ឋានយ៉ាងច្បាស់ថា បណ្តាអ្នកធ្វើសេចក្តីព្រាងច្បាប់ ហើយបន្ទាប់មកទៀតចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូង មិនដែលពិចារណាលើការអនុវត្តអាជ្ញាយុកាលចំពោះ

មាត្រា៦ នោះទេ។

[០៩:២០:៣៤]

ដូចបានជម្រាបជូនខាងលើ ខ្ញុំបាទ ខ្ញុំមានសហមេធាវីអន្តរជាតិរបស់ខ្ញុំពីររូបទៀត ដែលនឹងលើកពីលក្ខណៈនៃអាជ្ញាព្រឹត្ត ឬអាជ្ញាបញ្ញា នៃការរំលោភធ្ងន់ធ្ងរចំពោះអនុសញ្ញាទីក្រុងហ្សឺណែវ។

ខ្ញុំបាទ សូមអរគុណចំពោះការយកចិត្តទុកដាក់ស្ដាប់របស់លោកប្រធាន និងក្រុមប្រឹក្សា និងទុកវេទិកានេះជូនទៅសហមេធាវីអន្តរជាតិខ្ញុំបាទឈ្មោះ លី ម៉ា ដើម្បីធ្វើការបន្ត។

សូមអរគុណ!

**កញ្ញា លី ម៉ាញឿន៖**

សូមគោរពលោកប្រធាន លោក លោកស្រី សហភាតាទាំងអស់។ ខ្ញុំឈ្មោះ លី ម៉ា ជាមេធាវីតំណាងរដ្ឋប្បវេណី។

[០៩:២១:៤៥]

កាលពីម្សិលមិញសហព្រះរាជអាជ្ញាបានលើកឡើង សារណាដោយលម្អិតចំពោះឋានៈអន្តរជាតិជាពិសេសឋានៈនៃច្បាប់អន្តរជាតិនៅ អ.វ.ត.ក និងច្បាប់ទំនៀមទម្លាប់អន្តរជាតិស្ដីអំពីការបំពានធ្ងន់ធ្ងរ។ នៅក្នុងថ្ងៃនេះដើមបណ្ដឹងរដ្ឋប្បវេណីនឹងផ្ដោតសំខាន់ទៅលើបទដ្ឋានអាជ្ញាបញ្ញា ជាពិសេសនឹងឆ្លើយតបទៅនឹងសំណួររបស់អង្គជំនុំជម្រះ ថាតើអាជ្ញាយុកាលពាក់ព័ន្ធទៅនឹងអនុសញ្ញាទីក្រុងហ្សឺណែវបានបញ្ញត្ត-- និងអាចអនុវត្តបាននៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ជាពិសេសចន្លោះឆ្នាំ៧៥ និង៧៩ដែរឬទេ?

[០៩:២២:២៧]

បទដ្ឋានអាជ្ញាបញ្ញាត្រូវបានចាត់ទុកថា ជានិយាមចាំបាច់ និងនិយាមដាច់ខាតនៃនីតិអន្តរជាតិទូទៅ ដែលសហគមន៍អន្តរជាតិបានទទួលស្គាល់ថា និយាមនេះមិនអាចនិរាករណ៍បាន។ និយាមទាំងនេះបង្កើតកាតព្វកិច្ចដាច់ខាត ដែលរដ្ឋត្រូវអនុវត្តតាម។ ចំណុចជាច្រើនបានលើកឡើងអំពីមាត្រា៥៣ នៃអនុសញ្ញាទីក្រុងវីយ៉ែន ឆ្នាំ១៩៦៩ ស្ដីអំពីច្បាប់សន្ធិសញ្ញាចែងថា សន្ធិសញ្ញាត្រូវចាត់ទុកជាមោឃៈប្រសិនបើនៅពេលសន្ធិសញ្ញានោះវាផ្ទុយទៅនឹងបទដ្ឋាននីតិអន្តរជាតិ។

ប្រទេសកម្ពុជា គឺជារដ្ឋទីមួយដែលបានផ្ដល់ហត្ថលេខាទៅលើអនុសញ្ញានោះ ហើយបានទទួលស្គាល់ពេញលេញអំពីបទដ្ឋានអាជ្ញាបញ្ញា។ សហព្រះរាជអាជ្ញា កាលពីម្សិលមិញបានលើកឡើងអំពី

លក្ខខណ្ឌនៃនិយាមមួយដែលអាចទទួលស្គាល់ថា ជានិយាមអាជ្ញាបញ្ញា។ ដើមបណ្តឹងរដ្ឋប្បវេណីនឹងលើកឡើងអំពីលក្ខខណ្ឌនេះ ដែលថាតើយើងចាត់ទុកជាបទដ្ឋានអាជ្ញាបញ្ញាយ៉ាងម៉េចនៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ?

[០៩:២៣:៣៧]

ទីមួយ គឺរដ្ឋជាច្រើនត្រូវតែផ្តល់សច្ចាប័នទៅលើសន្ធិសញ្ញា។ ទីពីរ ពាក្យពេចន៍នៅក្នុងបុព្វកថា ឬក៏បទប្បញ្ញត្តិសន្ធិសញ្ញាដែលបង្ហាញអំពីឋានៈនៃបទល្មើសអន្តរជាតិនៅក្នុងច្បាប់អន្តរជាតិ។ ទីបី ត្រូវតែមានការស៊ើបអង្កេត និងការចោទប្រកាន់ ចំពោះចារីនៃបទល្មើសទាំងអស់នោះ។ និង ទីបួន ថាតើមានភស្តុតាងនៃគំនិតច្បាប់ បង្ហាញថាបទដ្ឋាននោះ ជាបទដ្ឋានអន្តរជាតិ ទំនៀមទម្លាប់អន្តរជាតិដែរឬទេ?

[០៩:២៤:០៦]

អនុសញ្ញាទីក្រុងហ្សឺណែវ គឺជាបទដ្ឋានបានវិវឌ្ឍត្រូវបានគេចងក្រង បញ្ចូល និងទទួលស្គាល់ជាសកលនៅក្នុងច្បាប់អន្តរជាតិ ហើយមានមូលដ្ឋានចេញមកពីក្រម លីបែល ឆ្នាំ១៨៦៣ ដែលកំណត់ថាទាហានគួរតែធ្វើអ្វីខ្លះក្នុងសង្គ្រាមស៊ីវិលអាមេរិក។

ការបំពានធ្ងន់ធ្ងរនៃអនុសញ្ញាទីក្រុងហ្សែណែវ គឺជាបទដ្ឋានអាជ្ញាបញ្ញានៃច្បាប់អន្តរជាតិ។ នេះមានន័យថា ឧក្រិដ្ឋកម្មសង្គ្រាមនេះមិនមានអាជ្ញាយុកាលឡើយ ជាពិសេសអាជ្ញាយុកាលដែលកំណត់នៅក្នុងក្រមព្រហ្មទណ្ឌជាតិ ដែលមិនមានចែងយោងអំពីបទល្មើសទាំងនេះឡើយ។ ដើមបណ្តឹងរដ្ឋប្បវេណីលើកឡើងថា ការបំពានអនុសញ្ញាទីក្រុងហ្សឺណែវ បានទទួលឋានៈជាវិធានអាជ្ញាបញ្ញា នៅមុនឆ្នាំ១៩៧៥ ដែលគាត់ទើបមានតួនាទីនៅក្នុងកម្ពុជាប្រជាធិបតេយ្យ។

[០៩:២៥:០១]

រដ្ឋជាច្រើននៃអនុសញ្ញា នៅពេលនោះ គឺបានលើកឡើងដោយខ្លួនថា នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ សមាជិក១៣៣ រួមទាំងសមាជិកអចិន្ត្រៃយ៍នៃក្រុមប្រឹក្សាសន្តិសុខបានក្លាយទៅជាភាគីនៃអនុសញ្ញានោះ។ ចំនួននេះ គឺមានចំនួន៩៦ភាគរយនៃសមាជិករដ្ឋរបស់អង្គការសហប្រជាជាតិ។ កម្ពុជាបានផ្តល់សច្ចាប័ន និងចូលជាភាគីនៃអនុសញ្ញាទាំងបួននៅក្នុងឆ្នាំ១៩៦៨។ ជាពិសេសទៅទៀតនោះ មិនមានការព្យួរសិទ្ធិណាមួយ ឬក៏លើកឡើងនូវបញ្ហាអាជ្ញាយុកាលនោះឡើយ។ ការលើកឡើងអំពី លក្ខខណ្ឌលើកលែងនៃអាជ្ញាយុកាល គឺត្រូវបានគូសបញ្ជាក់ថា មិនមានសន្ធិសញ្ញាអន្តរជាតិសិទ្ធិមនុស្ស ណាមួយ រួមទាំងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិ

សេដ្ឋកិច្ច និងសង្គមកិច្ចនោះ គឺមានភាគីចូលរួមនៅក្នុងឆ្នាំ១៩៧៥។

[០៩:២៦:១៧]

វាក៏ជាការពិតដែលមកទល់ពេលបច្ចុប្បន្ន។ មុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ សហគមន៍អន្តរជាតិបានទទួលស្គាល់ថា ការបំពានធ្ងន់ធ្ងរ បានទទួលឋានៈជាវិធានអាជ្ញាបញ្ញា។ បុព្វកថានៃអនុសញ្ញាឆ្នាំ១៩៦៨ នៃការមិនអនុវត្តអាជ្ញាយុកាលចំពោះឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ បានលើកឡើងថា ឧក្រិដ្ឋកម្មទាំងអស់នេះ គឺជាឧក្រិដ្ឋកម្មធ្ងន់ធ្ងរនៅក្នុងច្បាប់អន្តរជាតិ។

កាលពីម្សិលមិញមេធាវីការពារក្តីបានលើកឡើងអញ្ញត្រកម្មទាក់ទងទៅនឹង *ហង់ស៊ុយវ៉ាស* ដែលលើកឡើងអំពីអាជ្ញាយុកាល។ ប៉ុន្តែយើងខ្ញុំសូមលើកឡើងឲ្យបានច្បាស់ថា រដ្ឋមួយចំនួន គឺបានជំទាស់ទៅនឹងច្បាប់អន្តរជាតិនោះ មិនមែនថា វារារាំងថា ច្បាប់នោះមិនមែនជាច្បាប់អន្តរជាតិនោះឡើយ។

[០៩:២៧:១៧]

ការបដិសេធរបស់រដ្ឋនោះ គឺអនុញ្ញាតឲ្យរដ្ឋទាំងអស់នោះថា បទប្បញ្ញត្តិមួយចំនួន គឺមិនអាចអនុវត្តចំពោះរដ្ឋរបស់ខ្លួនតែប៉ុណ្ណោះ។ យើងឃើញថា ឧក្រិដ្ឋកម្មសង្គ្រាម ការចោទប្រកាន់ឧក្រិដ្ឋកម្មសង្គ្រាម មានធ្វើឡើងនៅតុលាការតូក្យូ និងតុលាការដទៃៗទៀត។ ចាប់ពីឆ្នាំ១៩៤៥ ដល់ឆ្នាំ១៩៤៨ សាលាក្តីចំនួនបី តុលាការយោធាអន្តរជាតិ តុលាការនូរឹមប៊ឺក អាមេរិក និងតុលាការយោធាអន្តរជាតិនៅចុងបូព៌ា គឺបានកាត់ទោសជនសង្ស័យចំពោះឧក្រិដ្ឋកម្មទាំងអស់ ដែលមានការរំលោភបំពានធ្ងន់ធ្ងរ។ ការមិនមានការចោទប្រកាន់មុនឆ្នាំ១៩៧០ និងឆ្នាំ១៩៩០ នោះ គឺជាផលវិបាកកើតឡើងចេញពីបញ្ហានយោបាយ។ ក៏ប៉ុន្តែ សហការជំនុំជម្រះទីបីបានលេចឡើងនោះ គឺបានធ្វើការចោទប្រកាន់អំពីការរំលោភបំពានធ្ងន់ធ្ងរ ហើយបានបង្កើតឡើងយ៉ាងត្រឹមត្រូវថា វាជាបទដ្ឋានអាជ្ញាបញ្ញា។

[០៩:២៨:៣៥]

តុលាការពិសេស រួមទាំងតុលាការយូហ្គោស្លាវី តុលាការរវ៉ាន់ដា និងតុលាការសៀរ៉ាឡេអូនមានយុត្តាធិការ ហើយបានចោទប្រកាន់រឿងក្តីពាក់ព័ន្ធទៅនឹងការបំពានធ្ងន់ធ្ងរ។ រឿងក្តីតុលាការអាយ.ស៊ី.ធី.វ៉ាយ បានរកឃើញថា និយាមនៅក្នុងច្បាប់មនុស្សធម៌អន្តរជាតិ ជាពិសេសចំពោះការរារាំងអំពើប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម គឺជាបទដ្ឋានអាជ្ញាបញ្ញា។ ហើយវាជាបទដ្ឋានដាច់ខាត មាត្រា៣៣ អាចមោឃភាពបាន ហើយវាមានឋានៈរបស់វា។ ប្រសិនបើមានការបកស្រាយណាមួយមិនត្រឹមត្រូវនោះ រួមទាំងច្បាប់អន្តរជាតិ និងច្បាប់ទំនៀមទម្លាប់

ផងដែរនោះ យើងត្រូវពិចារណា ថាតើច្បាប់នោះវាស្របយ៉ាងណាទៅនឹងច្បាប់ជាតិ? ហើយតើវាស្របទៅនឹងបទដ្ឋានអាជ្ញាបញ្ញាដែរឬទេ?

[០៩:២៩:៤៧]

ដូច្នេះបទដ្ឋានអាជ្ញាបញ្ញា យោងតាមក្រមឆ្នាំ១៩៥៦ វាប៉ះពាល់ ហើយនិងវាផ្ទុយទៅនឹងបទដ្ឋានអាជ្ញាបញ្ញា ពាក់ព័ន្ធទៅនឹងការបំពានធ្ងន់ធ្ងរ ហើយវាក៏ផ្ទុយទៅនឹងកាតព្វកិច្ចអន្តរជាតិ ក្នុងការចោទប្រកាន់បទល្មើសទាំងអស់នេះ។ ដូច្នេះយើងមិនអាចយកមកអនុវត្តបានទេ។

សហព្រះរាជអាជ្ញា កាលពីម្សិលមិញបានលើកឡើងអំពីកាតព្វកិច្ចដាច់ខាត ក្នុងការចោទប្រកាន់ការបំពានធ្ងន់ធ្ងរទាំងនោះ។ ដូច្នេះខ្ញុំមិនលើកឡើងសាជាថ្មីនោះទេ។

[០៩:៣០:១៦]

ជាសង្ខេបមកវិញ អាជ្ញាយុកាលពាក់ព័ន្ធទៅនឹងការបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ គឺមិនដែលមានចែងនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិនោះទេ។ ជាពិសេសឆ្នាំ១៩៧៥ និងឆ្នាំ១៩៧៩ ហើយក៏វាមិនមានអនុវត្តបាននៅក្នុងច្បាប់អន្តរជាតិផងដែរ។ ប៉ុន្តែយ៉ាងណាក៏ដោយការបំពានធ្ងន់ធ្ងរនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ នោះ វាមិនត្រឹមតែបានក្លាយជាច្បាប់ទំនៀមទម្លាប់អន្តរជាតិនោះទេ វាក្លាយទៅជាបទដ្ឋានអាជ្ញាបញ្ញាទៅទៀត។

ដូច្នេះនៅពេលនេះ ខ្ញុំសូមផ្តល់វេទិកាទៅដល់លោក ប៉ាស្កាល់ អូប៉ឺង ម្តង ដើម្បីឲ្យលោកធ្វើការបង្ហាញ។

សូមអរគុណ!

[០៩:៣១:០៣]

**លោក ប៉ាស្កាល់ អូប៉ឺង៖**

លោក លោកស្រី លោកចៅក្រមជាគោរព។

ខ្ញុំនឹងបន្ថែមសេចក្តីសង្កេតខ្លីៗ គឺថាការបំពានធ្ងន់ធ្ងរនេះ គឺមិនមានអាជ្ញាយុកាល មិនមែនជាកម្មវត្ថុនៃអាជ្ញាយុកាលទេ។ ដូច្នេះវិធានអាជ្ញាបញ្ញាដែលមានផលប៉ះពាល់លុបបំបាត់នូវអាជ្ញាយុកាលនោះ គឺមានចែងនៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦។ វិធានអាជ្ញាបញ្ញានេះតម្រូវឲ្យមាន មិនអាចមានប្រៀបទៅលើ ហើយនិងជាពិសេស គឺ ខ បញ្ញត្តដែលចែងអំពីវិធានអាជ្ញាបញ្ញា។

[០៩:៣១:៥០]

អនុសញ្ញាពីបញ្ហានេះ គឺមិនបានចែងអំពីអាជ្ញាយុកាលអំពីការបំពានធ្ងន់ធ្ងរនោះទេ។ ការរក្សាសិទ្ធិរបស់រដ្ឋក៏មិនបានបញ្ជាក់អំពីអាជ្ញាយុកាលនោះដែរ ហើយមិនមានប្រតិសកម្មទៅនឹងសន្ធិសញ្ញានោះដែរ។ ជាពិសេសទៅទៀតច្បាប់ជាតិនីមួយៗ បានចែងយ៉ាងច្បាស់ហាមមិនឲ្យអនុវត្តនូវអាជ្ញាយុកាលចំពោះបទឧក្រិដ្ឋសង្គ្រាមនោះទេ។ អនុសញ្ញាក្រុងវីយែន បានចែងថា និយាមអន្តរជាតិដែលផ្ទុយទៅនឹងវិធានអាជ្ញាបញ្ញាមិនអាចមានប្រៀបលើវិធានអាជ្ញាបញ្ញានោះបានទេ។ នៅក្នុងករណីនេះ អាជ្ញាយុកាលដែលនិយាយក្នុងច្បាប់កម្ពុជាឆ្នាំ១៩៥៥ មិនអាចរារាំងការចោទប្រកាន់ទៅលើបទបំពានធ្ងន់ធ្ងរនោះទេ។ អនុសញ្ញានិយាយពីការមិនអនុវត្តនូវអាជ្ញាយុកាលចំពោះបទឧក្រិដ្ឋសង្គ្រាម ហើយនិងឧក្រិដ្ឋប្រឆាំងមនុស្សជាតិនោះ ក៏បានហាមយ៉ាងដាច់ខាតមិនឲ្យការយកមកអនុវត្តនូវអាជ្ញាយុកាលចំពោះបទឧក្រិដ្ឋសង្គ្រាមនិងបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ។

[០៩:៣៣:០៨]

អនុសញ្ញាចូលជាធរមាននៅឆ្នាំ១៩៧០ គោលការណ៍ជានិយាមនោះ ដែលថាមិនមានអាជ្ញាយុកាលណាត្រូវយកមកអនុវត្តចំពោះការបំពានធ្ងន់ធ្ងរ ដែលអនុវត្តនៅក្នុងអាជ្ញាយុកាលពេលវេលារបស់ អ.វ.ត.ក នៅឆ្នាំ១៩៧៥ កាតព្វកិច្ចក្នុងការចោទប្រកាន់លើការបំពានធ្ងន់ធ្ងរលើអនុសញ្ញាក្រុងហ្សឺណែវនោះ គឺថាបានបង្កើតបានជាវិធានអាជ្ញាបញ្ញារួចទៅហើយនៅក្នុងច្បាប់អន្តរជាតិនោះ។

មិនមាននិយាមណាមួយអាចមានប្រៀប ឬក៏អាចធ្វើមោឃភាពនូវកាតព្វកិច្ចដាច់ខាត ដែលកើតចេញមកពីវិធានអាជ្ញាបញ្ញានេះបានទេ។

[០៩:៣៣:៥៥]

តុលាការព្រហ្មទណ្ឌអន្តរជាតិនៅក្នុងរឿងក្តីយូហ្គោស្លាវី នៅក្នុងរឿងក្តី ហ្វ័ររិនឌីហ្សា គឺជាឧទាហរណ៍មួយ ក្នុងករណីដែលតុលាការអន្តរជាតិសម្រេចថា ថាតើច្បាប់ជាតិអាចមានប្រៀបលើវិធានអាជ្ញាបញ្ញាដែរឬទេលើទារុណកម្ម? នៅក្នុងករណីនេះ តុលាការ អាយ.ស៊ី.ធី.វ៉ាយ បានសម្រេចថាច្បាប់ជាតិស្តីអំពីអាជ្ញាយុកាលមិនអាចអនុវត្តបានទេ។ មេធាវីការពារបានលើកអំពីអញ្ញត្រកម្មផ្អែកទៅលើពីប្រភពច្បាប់ដែលមានកំហុស ដែលថាអាជ្ញាយុកាលអាចអនុវត្តចំពោះការបំពានធ្ងន់ធ្ងរនៃអនុសញ្ញាក្រុងហ្សឺណែវឆ្នាំ១៩៤៩។

មេធាវីការពារលើកទឡ្ហីករណ៍បែបនេះ គួរតែអង្គជំនុំជម្រះច្រានចោលផ្អែកលើកាតព្វកិច្ចនៃការចោទប្រកាន់លើការបំពានធ្ងន់ធ្ងរលើវិធានអាជ្ញាបញ្ញា ដែលថា វិធាននោះមិនមាននិរាករណ៍បានទេ។

អាជ្ញាយុកាលអាចនឹងបង្កើតបានជានិរាករណ៍ ត្រូវតែអនុញ្ញាតដោយច្បាប់អន្តរជាតិ។ សូមអរគុណ។

[០៩:៣៥:១០]

**ប្រធានអង្គជំនុំ៖**

អរគុណលោក លោកស្រីមេធាវី ដែលបានធ្វើសេចក្តីថ្លែងការណ៍។

ជាកិច្ចបន្តនេះ ក្រុមមេធាវីការពារក្តី អៀង សារី មានពេលវេលា១៥នាទី ដើម្បីធ្វើសេចក្តីថ្លែងការណ៍តប ប្រសិនបើមេធាវីមានបំណងធ្វើដូច្នេះ។

**លោក ម៉ៃខល កាណាវាស៖**

អរុណសួស្តី លោក លោកស្រីចៅក្រម និងភាគី និងអស់លោក លោកស្រីទាំងអស់នៅក្នុងបន្ទប់សវនាការនេះ។ ខ្ញុំមានការលើកឡើងដោយសង្ខេបតែប៉ុណ្ណោះ។ ការបង្ហាញពីខាងសហព្រះរាជអាជ្ញាក៏ដូចជាខាងពីខាងដើមបណ្តឹងបណ្តឹងរដ្ឋប្បវេណី គឺជាការលើកឡើងដ៏ល្អ ហើយមើលទៅក៏វាជាឲ្យអ្វីដែលឲ្យយើងជឿផងដែរ។ ក៏ប៉ុន្តែ យើងខ្ញុំនៅតែរក្សាជំហរនូវទឡ្ហីករណ៍របស់យើងខ្ញុំដដែល។ ហើយទឡ្ហីករណ៍របស់ខ្ញុំក៏មានចំណុចគួរឲ្យជឿជាក់ផងដែរ។

[០៩:៣៦:២០]

យើងមិនឯកភាពថា មកត្រឹមឆ្នាំ១៩៧៥ និងឆ្នាំ១៩៧៩ ការបំពានធ្ងន់ធ្ងរបានទទួលឋានៈក្លាយទៅជាបទដ្ឋានអាជ្ញាបញ្ញានោះទេ។ ខ្ញុំមិនឯកភាពឡើយ។

កាលពីម្សិលមិញ យើងខ្ញុំបានដាក់ជូននូវភស្តុតាងដ៏រឹងមាំបង្ហាញថា មានការពិភាក្សាដេញដោលយ៉ាងផុសផុលពាក់ព័ន្ធទៅនឹងការអនុវត្តទៅបានដែរឬទេ នៃអាជ្ញាយុកាលនោះ?

នៅពេលនេះ យើងឃើញមានសំណួរលើកឡើងពីខាងសហព្រះរាជអាជ្ញា ថាតើវាយ៉ាងម៉េចពាក់ព័ន្ធទៅនឹងបញ្ហាហ្នឹង? ហើយបញ្ហាហ្នឹងក៏បានលើកឡើងដោយដើមបណ្តឹងរដ្ឋប្បវេណីផងដែរ។ នៅពេលដែលយើងនិយាយអំពីការបំពានធ្ងន់ធ្ងរនៃ ជាពិសេសបទឧក្រិដ្ឋកម្មសង្គ្រាម វាគឺជាបញ្ហាអញ្ញត្រកម្មមួយ ជាការលើកលែងមួយ។ ភាគី គឺរដ្ឋភាគីមានស្ថានភាពស្ទាក់ស្ទើរក្នុងការយល់ស្របទៅតាមការវិវឌ្ឍន៍នៃច្បាប់ព្រហ្មទណ្ឌអន្តរជាតិនេះឯង ដោយហេតុថា រដ្ឋទាំងអស់នោះហើយដែលចាប់ផ្តើមធ្វើសង្គ្រាមនៅពេលនោះ។ ហើយប្រហែលជាដោយសារតែការចាប់អារម្មណ៍ក្នុងលក្ខណៈកម្រិតរបស់ខ្លួន ជាពិសេសដោយសារអធិបតេយ្យជាតិរបស់ខ្លួន ដូចដែលខ្ញុំបានលើកឡើង។

[០៩:៣៨:០៥]

ការពិភាក្សាដេញដោល និងជំហរជាច្រើនបានលើកឡើងដោយរដ្ឋនានាលើបញ្ហានេះ។ នៅពេលដែលយើងមើលការដេញដោល ហើយនៅពេលដែលយើងមើលចំនួនរដ្ឋដែលបានចុះហត្ថលេខាទៅលើភាពមិនអាចអនុវត្តបាននៃអាជ្ញាយុកាលពាក់ព័ន្ធទៅនឹងឧក្រិដ្ឋកម្មសង្គ្រាមនោះ យើងមិនអាចសន្និដ្ឋានថានៅត្រឹមឆ្នាំ១៩៧៥ រហូតដល់ឆ្នាំ១៩៧៩ វាបានទទួលឋានៈជាច្បាប់ទំនៀមទម្លាប់អន្តរជាតិ ហើយក្លាយទៅជាបទដ្ឋានអាជ្ញាបញ្ញានោះឡើយ។ ហើយវាមិនអាចក្លាយទៅជាទឡ្ហីករណ៍ដូចដែលបានលើកឡើងដោយភាគីនៅក្នុងថ្ងៃនេះនោះឡើយ។

យើងខ្ញុំនៅតែរក្សាជំហរថាពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ អាជ្ញាយុកាលអនុវត្តចំពោះអនុសញ្ញាទីក្រុងហ្សឺណែវ ដូចដែលខ្ញុំបានបង្ហាញ ហើយយើងខ្ញុំបានលើកឡើងទឡ្ហីករណ៍បឋមរបស់ខ្ញុំរួចហើយ ហើយក៏បានលើកឡើងឆ្លើយតបទៅនឹងទឡ្ហីករណ៍របស់ភាគីពីម្ខាងទៀតផងដែរ។

[០៩:៣៩:២៣]

ដូច្នេះ ខ្ញុំសូមអនុញ្ញាតឲ្យអង្គសវនាការ អស់លោក លោកស្រីចៅក្រមពិចារណាទៅលើសារណាជាលាយលក្ខណ៍អក្សររបស់ខ្ញុំ ដែលយើងខ្ញុំបានដាក់ជូន។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អរគុណ លោកមេធាវី។

ជាកិច្ចបន្ត ឈានចូលដល់របៀបវារៈមួយទៀត គឺការទាញហេតុផលដោយផ្ទាល់មាត់ទាក់ទងនឹងអញ្ញត្រកម្មស្តីពីអាជ្ញាយុកាលនៃបទល្មើស ដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៥៦។

ឥឡូវនេះអង្គជំនុំជម្រះនឹងស្តាប់នូវការទាញហេតុផលដោយផ្ទាល់មាត់លើអញ្ញត្រកម្មចុងក្រោយទាក់ទងនឹងអាជ្ញាយុកាលនៃបទល្មើស ដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៥៦។ អញ្ញត្រកម្មនេះត្រូវបានលើកឡើងដោយក្រុមមេធាវីការពារក្តីទាំងអស់។

[០៩:៤០:១៩]

ក្រុមមេធាវីការពារក្តីមានរយៈពេលពីរម៉ោងសម្រាប់ធ្វើការបង្ហាញអំពីអញ្ញត្រកម្មនេះ ដូចដែលបានចង្អុលបង្ហាញរួចហើយ។ អង្គជំនុំជម្រះនឹងផ្តល់នូវពេលវេលាចំនួន៣០នាទីសម្រាប់ក្រុមមេធាវីការពារក្តីនីមួយៗ។ លើកលែងតែក្រុមមេធាវីការពាក្តីទាំងអស់មានការព្រមព្រៀងគ្នាផ្សេងពីនេះ។

បន្ទាប់មកសហព្រះរាជអាជ្ញានឹងមានរយៈពេលមួយម៉ោង និងសហមេធាវីនាំមុខតំណាងដើម

បណ្ដឹងរដ្ឋប្បវេណីមានរយៈពេលមួយម៉ោងក្នុងការឡើងធ្វើសេចក្ដីថ្លែងការណ៍តប។ ហើយចុងក្រោយក្រុមមេធាវីការពារក្ដីទាំងអស់មានរយៈពេល៣០នាទីដើម្បីធ្វើការឆ្លើយតបវិញ។

[០៩:៤១:០២]

អង្គជម្រះមិនបានកំណត់នូវសំណួរជាក់លាក់ណាមួយ សម្រាប់ភាគីធ្វើការពិចារណានោះទេ ទាក់ទងនឹងបញ្ហាអញ្ញត្រកម្មនេះ។ ប៉ុន្តែអង្គជម្រះបានបញ្ជាក់ថាក្រុមមេធាវីការពាក្ដី អៀង សារី អាចលើកឡើងដោយផ្ទាល់មាត់អំពីបញ្ហាដែលខ្លួនបានដាក់នៅក្នុងសារណាបន្ថែម ឯកសារ E94 ទៅតាមពេលវេលាដែលបានចែកឲ្យ ប្រសិនបើក្រុមមេធាវីមានបំណង។

ជាកិច្ចបន្ត អង្គជម្រះសូមផ្ដល់វេទិកាទៅមេធាវីការពារក្ដីទាំងបួនក្រុមឡើងធ្វើសេចក្ដីថ្លែងការណ៍បង្ហាញអំពីអំណះអំណាងពាក់ព័ន្ធទៅនឹងអញ្ញត្រកម្មស្ដីពីអាជ្ញាយុកាលបទល្មើសជាតិ ដូចមានចែងនៅក្នុងព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៥៦។ សូមអញ្ជើញលោកមេធាវី កាណាវាស!

[០៩:៤២:១១]

**លោក ម៉ៃខល កាណាវាស៖**

អរុណសួស្ដីអស់លោក លោកស្រីចៅក្រមសាជាថ្មី។ មេធាវី នួន ជា មិនលើកឡើងបញ្ហាហ្នឹងទេ ដូច្នេះ ខ្ញុំសូមលើកឡើងមុន ហើយខ្ញុំសូមឲ្យលោក អាង ឧត្ដម ជាអ្នកធ្វើការបង្ហាញជាបឋម។ សូមអរគុណ។

**លោក អាង ឧត្ដម៖**

ជាបឋមខ្ញុំបាទសូមគោរពលោកចៅក្រមប្រធាន សូមគោរពលោក លោកស្រីចៅក្រម សមាជិក។ ថ្ងៃនេះខ្ញុំបាទនឹងថ្លែងប្រាស្រ័យ និងពន្យល់សង្ខេបពីបញ្ហាទាក់ទងនឹងភាពអាចអនុវត្តបានចំពោះបទឧក្រិដ្ឋថ្នាក់ជាតិ ហើយនិងបង្ហាញពីទឡ្ហីករណ៍ទាំងឡាយរបស់យើងខ្ញុំ ហើយសហភាតារបស់ខ្ញុំ លោក ម៉ៃខល កាណាវាស អាចនឹងបន្តដោយការពន្យល់លម្អិតអំពីទឡ្ហីករណ៍របស់យើងខ្ញុំ។ ហើយនិងថ្លែងប្រាស្រ័យពីសំណួរនានាដែលលោកប្រធាន លោក លោកស្រីចៅក្រមអាចចោទសួរ។

[០៩:៤៣:៤២]

ក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ត្រូវបានទទួលស្គាល់ថា ជាក្រមព្រហ្មទណ្ឌដែលចូលជាធរមានក្នុងអំឡុងពេលនៃយុត្តាធិការរបស់អ.វ.ត.ក។

ក្រមព្រហ្មទណ្ឌនេះមានបទប្បញ្ញត្តិនានាដែលដាក់ការធ្វើមនុស្សឃាត ការធ្វើទារុណកម្ម និងការ

ធ្វើទុក្ខបុកម្នេញលើសាសនាឲ្យទៅជាបទឧក្រិដ្ឋ។

ក្រមព្រហ្មទណ្ឌនេះមានចែងពីអាជ្ញាយុកាល ដែលរារាំងមិនឲ្យមានការកាត់ទោសចំពោះបទឧក្រិដ្ឋកម្មទាំងនេះ បន្ទាប់ពីរយៈពេល១០ឆ្នាំបានកន្លងផុតទៅ ដោយគិតចាប់តាំងពីពេលនៃការប្រព្រឹត្ត។

[០៩:៤៤:៤៤]

តុលាការជាទីគោរព។ អាជ្ញាយុកាលចំពោះឧក្រិដ្ឋកម្មដែលចោទប្រកាន់ថា បានប្រព្រឹត្តពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ១៩៧៩។ រយៈពេលនេះ គឺជារយៈពេលនៃយុត្តាធិការពេលវេលានៃតុលាការយើងបានផុតរលត់ចាប់ពីខែមករា ឆ្នាំ១៩៨៩មក។

ក្នុងឆ្នាំ២០០១ ច្បាប់ស្តីពីបង្កើត អ.វ.ត.ក ដើម្បីកាត់ទោសឧក្រិដ្ឋកម្មនានាដែលបានប្រព្រឹត្តក្នុងអំឡុងពេលកម្ពុជាប្រជាធិបតេយ្យត្រូវបានអនុម័តឡើង។

ក្នុងនោះមាត្រា៣ នៃច្បាប់នេះ ផ្តល់ឲ្យអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានូវយុត្តាធិការលើឧក្រិដ្ឋកម្មនៃការធ្វើមនុស្សឃាត ការធ្វើទារុណកម្ម និងការធ្វើទុក្ខបុកម្នេញលើសាសនា ដែលមានចែងក្នុងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ហើយបានពន្យារពេលអាជ្ញាយុកាល១០ឆ្នាំបន្ថែម ឡើងដល់២០ឆ្នាំ។

[០៩:៤៦:១៤]

ក្នុងឆ្នាំ២០០៤ ច្បាប់នេះត្រូវបានធ្វើវិសោធនកម្មទៀត។ ច្បាស់ប្រាដកណាស់ថា ព្រោះថាពេលវេលារយៈពេល២០ឆ្នាំនៃអាជ្ញាយុកាលនេះនឹងផុតរលត់មុនពេលដែលរឿងក្តីទាំងឡាយអាចចាប់ផ្តើមនៅ អ.វ.ត.ក។

យើងឃើញដូច្នេះហើយ ទើបការពន្យារអាជ្ញាយុកាលតាមរយៈមាត្រា៣ត្រូវបានបន្ថែមពី២០ឆ្នាំ ដល់រហូតដល់៣០ឆ្នាំ។

ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មានការផ្លាស់ប្តូរតាមពេលវេលា ហើយធ្វើវាឲ្យហាក់បីដូចជាអាជ្ញាយុកាលមិនទាន់បានផុតរលត់អ៊ីចឹងឯង។ ករណីនេះបង្កឲ្យមានបញ្ហា ពីព្រោះគោលការណ៍នីត្យានុកូលភាពបានហាមឃាត់ៗការអនុវត្តប្រតិសកម្មចំពោះច្បាប់។ វាក៏ជាបញ្ហាផងដែរ ពីព្រោះច្បាប់ស្តីពីការបង្កើត អ.វ.ត.ក អនុវត្តតែនៅ អ.វ.ត.ក ប៉ុណ្ណោះ។

[០៩:៤៧:៥២]

នេះមានន័យថា លោក អៀង សារី អាចត្រូវរងការចោទប្រកាន់ពីបទឧក្រិដ្ឋដែលជនជាប់ចោទផ្សេងទៀតក្នុងស្ថានភាពស្រដៀងគ្នានេះ ក្នុងតុលាការដទៃទៀតនៅប្រទេសកម្ពុជាមិនអាចរងការចោទ

ប្រកាន់។ ការអនុវត្តបែបនេះ គឺរំលោភបំពានលើសិទ្ធិរបស់គាត់ ក្នុងការទទួលបានភាពស្មើគ្នានៅចំពោះមុខច្បាប់។

តុលាការជាទីគោរព! ចៅក្រមស៊ើបអង្កេតម្នាក់ក្នុងចំណោមចៅក្រមស៊ើបអង្កេតទាំងពីរប្រាកដជាបានដឹងពីបញ្ហានេះ។ នៅក្នុងដីកាដំណោះស្រាយ សហចៅក្រមស៊ើបអង្កេតបានថ្លែងបញ្ជាក់ថា ពួកខ្លួនបានប៉ុនប៉ងៗចេញផ្សាយអត្ថបទរួមគ្នាមួយស្តីពីការជំនុំជម្រះក្តីពីរដងចំពោះអង្គហេតុដដែល។ ស្តីពីអាជ្ញាយុកាលចំពោះបទឧក្រិដ្ឋកម្មថ្នាក់ជាតិដែលពាក់ព័ន្ធ និងស្តីពីផលប៉ះពាល់នៃសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០០១។ ក៏ប៉ុន្តែ ពួកគេមិនអាចធ្វើបានឡើយក្នុងការប៉ុនប៉ងចេញអត្ថបទរួមបែបនេះ។

[០៩:៤៩:៥៦]

សហចៅក្រមស៊ើបអង្កេតមិនបានបរិយាយលម្អិតទៅលើគោលជំហរទីទៃពីគ្នារបស់ពួកគេ លើបញ្ហាទាំងនេះឡើយ។ សហចៅក្រមស៊ើបអង្កេតបានថ្លែងបញ្ជាក់ថា ពួកគេបានដឹងខ្លួនឯងថា ជាប់គាំងរាំងខ្ទាស់ខាងនីតិវិធីដែលបណ្តាលមួយផ្នែកមកពីរចនាសម្ព័ន្ធកូនកាត់របស់តុលាការនេះ។ សហចៅក្រមស៊ើបអង្កេតបានសម្រេចជ្រើសរើសមិនប្រើយន្តការនីតិវិធីនៅក្នុងវិធានផ្ទៃក្នុង ដើម្បីដោះស្រាយជម្លោះខ្វែងគំនិតគ្នានេះទេ។ ដោយជឿជាក់ថា ការធ្វើបែបនេះអាចនឹងៗបង្កហានិភ័យគ្រោះថ្នាក់ដល់ដំណើរការតាមផ្លូវច្បាប់ទាំងមូល ហើយពួកគេសម្រេចចិត្តទុកបញ្ហានេះ ឲ្យអង្គជំនុំជម្រះសាលាដំបូងធ្វើការសម្រេចថា ត្រូវប្រកាន់យកវិធានការផ្នែកនីតិវិធីអ្វី ទាក់ទងនឹងឧក្រិដ្ឋកម្មដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ នេះ។ យើងខ្ញុំស្នើសុំមេត្តាពិចារណាថា មាត្រា៣(ថ្មី) មិនអាចយកមកអនុវត្តបានឡើយ ពីព្រោះ៖

ក) សហចៅក្រមស៊ើបអង្កេតមានការខ្វែងគំនិត មិនបានយល់ស្របនឹងគ្នាថា មាត្រានេះអាចអនុវត្តបាន ឬអត់។ ដូច្នេះហើយ មាត្រានេះ មិនអាចយកមកអនុវត្តបានទេ នៅចំពោះមុខ អ.វ.ត.ក យើងនេះ។

ខ) ការអនុវត្តមាត្រានេះ គឺរំលោភបំពានលើសន្និជាមូលដ្ឋានរបស់លោក អៀង សារី ក្នុងការទទួលបានការប្រព្រឹត្ត ដោយស្មើភាពគ្នានៅចំពោះច្បាប់ និង

គ) ការអនុវត្តមាត្រានេះ រំលោភបំពានលើគោលការណ៍អប្រតិសកម្ម។

[០៩:៥៣:០៥]

តុលាការជាទីគោរព! សំណើសុំការពិចារណាផ្ទាល់មាត់របស់ខ្ញុំ លើបញ្ហានេះចប់ត្រឹមនេះ។ សហភាតារបស់ខ្ញុំ និងឡើងមកថ្លែងលម្អិតពីបញ្ហានេះ ជូនអង្គសវនាការ ប្រសិនបើគាត់មាន។

សូមអរគុណលោកប្រធាន លោក លោកស្រីចៅក្រម ដែលយកចិត្តទុកដាក់ស្តាប់ទឡ្ហីករណ៍របស់ខ្ញុំបាទ។ សូមអរគុណ។

**លោក ម៉ៃខល កាណាវាស៖**

សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម ដូចដែលបានលើកឡើងនៅក្នុងសារណាលាយលក្ខណ៍អក្សររបស់យើងខ្ញុំនោះ។

[០៩:៥៥:១៧]

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះដោយដើម្បីឲ្យបានកាន់ឲ្យបានច្បាស់លាស់ នូវការបែងចែកពេលវេលាសម្រាប់មេធាវីការពារក្តីទាំងបួនក្រុម ដែលអង្គជំនុំជម្រះបានបែងចែករួចហើយ សរុបមានរយៈពេលពីរម៉ោង។ ហើយអម្បាញ់មិញនេះឃើញថាឈានចូលដល់ទៅក្រុមមេធាវីការពារក្តីលោក អៀង សារី ឡើងធ្វើសេចក្តីថ្លែងការណ៍មុន ហើយមេធាវី នួន ជា តាមរយៈមេធាវីការពារក្តីលោក អៀង សារី ដែលបាននិយាយថាមេធាវីការពារ នួន ជា មិននិយាយអំពីបញ្ហាប្រធានបទនេះទេ។ អ៊ីចឹងទេ អង្គជំនុំជម្រះសួរទៅមេធាវី នួន ជា ឲ្យបានច្បាស់លាស់ ថាតើលោកមិនមានបំណងក្នុងការនិយាយដែរឬទេ? ប្រសិនបើបង្ហាញជំហរច្បាស់លាស់នោះ អង្គជំនុំជម្រះនឹងធ្វើការកំណត់ពេលវេលាសម្រាប់ដល់ក្រុមផ្សេងទៀតដើម្បីលៃលកចែករំលែកពេលវេលាហ្នឹងឲ្យសមស្របទៅតាមអ្វី ដែលអង្គជំនុំជម្រះបានធ្វើការបែងចែករួចហើយ។ ពីព្រោះនៅក្នុងនេះ អង្គជំនុំជម្រះបានជម្រាបហើយ ថាលើកលែងតែក្រុមមេធាវីការពារក្តីទាំងអស់ មានការព្រមព្រៀងគ្នាផ្សេងពីនេះ នៅក្នុងការកម្រិតរយៈពេលពីរម៉ោងដែលបានចែកជូននេះ។

[០៩:៥៦:៤៥]

**លោក ម៉ៃខល ផេសមិន៖**

យើងខ្ញុំ-- យើងមិននិយាយទេ ដូចដែលមេធាវីលោក អៀង សារី បញ្ជាក់អ៊ីចឹង។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវី។ ចុះ មេធាវីការពារក្តីលោកស្រី អៀង ធីរិទ្ធ មានបំណងក្នុងការធ្វើសេចក្តីថ្លែងការណ៍ពាក់ព័ន្ធនឹងអញ្ញត្រកម្មនេះទេ?

**លោក ផាត់ ពៅស៊ាង៖**

សូមគោរពក្រុមប្រឹក្សាអង្គជំនុំជម្រះសាលាដំបូង គឺមេធាវីអ្នកស្រី អៀង ធីរិទ្ធ ក៏មិនមានបំណង នៅក្នុងការធ្វើសេចក្ដីសន្និដ្ឋានផ្ទាល់មាត់ទៀតដែរ ពីព្រោះបានសរសេរជាលាយលក្ខណ៍អក្សររួចហើយ។ បាទ សូមអរគុណ។

[០៩:៥៧:៣១]

**ប្រធានអង្គជំនុំ៖**

ចុះ មេធាវីការពារក្ដីលោក ខៀវ សំផន?

សូមអញ្ជើញលោកមេធាវី ស សូវាន!

**លោក ស សូវាន៖**

អង្គសាលាដំបូង សូមគោរពក្រុមអយ្យការ សូមគោរពលោកមេធាវីខាងជនរងគ្រោះ និងក្រុម មេធាវីជនជាប់ពិរុទ្ធ។

ខ្ញុំបាទមិនឲ្យយូរវែងឆ្ងាយដើម្បីឲ្យដំណើរតុលាការបាន ជឿនលឿន។ សុំ ពីព្រោះខ្ញុំដូចសហ ភាតាខ្ញុំមានប្រសាសន៍អំមិញនេះ ថាបានសរសេរទៅជម្រាបអង្គជំនុំជម្រះសាលាដំបូងអស់ហើយពីរឿង អញ្ញត្រកម្មដែលស្ដីអំពី សុំទោសណ៎ែ! *ប្រេសស្ក្រិបស៊ីង* អាជ្ញាយុកាលបទល្មើសអាជ្ញា នៅក្នុងក្រម៥៦។ ប៉ុន្តែខ្ញុំស្ដាប់មើលមកយើងដូចថាមិនសូវយល់ហើយ ប្រើពាក្យ ខ្ញុំមិនសូវយល់ទៅទៀត ប្រើពាក្យអំមិញ អាជ្ញាអី បញ្ញាណ៎ា។ ឥឡូវអ៊ីចេះ ដើម្បីឲ្យដំណើរការទៅលឿន ខ្ញុំសូមលោកប្រធាន មេត្តាឲ្យខ្ញុំតែ ដប់ប្រាំដប់មីនុត ខ្ញុំមិនឲ្យនេះទេ ទុកពេលវេលា។ ខ្ញុំសូមជម្រាប--

[០៩:៥៩:០៤]

**ប្រធានអង្គជំនុំ៖**

លោកមេធាវី អង្គជំនុំជម្រះគ្រាន់តែចង់ដឹងថា តើពាក់ព័ន្ធនឹងបញ្ហាអញ្ញត្រកម្មអាជ្ញាយុកាលបទ ល្មើសជាតិ ដែលអង្គជំនុំជម្រះបានកំណត់ក្នុងការបែងចែកពេលវេលាឲ្យក្រុមមេធាវីការពារក្ដីនីមួយៗ សាមសិបមីនុតនេះ តើលោកប្រើសិទ្ធិនៅក្នុងការធ្វើសេចក្ដីថ្លែងការណ៍ បង្ហាញអំពីអំណះអំណាងរបស់ លោក ពាក់ព័ន្ធនឹងអញ្ញត្រកម្មនេះ ដែរឬទេ? ប្រសិនបើលោកឆ្លើយថា ទេ អង្គជំនុំជម្រះនឹងឲ្យ ប្រគល់ ឲ្យវេទិកាទៅមេធាវីការពារក្ដី អៀង សារី គាត់ប្រើប្រាស់ កម្រិតមួយដែលលទ្ធភាពដែលពេលវេលា បានបែងចែកអស់ហើយ។ តែបើសិនជាលោកថា ត្រូវចំណាយពេលវេលា នឹងធ្វើសេចក្ដីថ្លែងការណ៍

អង្គជំនុំជម្រះនឹងលៃពេលវេលាបែងចែករវាងក្រុមមេធាវីខាងក្រុមលោក ហើយនិងក្រុមមេធាវីការពារ អៀង សារី តែប៉ុណ្ណោះ។ បញ្ហាផ្សេងទៀត អង្គជំនុំជម្រះមិនអនុញ្ញាតឲ្យលោកនិយាយទេ។

[១០:០០:០៣]

**លោក ស សូវាន៖**

សូមគោរពលោកប្រធាន! យកថាអំមិញហ្នឹង ថាប្អូនក្រុមហ្នឹង ខ្ញុំមាន៥០ អ៎ះ ៣០ នាទី ខ្ញុំមិនសុំគេទេនៅក្នុង៣០ នោះខ្ញុំសុំតែ២០ នាទីទេ។ តើលោកប្រធានមេត្តាអនុញ្ញាតទេ? ខ្ញុំនិយាយតែពីរឿងអញ្ញត្រកម្ម អាជ្ញាយុកាលក្រមព្រហ្មទណ្ឌ៥៦--

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។

**លោក ស សូវាន៖**

សូមៗ--

**ប្រធានអង្គជំនុំ៖**

បាទ, អរគុណៗ។ អង្គជំនុំជម្រះចង់បានតែប៉ុណ្ណឹងទេ ដើម្បីលៃពេលវេលាជាមួយនឹងលោក កាណាវាស។ ចាំ កាណាវាស ចប់ អង្គជំនុំជម្រះនឹងផ្តល់វេទិកាទៅលោកហើយ។

[១០:០០:០៦]

**លោក ស សូវាន៖**

សូមអរគុណលោកប្រធាន។ ដូច្នេះខ្ញុំចង់ជម្រាបអំពីអាជ្ញាយុកាល--

**ប្រធានអង្គជំនុំ៖**

អង្គុយសិនទៅលោកមេធាវី គឺកាណាវាស មិនទាន់បាននិយាយទេអំមិញ មិនទាន់បាននិយាយចប់ទេ។ អ៊ីចឹងធ្វើប្រតិចារឹក ក៏វាលំបាកដែរ។ អ៊ីចឹងគឺ--

**លោក ស សូវាន៖**

សុំទោសៗ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី លោក កាណាវាស!

[១០:០១:០២]

**លោក ម៉ៃខល កាណាវាស៖**

លោកប្រធានសូមគោរព លោក លោកស្រីចៅក្រម។

យើងខ្ញុំសូមថ្លែងអំណរគុណដល់អង្គជំនុំជម្រះ ដែលអនុញ្ញាតឲ្យខ្ញុំលើកឡើងបញ្ហាហ្នឹង។ ដូច្នេះ ចំពោះចំណុចនេះ គឺខ្ញុំនឹងមិនលើកឡើងហួសពេលរយៈកំណត់នោះទេ យ៉ាងហោចណាស់ យ៉ាងច្រើនបំផុត ខ្ញុំនឹងលើកឡើងនៅក្នុងរយៈពេល១៥នាទីតែប៉ុណ្ណោះ។

ខ្ញុំចង់លើកឡើង និងពង្រឹងបន្តិចបន្តួចពាក់ព័ន្ធទៅនឹងទឡ្ហីករណ៍មាត្រា៣ និងទឡ្ហីករណ៍ទាំងឡាយដែលបានលើកឡើងដោយខាងសហព្រះរាជអាជ្ញា។ ចំពោះមាត្រា៣(ថ្មី) ឧក្រិដ្ឋកម្មអន្តរជាតិមិនអាចអនុវត្តបាននោះទេ ដោយសារតែវានឹងរំលោភទៅលើអប្រតិសកម្មនៃច្បាប់។

[១០:០១:៥៩]

យើងសូមលើកឡើងថា ក្រុមប្រឹក្សាធម្មនុញ្ញបានសម្រេចថា ការពន្យារនៃការអនុវត្តអាជ្ញាយុកាលក្នុងមាត្រា៣ មានលក្ខណៈស្របធម្មនុញ្ញ។ យើងលើកឡើងថា ការសម្រេចនោះគឺជាការភ័ន្តច្រឡំ។ យើងទទួលស្គាល់ថា លោក លោកស្រីចៅក្រមនៅ អ.វ.ត.ក មិនមានអំណាច និងសមត្ថកិច្ចក្នុងការសម្រេចអំពីធម្មនុញ្ញភាពនោះទេ។ ក៏ប៉ុន្តែទោះបីជា យើងសន្មតថាវាជាបញ្ហាធម្មនុញ្ញភាពក៏ដោយ គោលការណ៍នៃអប្រតិសកម្មនៃច្បាប់ គឺជាគោលការណ៍មូលដ្ឋានដែលលោក អៀង សារី មានសិទ្ធិមិនអាចយកច្បាប់អនុវត្តចំពោះគាត់ដោយប្រតិសកម្មនោះទេ។ ដូច្នេះ ខ្ញុំនឹងលើកទឡ្ហីករណ៍ពាក់ព័ន្ធទៅនឹងចំណុចនេះ។ ខ្ញុំលើកឡើងមាត្រា៦ នៃក្រមឆ្នាំ១៩៥៦ ដែលរារាំងការអនុវត្តប្រតិសកម្មនៃច្បាប់ ហើយវាក៏ផ្ទុយទៅនឹងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយផងដែរ។ នៅក្នុងនោះ គឺក៏បានទទួលស្គាល់មិនឲ្យអនុវត្តច្បាប់ដោយប្រតិសកម្មផងដែរ គឺហាមឃាត់ប្រតិសកម្មនៃច្បាប់។

[១០:០៣:៣៧]

ដូច្នេះ យើងខ្ញុំបានលើកឡើងដោយលម្អិតរួចហើយ នៅក្នុងសារណាជាលាយលក្ខណ៍អក្សររបស់ខ្ញុំ។ ខ្ញុំមិនលើកឡើងទៀតទេ។ មាត្រា-- សហព្រះរាជអាជ្ញាលើកឡើងថា មាត្រា៣ អាចអនុវត្តបានដោយគ្មានការរំលោភទៅលើគោលការណ៍ប្រតិសកម្មនៃច្បាប់នោះទេ។ ដោយសារតែអាជ្ញាយុកាលនៅក្នុងមាត្រា១០៩ នៃក្រមឆ្នាំ១៩៥៦ អាចព្យួរទុកបាន ហើយគេអាចពន្យារបានមុនពេលដែលវាផុត។

ដូច្នេះ ខ្ញុំសូមលើកឡើងថា វាអាចមានការព្យួរអាជ្ញាយុកាល។ ចំពោះគោលការណ៍ច្បាប់ យើង

ទទួលស្គាល់ថា អាជ្ញាយុកាលនៅក្នុងកាលៈទេសៈមួយចំនួន អាចត្រូវបានគេព្យួរទុកបាន។ ឧទាហរណ៍ ថា នៅពេលដែលគេមិនមានការស៊ើបអង្កេត។ ដូច្នេះចំណុចនេះ វាជាស្ថានជាមួយដែលអាចព្យួរអាជ្ញាយុកាល។

[១០:០៥:៣៧]

យើងខ្ញុំសូមលើកឡើងថា នៅក្នុងរឿងក្តីនេះ យើងមានការជំនុំជម្រះឆ្នាំ១៩៧៩ ដូច្នេះវាបង្ហាញយ៉ាងច្បាស់ថា វាមានហេតុការណ៍មួយកើតឡើងទៅលើបុគ្គល ហើយយើងអាចចាត់ទុកថា ការជំនុំជម្រះនៅពេលនោះគឺជាការចោទប្រកាន់មួយ ដែលអាចព្យួរទៅលើអាជ្ញាយុកាល ក៏ប៉ុន្តែក្រោយឆ្នាំ១៩៧៩ មិនមានភស្តុតាង ឬក៏កិច្ច ឬក៏ការស៊ើបអង្កេតណាមួយផ្សេងពីនោះទៀតឡើយ។ វាអាចបង្ហាញឲ្យយើងឃើញថា វាគឺដោយសារតែឆន្ទៈនយោបាយ។ ការមិនមានឆន្ទៈនយោបាយមិនមែនជាអញ្ញត្រកម្ម និងករណីលើកលែងនោះទេ។

[១០:០៥:២៦]

យើងសូមលើកឡើងថា នៅក្នុងប្រព័ន្ធតុលាការក្នុងប្រទេសកម្ពុជាក្រោយឆ្នាំ១៩៧៩ ដល់ ១៩៩១ គឺប្រព័ន្ធតុលាការបានដំណើរការឡើងត្រឹមត្រូវ។ នៅក្នុងប្រទេសកម្ពុជា ប្រទេសកម្ពុជាមានសមត្ថភាពក្នុងការស៊ើបអង្កេត ប្រសិនបើខ្លួនមានចេតនា និងគោលបំណងក្នុងការស៊ើបអង្កេត ប៉ុន្តែប្រទេសកម្ពុជាជ្រើសរើសមិនធ្វើការស៊ើបអង្កេត។ ហេតុផលនោះគឺថា មានការរារាំង។ នៅក្នុងរបាយការណ៍ យើងឃើញថា ប្រព័ន្ធតុលាការមានការដំណើរការល្អ ហើយការស៊ើបអង្កេតបានធ្វើឡើងក្នុងអំឡុងពេលនោះ។ ក៏ប៉ុន្តែដូចករណីរ០០៣ និង០០៤ នោះ គឺប្រហែលដោយសារតែមិនមានឆន្ទៈនយោបាយក្នុងការចោទប្រកាន់ ហេតុដូច្នេះហើយ ទើបមិនមានការស៊ើបអង្កេត ឬក៏មិនមានការតាមដានទៅលើករណីទាំងពីរនេះ។

[១០:០៦:៣០]

ជាទឡ្ហីករណ៍បន្ទាប់ទៀត សហព្រះរាជអាជ្ញាបានលើកឡើងថា ការពន្យារអាជ្ញាយុកាល គឺជាបញ្ហាពាក់ព័ន្ធទៅនឹងនីតិវិធី វាមិនមានជាបញ្ហាសារធាតុនោះទេ។ ដូច្នេះ គោលការណ៍នៃការអប្រតិសកម្មនៃច្បាប់គឺ មិនអាចយកមកអនុវត្តទៅបាននោះទេ។ វាជាបញ្ហានីតិវិធី មិនមែនជាបញ្ហានៃសារធាតុនោះទេ។ ខ្ញុំសូមបង្ហាញថា វាមិនមែនថា វាជាបញ្ហានីតិវិធី ឬបញ្ហាសារធាតុនោះទេ ច្បាប់ពន្យារអាជ្ញាយុកាលគឺ រារាំងការកាត់ទោស និងការចោទប្រកាន់ ដែលវាចែងមាននៅក្នុងនីតិវិធី ទោះបី

វាជាបញ្ហានីតិវិធីក៏ដោយ លោក អៀង សារី នៅតែទទួលបាននីតិវិធីក្នុងការស្វែងរកយុត្តិធម៌ និងនីតិវិធីតាមច្បាប់សារធាតុក្នុងការទទួលបានយុត្តិធម៌ដដែល។

[១០:០៧:៣១]

យើងខ្ញុំបានបង្ហាញនៅក្នុងសារណាជាលាយលក្ខណ៍អក្សរ បានបង្ហាញភស្តុតាងថា រដ្ឋបានធ្វើការកែប្រែអាជ្ញាយុកាលចំពោះឧក្រិដ្ឋកម្ម ជាពិសេសចំពោះករណីដែលពន្យារវំលោភទៅលើគោលការណ៍អប្រតិសកម្មនៃច្បាប់។ យើងអាចឃើញ មើលឃើញនៅក្នុងអនុសញ្ញាឆ្នាំ១៩៦៨ ទាក់ទងទៅនឹងអប្រតិសកម្មនៃច្បាប់ឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ ដូច្នេះ ខ្ញុំសូមឲ្យលោក លោកស្រីចៅក្រម ពិចារណាអនុសញ្ញានោះដោយហ្មត់ចត់ យើងឃើញមានការពិភាក្សា និងហេតុផលបង្ហាញថា ហេតុអ្វីបានជារដ្ឋមិនឯកភាពទៅលើសញ្ញានេះ។ ករណីនោះ និងហេតុផលនោះគឺថា វាមានការរាំងស្ទះនៅពេលនោះ គេមិនអាចអនុម័តច្បាប់ ហើយគេមិនអាចអនុម័តច្បាប់ក្រោយពេលដែលអាជ្ញាយុកាលនោះវាផុតរួចទៅហើយនោះឡើយ។ យើងក៏មិនអាចចោទប្រកាន់ផងដែរ ប្រសិនបើអាជ្ញាយុកាលនោះវាផុតផងដែរ។ ខ្ញុំសូមអរគុណលោក លោកស្រីចៅក្រម ដែលអនុញ្ញាតឲ្យខ្ញុំលើកឡើងទៅលើបញ្ហានេះ ដែលវាពាក់ព័ន្ធទៅនឹងបញ្ហាអង្គច្បាប់។ សូមអរគុណលោក លោកស្រីចៅក្រម។

[១០:០៨:៥៨]

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវី។ ជាកិច្ចបន្ត អង្គជំនុំជម្រះសូមផ្តល់វេទិកាទៅមេធាវីការពារក្តីលោក ខៀវ សំផន មេធាវី ស សូវាន ដែលមានបំណងក្នុងការធ្វើសេចក្តីថ្លែងការណ៍ បង្ហាញអំពីអំណះអំណាងពាក់ព័ន្ធជាមួយនឹងអញ្ញត្រកម្ម ដែលអាជ្ញាយុកាលនៃបទល្មើសជាតិ។ សូមអញ្ជើញ!

**លោក ស សូវាន៖**

សូមគោរពអង្គជំនុំជម្រះសាលាដំបូង គោរពលោកប្រធាន និងគោរពទាំងអស់ក្រុមអយ្យការ មេធាវីជនរងគ្រោះ និងគោរពមេធាវី និងមហាជនទាំងអស់។

ខ្ញុំបាទមិននិយាយឡើងវិញទេ ពីព្រោះលោក កាណាវាស គាត់បានជម្រាបខ្លះហើយ ប៉ុន្តែខ្ញុំសង្កត់ត្រង់ប៉ុណ្ណោះទេ មិនមែនថា កូនក្តីខ្ញុំ នៅក្រោយខ្ញុំនេះ គាត់មានតួនាទីជាប្រធានរដ្ឋ ហើយនៅក្នុងភាសាអង់គ្លេសនោះ គេហៅ *ហ៊ិតអហ្វស្តេត* ហើយបើបារាំងគេថា *សេហ្វដឺឡេតា* ខ្មែរយើងថា ប្រមុខរដ្ឋ។ ប៉ុន្តែនៅក្នុងរបបប្រជាធិបតេយ្យហ្នឹង គេមិនថាអីចឹងទេ គេថា *ប្រេស៊ីដង់ឌុយប្រេស៊ីដ្យូម* នៅក្នុង

ហ្នឹងវាមានបីនាក់ បើខ្ញុំមិនភ្លេចទេគឺ លោក ខៀវ សំផន ជាប្រធាន *ឡឺប្រេស៊ីដង់* ពីរនាក់ទៀត រស់ ញឹម និង សោ ភឹម។ ក៏ប៉ុន្តែ ខ្ញុំសូមកត់សម្គាល់អ៊ីចេះថា កូនក្ដីខ្ញុំអតីតប្រធានរដ្ឋក៏ថាបាន ប្រមុខរដ្ឋក៏ថាបាន លោកទទួលមុខងារពីព្រះមហាក្សត្រ ដែលលោកលាលែងអំពីតំណែងនៅខែបួន ដូចមេសា មិនដឹង ៧៦ ពីខែបួន ៧៦ រហូតដល់ធ្លាក់របបប្រជាធិបតេយ្យនេះ មានរដ្ឋធម្មនុញ្ញតែមួយគត់ គឺរដ្ឋធម្មនុញ្ញរបបកម្ពុជាប្រជាធិបតេយ្យនេះ គឺឆ្នាំ១៩៧៦ ដូច្នេះគ្មានដូរទេ។

[១០:១១:១៥]

គាត់ឡើងមានតួនាទីជាប្រមុខរដ្ឋក៏បាន ឬមួយគឺជាប្រធានរដ្ឋ ហើយខ្ញុំចង់ជម្រាបថា ឥឡូវហ្នឹងយើងនិយាយពីអញ្ញត្រកម្ម អំពីអាជ្ញាយុកាលបទល្មើសនៅឆ្នាំ១៩៥៦។ បើយើងនិយាយអំពីតួនាទីគាត់ ខ្ញុំអាចប្រដូចលោក សាកូហ្ស៊ី រាល់ថ្ងៃអ៊ីចឹងដែរ នៅក្នុងប្រទេស ដែលមានប្រជាធិបតេយ្យសេរីពហុបក្ស។ បើនៅក្នុងប្រទេសប្រជាធិបតេយ្យ ប្រជាមានិតនោះវាមានបញ្ហា ខ្ញុំមិនបាច់វែងឆ្ងាយទេ។ ខ្ញុំវិលមកអញ្ញត្រកម្មអំពីអាជ្ញាយុកាល នែ៎ដែលមានចែងនៅក្នុងក្រម៥៦ គេថា បើមានអ្នកណាមួយប្រព្រឹត្តបទល្មើសឧក្រិដ្ឋ ខ្ញុំនិយាយតែពីឧក្រិដ្ឋទេ បណ្ដឹងអាជ្ញាត្រូវរលត់កាលណាគេមិនប្ដឹងក្នុងរយៈពេល ១០ឆ្នាំចាប់រាប់តាំងពីថ្ងៃប្រព្រឹត្តបទល្មើល។ ប៉ុន្តែខ្ញុំសោកស្ដាយណាស់នៅកន្លែងនេះ ពីព្រោះវាមានអាជ្ញាយុកាល បណ្ដឹងអាជ្ញាវាមានអាជ្ញាយុកាលទោស អាជ្ញាទោសនៅក្នុងឆ្នាំ១៩៥៦នេះ វាមានដល់ ២០ឆ្នាំ បើតុលាការទទួលស្គាល់ថា អ្នកនោះឯងជាប់គុក១០ឆ្នាំ ហើយបើរត់គេចមិនឲ្យគេចាប់បាន គាត់គេច២០ឆ្នាំ។ ២០ឆ្នាំ មួយថ្ងៃ គាត់មកអត់អ្នកណាចាប់ទេ អាជ្ញាយុកាលទោស ជាប់ទោស។

[១០:១២:៤៥]

មួយទៀត អាជ្ញាយុកាលបណ្ដឹងអាជ្ញា ឥឡូវនេះយើងកំពុងតែនិយាយអាជ្ញាយុកាលបណ្ដឹងអាជ្ញា។ ពីម្សិលមិញហ្នឹង ជជែកគ្នាពីរឿងឯកឧត្តម សូមទោសមិនមែន លោក អៀង សារី គាត់ទាមទារ យើងថា អ្ហូ!ស្អីឯណានែ៎ លោកចៅក្រម នែ៎លោកប្រធាន អ៎!លោកមេធាវីខាងជនរងគ្រោះថា ស្អីពាក្យភាសាបារាំងគេថា *អាអាំនេសធី* នោះ *អុបតឺនុយ* នែ៎ពីរឿងគេ-- តែធម្មតាទេ កាលណាតែគេចរចាដើម្បីបញ្ចប់សង្គ្រាម ខ្ញុំមិនមែនកាន់ជើងលោក អៀង សារី គាត់មានមេធាវីគាត់កាន់ហើយ។ វាជាថ្នូរ រាល់ថ្ងៃហ្នឹងគេប្រាប់ ហ្កាដាហ្វី នែ៎រាល់ថ្ងៃនេះ ថាដាក់អាវុធទាំងអស់ទៅ ខ្ញុំឲ្យអ្នកឯងរួចខ្លួនមិនចាប់ចង មិនប្ដឹង មិនអី អាហ្នឹងវាជាថ្នូរ ធម្មតាវាមានថ្នូរហើយ។

[១០:១៣:៤២]

**ប្រធានអង្គជំនុំ៖**

មេធាវី ស សូវាន ការកំណត់នូវរបៀបវារៈដែលត្រូវធ្វើសេចក្តីថ្លែងការណ៍ ដើម្បីបង្ហាញនេះគឺជុំវិញបញ្ហាអញ្ញត្រកម្មអាជ្ញាយុកាលនៃបទល្មើសជាតិ តាមក្នុងក្រមព្រហ្មទណ្ឌព្រះរាជាឆ្នាំ១៩៥៦ ដែលតើវាមានបញ្ហាអនុវត្តបានដែរឬទេ នៅក្នុង អ.វ.ត.ក យើងនេះពាក់ព័ន្ធនឹងបទល្មើសចំនួនបី ដែលចោទប្រកាន់លើជនជាប់ចោទ។ នេះជាមូលបញ្ហា នៃបញ្ហាអញ្ញត្រកម្ម។

**លោក ស សូវាន៖**

ខ្ញុំសូមគាំទ្រ សូមទោសលោកប្រធាន។ ខ្ញុំសូមគាំទ្រសេចក្តីសន្និដ្ឋានរបស់លោកមេធាវី អៀង សារី កាណាវាស។ ខ្ញុំគ្រាន់តែថា ចង់បញ្ជាក់ថា ន៎ែ ខ្ញុំបញ្ជាក់ហ្នឹងមិនឲ្យហួសពេលវេលាទេ ពីព្រោះអ៊ីចេះ ខ្ញុំស្តាប់ពាក្យទៅមើលឃើញថា អាជ្ញាយុកាលហ្នឹង គេចង់បំភ្លេចឲ្យសង្គមជាតិហ្នឹង វាចូលទៅវិញទៅ។ ហេតុដូច្នេះ អាជ្ញាយុកាលនេះ ន៎ែគេនិយាយអំមិញហ្នឹងហើយ គេថាប្រតិសកម្មនៃបទល្មើសអាជ្ញាប្រតិសកម្ម វាគ្មានប្រតិសកម្មទេ ឃើញទេ។ ហើយបើកាលណា រួចប្រតិសកម្មរឿងទោសធ្ងន់ធ្ងរទៅទៀត ទោសធ្ងន់ធ្ងរគេហាមឃាត់ មិនឲ្យមានប្រតិសកម្មទេ ខ្ញុំចង់ជម្រាបនៅទីនេះមានហ្នឹងហើយ។

[១០:១៥:២៣]

ឥឡូវបានថា ខ្ញុំមិនឲ្យខាតពេលទេ ទុកឲ្យដំណើរការទៅ ពីព្រោះបាននិយាយអស់ហើយ។ ខ្ញុំគ្រាន់តែជម្រាបអ៊ីចេះថា ចង់បានសង្គមជាតិបំភ្លេច ពីព្រោះឪពុកខ្ញុំ គ្រួសារខ្ញុំក៏ស្លាប់ក្នុងហ្នឹងនៅនឹងមុខខ្ញុំនោះ ជួយឪពុកខ្ញុំហើយ ដើម្បីឲ្យវាស្លាប់ទៅមានស្អីមួយ ដើម្បីតបស្នងសងគុណថា បងប្អូនយើងស្លាប់ ខ្ញុំសូមគោរពទាំងអស់។ គ្រាន់តែខ្ញុំសុំគ្រាន់តែរកយុត្តិធម៌។ កូនក្តីខ្ញុំ ខ្ញុំសួរដែរបើគាត់បានប្រព្រឹត្តមែនទេ ប្រាប់គេទៅ ខ្ញុំសុំសួរ *កុងស្តង់អាតេណេអង់* (និយាយភាសាបារាំង)។ ខ្ញុំអត់ឃុបឃិតជាមួយអ្នកណាកាប់ប្រជាពលរដ្ឋខ្ញុំទេ អ្នកណាក៏ដោយ អ្នកឯងជនជាតិអីក៏ដោយ ជនជាតិអ្នកណាក៏ដោយ ខ្ញុំមិនសុខចិត្តជាដាច់ខាត ហើយខ្ញុំសុំតុលាការនេះឲ្យមានការពិត កុំខ្លាចឲ្យសោះ ហើយខ្ញុំស្លាប់ទៅជាមួយខ្ញុំយកទៅក្នុងខ្លួនខ្ញុំ ឲ្យខ្មែរទាំងអស់គ្នាដឹងរឿងខ្មែរទាំងអស់។ សូមអរគុណលោកប្រធាន។ ខ្ញុំសូមឈប់ប៉ុណ្ណឹង។

[១០:១៦:៥៣]

**ប្រធានអង្គជំនុំ៖**

ជាកិច្ចបន្ត អង្គជំនុំជម្រះសូមអញ្ជើញសហព្រះរាជអាជ្ញា សូមផ្តល់នូវវេទិកាជូនទៅសហព្រះរាជ

អាជ្ញា ដើម្បីមានលទ្ធភាពអាចធ្វើសេចក្ដីថ្លែងការណ៍តប ប្រសិនបើមានបំណងក្នុងការធ្វើសេចក្ដីថ្លែងការណ៍។ សូមអញ្ជើញ!

**លោក សេង ប៊ុនឃាង៖**

សូមអរគុណ លោកប្រធាន។ សូមគោរពអង្គជំនុំជម្រះ និងសូមគោរពអង្គសវនាការទាំងមូល។

ខ្ញុំសូមឆ្លើយតបទៅនឹង ទាក់ទងនឹងអាជ្ញាយុកាលទៅនឹងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦។ តំណាងអយ្យការសូមស្នើឱ្យអង្គជំនុំជម្រះសាលាដំបូង បដិសេធរាល់ការលើកឡើងទាំងឡាយណា ដែលថាអាជ្ញាយុកាលចំពោះបទល្មើសតាមក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ត្រូវបានផុតរលត់ហើយនោះ។

**ប្រធានអង្គជំនុំ៖**

ឈប់សិន។ អញ្ជើញ!

[១០:១៨:០១]

**លោក អាង ឧត្តម៖**

សូមគោរពលោកប្រធាន។ ខ្ញុំបាទសូមអនុញ្ញាតឱ្យលោក អៀង សារី ចុះទៅសម្រាក និងចូលរួមសវនាការនៅបន្ទប់ខាងក្រោម ដោយសារគាត់មានបញ្ហាឈឺចង្កេះទៀតហើយ។ ហើយខ្ញុំបាទក៏សុំផងដែរដោយសារ ដូចម្សិលមិញនៅសវនាការចុងក្រោយពេលព្រឹក លោកប្រធានសួរៗថា ប្រសិនបើខ្ញុំចង់សុំឱ្យលោក អៀង សារី ឬពេលរសៀលផង ដូច្នេះថ្ងៃនេះខ្ញុំសូមស្នើសុំទុកឱ្យហើយថា នៅថ្ងៃរសៀលនេះក៏សុំអនុញ្ញាតឱ្យលោក អៀង សារី នោះចូលរួមសវនាការនៅបន្ទប់ជាន់ក្រោមដដែល ដោយមិនចាំបាច់ឱ្យនាំខ្លួនគាត់មកបន្ទប់សវនាការនេះទេ។ សូមអរគុណ។

[១០:១៨:៥៧]

**ប្រធានអង្គជំនុំ៖**

បានស្ដាប់សំណើរបស់មេធាវីជាតិការពារក្ដីឱ្យលោក អៀង សារី ស្នើសុំឱ្យលោក អៀង សារី ដកថយទៅធ្វើចូលរួមក្នុងកិច្ចដំណើរការសវនាការពីចម្ងាយ ដោយមូលហេតុសុខភាព អង្គជំនុំជម្រះអនុញ្ញាតតាមការស្នើសុំ គឺឱ្យលោក អៀង សារី ដកខ្លួនចេញពីការចូលនៅក្នុងដំណើរការសវនាការដោយផ្ទាល់ពីបន្ទប់សវនាការការនេះ។ តែតម្រូវឱ្យលោក អៀង សារី ចូលរួមសវនាការពីចម្ងាយតាមរយៈមធ្យោបាយប្រព័ន្ធសោតទស្សន៍ ដែលបានរៀបចំទុកជាស្រេចសម្រាប់គាត់នៅបន្ទប់រង់ចាំខាងក្រោមសាលសវនាការនេះ។ ហើយគឺអនុញ្ញាតពេញមួយថ្ងៃនេះតែម្ដង។

អនុរក្សមន្ទីរឃុំឃាំងឲ្យនាំលោក អៀង សារី ទៅកាន់បន្ទប់រង់ចាំ ដើម្បីឲ្យគាត់អាចតាមដានដំណើរការសវនាការពីចម្ងាយ ហើយនិងបង្គាប់ឲ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍ សម្រាប់ជនជាប់ចោទតាមដាននូវកិច្ចដំណើរការសវនាការពីចម្ងាយ។

សូមអញ្ជើញលោកសហព្រះរាជអាជ្ញារងជាតិ!

[១០:២០:២២]

**លោក សេង ប៊ុនឃាង៖**

សូមអរគុណឯកឧត្តមលោកប្រធាន។

ខ្ញុំនឹងបន្តតទៀត តំណាងអយ្យការសន្និដ្ឋានថា អាជ្ញាយុកាលចំពោះបទល្មើសតាមច្បាប់ជាតិនេះ មិនត្រូវបានផុតរលត់នៅឡើយទេ នៅពេលដែលមានការពន្យារនៅក្នុងច្បាប់ ស្តីពីការបង្កើត អ.វ.ត.ក ព្រោះថា ការពន្យាពេលអាជ្ញាយុកាលនេះ គឺគេអាចធ្វើបាន ទោះបីជាវាហួសហើយក៏ដោយ ឲ្យតែវាឋិតនៅក្នុងលក្ខខណ្ឌដែលតម្រូវឲ្យគេអាចពន្យារពេលបាន។ ហើយលក្ខខណ្ឌនៃការពន្យារនេះមានដូចជា៖

១) មិនមានចែងអំពីអាជ្ញាយុកាលទេ នៅក្នុងសម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា រហូតដល់មានការបង្កើតច្បាប់អ៊ិនតាក់ក្នុងឆ្នាំ១៩៩២។ ២) គោលការណ៍ទូទៅនៃការព្យួរអាជ្ញាយុកាល។ ៣) ការព្យួរអាជ្ញាយុកាល ដោយសារមិនមានប្រព័ន្ធច្បាប់អាចដំណើរការបាន។ ៤) ការព្យួរអាជ្ញាយុកាល ដោយសារប្រទេសកំពុងមានសង្គ្រាម។ ៥) ការព្យួរអាជ្ញាយុកាល ដោយសារកំហុសរបស់ជនល្មើស។

[១០:២១:៣៥]

ប៉ុន្តែ មុននឹងលើកឡើងអំពីអំណះអំណាងទាំងអស់នេះ។ ខ្ញុំសូមលើកឡើងអំពីទិដ្ឋភាពទូទៅមួយចំនួន ដើម្បីឆ្លើយតបទៅនឹងការលើកឡើងរបស់មេធាវីការពារក្តី អំពីការព្យួរអាជ្ញាយុកាលចំពោះបទល្មើសតាមក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ នេះ។

ចំណុចទីមួយ ទាក់ទងនឹងប្រព័ន្ធច្បាប់របស់ប្រទេសកម្ពុជា យើងឃើញថា នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យកាន់អំណាចនោះ គឺប្រព័ន្ធតុលាការត្រូវបានវិនាសខ្ទាត់ខ្ទាយ។ យោងតាមឯកសារមួយចំនួនបានបង្ហាញថា មូលហេតុដែលប្រព័ន្ធតុលាការត្រូវរំលាយចោលបែបនេះ គឺដោយសារតែបក្សកុម្មុយនីស្តកម្ពុជា ចាត់ទុកអ្នកច្បាប់ទាំងឡាយ គឺជាគោលដៅដែលត្រូវសម្លាប់ចោល។ ទោះបីជាយើងឃើញនៅក្នុងរដ្ឋធម្មនុញ្ញនៃរបបកម្ពុជាប្រជាធិបតេយ្យ មានចែងអំពីអត្ថិភាពនៃតុលាការក៏ដោយ តាមពិតទៅ មិនមានតុលាការមួយត្រូវបានបង្កើតឡើង និងដំណើរការនោះទេ។

[១០:២២:៤៤]

ចាប់ពីឆ្នាំ១៩៧៩ ដល់ឆ្នាំ១៩៨១ នៅក្នុងរយៈកាលនេះ យើងឃើញថា ប្រព័ន្ធតុលាការបានបង្កើតឡើងដោយសាធារណរដ្ឋប្រជាមានិតកម្ពុជា គឺបានបន្តដំណើរការរហូតដល់ឆ្នាំ១៩៩២, ៩៣។ ក្នុងរយៈពេលនេះ ទាំងប្រព័ន្ធច្បាប់ស៊ីវិលបារាំង ទាំងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ មិនត្រូវបានគេយកមកអនុវត្តឡើយ គឺគេអនុវត្តក្រឹត្យច្បាប់ក្នុងឆ្នាំ១៩៨០ និងក្រឹត្យច្បាប់មួយទៀត ដែលបង្កើតឡើងនៅឆ្នាំ១៩៨២ ហើយបទល្មើសចម្បងបំផុតនៅពេលនោះ គឺគេផ្តោតទៅលើទោសក្បត់បដិវត្តន៍តែប៉ុណ្ណោះ។

អ្នកច្បាប់ដែលបម្រើការងារនៅតុលាការ ដែលបង្កើតឡើងនៅពេលនោះ គឺភាគច្រើនគឺជាអតីតគ្រូបង្រៀន និងអ្នកដទៃទៀត ដែលមិនបាន ឬក៏បានទទួលការបណ្តុះបណ្តាលផ្នែកច្បាប់តិចតួចតែប៉ុណ្ណោះ។ លើសពីនេះទៀត នៅក្នុងរយៈពេលនោះ ជនជាប់ចោទមិនអាចទទួលបានមេធាវីដែលមានសមត្ថភាពជីវ ដើម្បីការពារក្តីឲ្យគេនោះទេ។ ហើយសិទ្ធិក្នុងការប្តឹងឧទ្ធរណ៍ក៏គ្មានដែរ ពីព្រោះនៅពេលនោះ តុលាការមានតែមួយថ្នាក់ ហើយធ្វើការជំនុំជម្រះជាលើកទីមួយ និងជាលើកចុងក្រោយបង្អស់ផងដែរ។

[១០:២៤:១៤]

ចំណែកឯតុលាការកំពូលត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ១៩៨៥ ហើយបើតាមប្រភពឯកសារមួយចំនួនជាពិសេសអត្ថបទដែលមានចំណងជើងថា ប្រទេសកម្ពុជាកសាងប្រព័ន្ធច្បាប់ពីបាតដៃទទេ។ នៅក្នុងនោះបានកត់សម្គាល់ថា សិទ្ធិក្នុងការប្តឹងសាទុក្ខទៅតុលាការកំពូល គឺមិនមានទេ។ ហើយតាមសភាពជាក់ស្តែងទៀតនោះ ឃើញថា ក្រសួងយុត្តិធម៌ គឺជាអ្នកពិនិត្យមើលឡើងវិញលើសាលក្រមអំពីភាពត្រឹមត្រូវ ទាំងអង្គហេតុ និងអង្គច្បាប់។

ដូច្នេះឃើញថា តួនាទី និងសិទ្ធិអំណាចរបស់តុលាការគឺនៅមានកម្រិតនៅឡើយ ហើយរហូតមកដល់ឆ្នាំ១៩៩២ ពោលគឺបន្ទាប់ពីមានកិច្ចព្រមព្រៀងទីក្រុងប៉ារីស និងសម័យអន្តរកាល ដែលដឹកនាំដោយអ៊ុនតាក់មក ទើបកម្ពុជាចាប់ផ្តើមពង្រឹងវិស័យច្បាប់ឡើងវិញ ជាពិសេសគឺបានបង្កើតឲ្យមានបទប្បញ្ញត្តិស្តីពីប្រព័ន្ធតុលាការ ច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌ សម្រាប់អនុវត្តក្នុងសម័យអន្តរកាល ឬហៅថា ច្បាប់អ៊ុនតាក់ ដែលត្រូវបានយកអនុវត្តចាប់តាំងពីពេលនោះជាហូរហែមក។

[១០:២៥:៣៥]

នៅក្នុងច្បាប់អ៊ុនតាក់នេះ គឺមានបង្កើតតុលាការនៅតាមខេត្តក្រុង និងសាលាឧទ្ធរណ៍ ហើយ

ថែមទាំងបានពង្រីកសិទ្ធិអំណាចរបស់តុលាការកំពូលផងដែរ។ ច្បាប់នេះបានធានានូវសិទ្ធិរបស់ជនជាប់ចោទដែលត្រូវបានគេចាប់ខ្លួន ជាពិសេសទៅទៀតនោះយើងឃើញថា នៅក្នុងច្បាប់នេះ ក៏បានលើកអំពីកង្វះខាតមួយចំនួន នៅក្នុងប្រព័ន្ធច្បាប់ដែលមានស្រាប់ផងដែរ។ ចំណុចនេះ គឺបានឆ្លុះបញ្ចាំងឲ្យឃើញថា កង្វះខាតផ្នែកច្បាប់នៅប្រទេសកម្ពុជា គឺពិតជាមាន រួមទាំងការចាប់ផ្តើមកសាងប្រព័ន្ធច្បាប់ឡើងវិញផងដែរ។

នៅក្នុងឆ្នាំ១៩៩៣ រដ្ឋសភានៃប្រទេសកម្ពុជាបានអនុម័តដាក់ឲ្យប្រើច្បាប់ ស្តីពីនីតិវិធីព្រហ្មទណ្ឌ ហើយដែលច្បាប់នេះ គឺបានដាក់បញ្ចូលឡើងវិញនូវទិដ្ឋភាពនានា នៃប្រព័ន្ធច្បាប់ស៊ីវិលរបស់បារាំង ដោយមានចែងអំពីតួនាទី និងសិទ្ធិអំណាចរបស់ព្រះរាជអាជ្ញា ចៅក្រមអង្កេត និងចៅក្រមជំនុំជម្រះ ហើយច្បាប់នេះក៏បានបើកផ្លូវឲ្យជនជាប់ចោទ មានសិទ្ធិប្តឹងឧទ្ធរណ៍ទៅសាលាឧទ្ធរណ៍បាន ប្រសិនបើខ្លួនមិនពេញចិត្តនឹងសេចក្តីសម្រេចរបស់តុលាការថ្នាក់ក្រោម។

[១០:២៦:៥២]

បន្ទាប់មកទើបអាចនាំទៅដល់ការបង្កើតរដ្ឋធម្មនុញ្ញក្នុងឆ្នាំ១៩៩៣ ហើយដែលក្នុងរដ្ឋធម្មនុញ្ញនោះ ក៏បានចែងអំពីការប្តេជ្ញាចិត្ត ក្នុងការទទួលស្គាល់សមភាពចំពោះមុខច្បាប់ និងការគោរពបទដ្ឋានសិទ្ធិមនុស្សទាំងឡាយ ព្រមទាំងបានបង្កើតនូវគោលការណ៍ប្រព័ន្ធតុលាការឯករាជ្យ ហើយក៏មានការគាំទ្រជាអន្តរជាតិមួយមកលើរាជរដ្ឋាភិបាលកម្ពុជា ដែលកើតចេញពីការបោះឆ្នោតនៅឆ្នាំ១៩៩៣ ដែលនៅពេលនោះ ពួកខ្មែរក្រហមបានធ្វើពហិការមិនព្រមចូលរួមក្នុងការបោះឆ្នោតជាសកលនេះទេ។

ហើយជាបន្តបន្ទាប់មកទៀត ទើបមានការបង្កើតគ្រឹះស្ថានឧត្តមសិក្សាផ្នែកច្បាប់ បានចាប់ផ្តើមបណ្តុះបណ្តាលថ្នាក់បរិញ្ញាប័ត្រ ដែលមានក្នុងរយៈពេលបណ្តុះបណ្តាលគឺបួនទៅប្រាំឆ្នាំ។ បើយើងប្រៀបធៀបទៅនឹងការបណ្តុះបណ្តាលពីមុនៗមក គឺធ្វើឡើងត្រឹមតែកម្រិតថ្នាក់មធ្យម ហើយរយៈបណ្តុះបណ្តាលក៏មានរយៈពេលខ្លីដែរ។ លុះដល់ឆ្នាំ១៩៩៥ ទើបមានការបង្កើតឡើងនូវគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។

[១០:២៨:០៤]

អាស្រ័យដូចនេះហើយ ទើបអង្គនីតិបញ្ញត្តិអាចមានលទ្ធភាពធ្វើច្បាប់ថ្មីៗជាច្រើន រួមទាំងច្បាប់ស្តីពីការដាក់កម្ពុជាប្រជាធិបតេយ្យឲ្យនៅក្រៅច្បាប់ក្នុងឆ្នាំ១៩៩៤។ ហើយនៅឆ្នាំ១៩៩៧ រាជរដ្ឋាភិបាលបានស្នើសុំទៅអង្គការសហប្រជាជាតិ ដើម្បីបង្កើតឲ្យមានតុលាការមួយ ដែលមានកម្រិតស្តង់ដារ

តាមបទដ្ឋានអន្តរជាតិ ដើម្បីធ្វើការផ្តន្ទាទោសឧក្រិដ្ឋជន ដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។

យោងតាមការរៀបរាប់កន្លងមក ឃើញថា សមត្ថភាពតុលាការកម្ពុជានៅពេលនោះ គឺមានការខ្វះខាត ដោយសារតែការបំផ្លិចបំផ្លាញប្រព័ន្ធតុលាការទាំងស្រុង ដោយរបបកម្ពុជាប្រជាធិបតេយ្យ ដែលបញ្ហានេះត្រូវការពេលវេលាយ៉ាងច្រើន ដើម្បីបង្កើតប្រព័ន្ធតុលាការឡើងវិញ ដូចជាការបណ្តុះបណ្តាលមេធាវី ចៅក្រម ព្រះរាជអាជ្ញា ដើម្បីពង្រឹងវិស័យច្បាប់ ឲ្យមានលក្ខណៈសមស្របតាមបទដ្ឋានឡើងវិញ។

ដូច្នេះឃើញថា ចាប់ពីសម័យអន្តរកាលដែលគ្រប់គ្រងដោយអ៊ុនតាក់ ជាពិសេសគឺចាប់តាំងពីឆ្នាំ១៩៩៣ មក គឺមានការរៀបចំ និងបង្កើតឲ្យមានប្រព័ន្ធតុលាការមួយ ដែលអាចដំណើរការបានសមស្រប ហើយដែលយើងឃើញថា កាលពីកន្លងមក បញ្ហាទាំងនេះមិនទាន់មានលក្ខណៈសមស្របអាចទទួលយកបាននៅឡើយទេ។

[១០:២៩:៤២]

ចំណុចទីពីរ ទាក់ទងទៅនឹងសន្តិសុខសង្គមនៅប្រទេសកម្ពុជា បើយើងក្រឡេកទៅមើលបន្ទាប់ពីថ្ងៃរំដោះ ៧ មករា ឆ្នាំ១៩៧៩ មកឃើញថា ប្រទេសកម្ពុជានៅតែឋិតក្នុងស្ថានភាពមានសង្គ្រាមស៊ីវិល និងអស្ថិរភាពដដែល ហើយជនជាប់ចោទក៏នៅតែបន្តធ្វើជាអ្នកដឹកនាំកម្លាំងប្រឆាំងនឹងរាជរដ្ឋាភិបាលដដែល។ នៅពេលនោះកងកម្លាំងរបស់ជនជាប់ចោទ បានគ្រប់គ្រងផ្នែកខ្លះនៃទឹកដីប្រទេសកម្ពុជា ហើយបានយកទីតាំងតំបន់ភ្នំ ដែលនៅឋិតជិតព្រំដែនថៃ ធ្វើជាមូលដ្ឋានដ៏រឹងមាំ ដើម្បីប្រឆាំងនឹងរដ្ឋាភិបាល។

ហើយជាពិសេសទៀត គឺនៅពេលនោះ អង្គការសហប្រជាជាតិនៅតែបន្តទទួលស្គាល់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ថាជារដ្ឋាភិបាលស្របច្បាប់ និងមានសិទ្ធិធ្វើជាតំណាងឲ្យប្រទេសកម្ពុជានៅឯមហាសន្និបាតអង្គការសហប្រជាជាតិផងដែរ។

បញ្ហាទាំងនេះហើយ ដែលបណ្តាលឲ្យជនជាប់ចោទអាចធ្វើសកម្មភាពយ៉ាងពេញទំហឹងប្រឆាំងជាមួយរដ្ឋាភិបាល។ ហើយបើយើងពិនិត្យទៅលើតួនាទីរបស់ជនជាប់ចោទនីមួយៗវិញឃើញថា នៅពេលនោះ ពួកគេសុទ្ធតែមានតួនាទីខ្ពស់ ឧទាហរណ៍ដូចជា អៀង សារី គឺជារដ្ឋមន្ត្រីក្រសួងការបរទេសរបស់កម្ពុជាប្រជាធិបតេយ្យ និងជាតំណាងនៅអង្គការសហប្រជាជាតិ ដែលជាអ្នកស្វែងរកមូលនិធិឧបត្ថម្ភ

ចលនាតស៊ូខ្មែរក្រហម ហើយបន្តបន្ទាប់មកទៀត គាត់បានទទួលអំណាចលើការត្រួតត្រាតំបន់និងកងកម្លាំងផ្ទាល់ខ្លួនរបស់គាត់នៅប៉ៃលិន។

[១០:៣១:៣៥]

ចំណែកឯ ខៀវ សំផន គឺជាមេដឹកនាំនៃពួកប្រឆាំង និងជាអនុប្រធានទទួលបន្ទុកកិច្ចការបរទេសក្នុងជួររដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យ។ រីឯ អៀង ធីរិទ្ធ គឺជាប្រធានដឹកនាំគណៈប្រតិភូសម្រាប់កិច្ចចរចា របស់រដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យ ហើយត្រូវបានតែងតាំងជាអគ្គលេខាធិការនៃក្រសួងការបរទេសផងដែរ។ ចំពោះនួន ជា គឺជាមេដឹកនាំ និងមានអំណាចត្រួតត្រាលើតំបន់ចាប់ពីសំឡូតរហូតដល់កោះកុង ហើយក៏ជាអ្នកផ្តល់ការណែនាំដល់កងទ័ពព្រៃផងដែរ។

ដោយសារតែកត្តាទាំងអស់នេះហើយ ទើបធ្វើឲ្យក្រុមរបស់ជនជាប់ចោទ អាចគ្រប់គ្រងកម្លាំងប្រដាប់អាវុធនៅក្នុងព្រៃ ហើយនៅតែបន្តធ្វើសង្គ្រាមប្រឆាំងនឹងរដ្ឋាភិបាលជាបន្តបន្ទាប់។ ទោះបីជាមានកិច្ចព្រមព្រៀងទីក្រុងប៉ារីសខែតុលា ឆ្នាំ១៩៩១ និងបន្ទាប់ពីការបង្កើតព្រះរាជាណាចក្រកម្ពុជាទីពីរ ក្នុងឆ្នាំ១៩៩៣ ហើយក៏ដោយ ក៏កងកម្លាំងដែលគ្រប់គ្រងដោយជនជាប់ចោទ នៅតែបន្តធ្វើសង្គ្រាមជាមួយរដ្ឋាភិបាលដដែល។

ដូច្នេះឃើញថា នៅប្រទេសកម្ពុជានៅពេលនោះ គឺជាប្រទេសមួយដែលមានតំបន់ត្រួតត្រាច្រើន ហើយជនជាប់ចោទទាំងអស់ មិនឋិតនៅក្រោមការគ្រប់គ្រងរបស់រដ្ឋាភិបាលក្រុងភ្នំពេញទេ គឺឋិតនៅក្នុងតំបន់គ្រប់គ្រងដាច់ដោយឡែករបស់ខ្មែរក្រហម។ ដូច្នេះនៅពេលនោះបញ្ហាដែលសំខាន់ជាងគេបំផុតគឺធ្វើយ៉ាងណាដើម្បីឲ្យប្រទេសកម្ពុជា ទទួលបាននូវសុខសន្តិភាពដូចដែលរដ្ឋាភិបាល បានខិតខំប្រឹងប្រែងរកដំណោះស្រាយចរចា ដោយចំណាយពេលវេលាយ៉ាងយូរដើម្បីបញ្ចប់សង្គ្រាម ហើយនៅពេលនោះ ខ្មែរក្រហមបានដើរតួនាទីដ៏សំខាន់ក្នុងការចូលរួមចរចារកសន្តិភាពផងដែរ។

ឃើញថា ដំណើរការនីតិវិធីតុលាការ ដែលស្ថិតក្នុងពេលដែលប្រទេសកំពុងមានសង្គ្រាមបែបនេះ គឺមិនទំនងជាអាចដោះស្រាយទៅតាមរបៀបមួយដែលសមស្របនោះទេ។

[១០:៣៣:៥៣]

ហេតុដូច្នេះឃើញថា ដោយសារប្រទេសមិនទាន់ទទួលបានសុខសន្តិភាពផងនោះ ទើបធ្វើឲ្យប្រព័ន្ធយុត្តិធម៌ មិនទាន់មានភាពឯករាជ្យពេញលេញនោះទេ។ ដូច្នេះ ការស៊ើបអង្កេត ការចោទប្រកាន់ចំពោះឧក្រិដ្ឋកម្មនានា ដែលជនជាប់ចោទបានប្រព្រឹត្តក្នុងអំឡុងពេល នៃរបបកម្ពុជាប្រជាធិបតេយ្យ

នោះ មិនអាចផ្តើមធ្វើបាននៅឡើយទេ។ ទើបតែក្នុងឆ្នាំ១៩៩៦ ដោយសារតែការដាក់ចេញនូវយុទ្ធសាស្ត្រឈ្នះឈ្នះរបស់រាជរដ្ឋាភិបាល ទើបធ្វើឲ្យប្រទេសកម្ពុជាអាចទទួលបានសុខសន្តិភាពបន្តិចម្តងៗ ហើយជាបន្តបន្ទាប់មក ក៏មានមេដឹកនាំខ្មែរក្រហមមួយចំនួនបានធ្វើសមាហរណកម្មជាមួយរាជរដ្ឋាភិបាល។

ក៏ប៉ុន្តែទោះជាយ៉ាងនេះហើយក៏ដោយ ក៏យើងឃើញថា នៅពេលនោះ នួន ជា និង អៀង សារី នៅតែបន្តដឹកនាំកម្លាំងប្រដាប់អាវុធ ប្រឆាំងជាមួយរាជរដ្ឋាភិបាលដដែល ដោយមិនព្រមចុះចូលជាមួយរដ្ឋាភិបាលទេ រហូតដល់ខែធ្នូឆ្នាំ១៩៩៨។ បន្ទាប់ពីមានការរួបរួមកម្លាំងរបស់ខ្មែរក្រហមជាមួយរដ្ឋាភិបាលមក ទើបធ្វើឲ្យប្រទេសកម្ពុជាអាចមានសុខសន្តិភាព និងស្ថេរភាពសង្គម ហើយបន្ទាប់មកទើបមានឱកាសបង្កើតសាលាក្តីខ្មែរក្រហមនេះបាន។

ហេតុដូច្នេះឃើញថា អំពើរបស់ជនជាប់ចោទដែលបានបង្កសង្គ្រាមប្រឆាំងជាមួយរដ្ឋាភិបាលអស់រយៈពេលដ៏យូរ គឺជាមូលហេតុមួយដែលបណ្តាលឲ្យការអភិវឌ្ឍ និងការបង្កើតប្រព័ន្ធតុលាការដើម្បីអាចដំណើរការបានប្រកបដោយប្រសិទ្ធភាពនោះត្រូវបានអាក់ខាន។ ដូច្នេះ ជនជាប់ចោទត្រូវតែទទួលខុសត្រូវនូវអំពើរបស់ខ្លួនទាំងនេះ។

[១០:៣៦:០០]

**ប្រធានអង្គជំនុំ៖**

សហព្រះរាជអាជ្ញារងសម្រាកមួយនាទី ដើម្បីឲ្យផ្នែកខាងបច្ចេកទេសប្តូរ ឌីវីឌី ពីព្រោះអស់ឌីវីឌី។

សូមអញ្ជើញសហព្រះរាជអាជ្ញារងជាតិបន្ត!

**លោក សេង ប៊ុនឃាង៖**

បាទ, សូមអរគុណលោកប្រធាន។ មុននេះបន្តិចខ្ញុំបានលើកឡើងអំពីតួនាទីរបស់ជនជាប់ចោទនីមួយៗនៅក្នុងរយៈពេលសង្គ្រាមស៊ីវិលនៅប្រទេសកម្ពុជា ដោយបានលើកមានការភ័ន្តច្រឡំថានួន ជា និងអៀង សារី។ តាមពិតគឺនៅពេលនោះ គឺនួន ជា និងខៀវ សំផន នៅតែបន្តកម្លាំងប្រដាប់អាវុធប្រឆាំងជាមួយរដ្ឋាភិបាល សូមកែចំណុចនេះ។

ហើយជាបន្តទៀត ជនជាប់ចោទត្រូវតែទទួលខុសត្រូវនូវអំពើរបស់ខ្លួនទាំងនេះ ដែលបានធ្វើឲ្យមានការអាក់ខានចំពោះដំណើរការតុលាការ។ ហើយចំណុចនេះអង្គបុរេជំនុំជម្រះក៏បានធ្វើការកត់សម្គាល់ផងដែរថា “ជនជាប់ចោទមិនអាចទទួលផលប្រយោជន៍ពីការកន្លងផុតទៅនៃពេលវេលានោះទេ

ប្រសិនបើជនជាប់ចោទត្រូវបានគេរកឃើញថា មានការទទួលខុសត្រូវមួយផ្នែកចំពោះអសមត្ថភាពនៃប្រព័ន្ធតុលាការក្នុងការស៊ើបអង្កេត និងជំនុំជម្រះ”។

[១០:៣៧:៥៧]

ចំណុចទីបី ទាក់ទងទៅនឹងច្បាប់ អ.វ.ត.ក។ ច្បាប់ អ.វ.ត.ក ត្រូវបានអនុម័តឡើងដោយអង្គនីតិបញ្ញត្តិនៃព្រះរាជាណាចក្រកម្ពុជា ហើយនៅថ្ងៃទី៧ ខែសីហា ឆ្នាំ២០០១ ក្រុមប្រឹក្សាធម្មនុញ្ញបានលើកយកច្បាប់នេះមកពិនិត្យ ជាពិសេសត្រង់មាត្រា៣ ហើយបានសម្រេចថា មាត្រា៣នេះស្របនឹងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

លើសពីនេះទៀតឃើញថា អង្គនីតិបញ្ញត្តិប្រទេសកម្ពុជា គឺជាអង្គការកំពូលមានសិទ្ធិអំណាចក្នុងការធ្វើច្បាប់ទាំងឡាយដើម្បីឲ្យអាជ្ញាធរដែលមាន-- ដែលជាអ្នកប្រតិបត្តិច្បាប់ត្រូវតែអនុវត្តតាម។ ហើយអ្នកប្រតិបត្តិតាម ដែលក្នុងនោះមានអង្គតុលាការផងដែលនោះ គឺចាំបាច់ត្រូវតែគោរពច្បាប់ជាធរមានដែលអង្គនីតិបញ្ញត្តិបានអនុម័តរួចហើយនោះ។ ដោយយោងតាមមាត្រា១៣៦ នៃរដ្ឋធម្មនុញ្ញបានចែងថា “អ្នកដែលមានសិទ្ធិពិនិត្យអំពីធម្មនុញ្ញភាពនៃច្បាប់-- គឺដែលច្បាប់ដែលធ្វើឡើងដោយអង្គនីតិបញ្ញត្តិនោះ គឺមានតែក្រុមប្រឹក្សាធម្មនុញ្ញតែមួយប៉ុណ្ណោះ”។ ហើយមាត្រា១៤២ នៃរដ្ឋធម្មនុញ្ញក៏បានបញ្ជាក់យ៉ាងច្បាស់ដែលថា “បើក្នុងករណីក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យទៅឃើញថា បទប្បញ្ញត្តិ ឬមាត្រាណាមួយ មិនស្របទៅនឹងរដ្ឋធម្មនុញ្ញនោះ គឺបទប្បញ្ញត្តិនោះមិនអាចយកមកអនុវត្តបានឡើយ”។

[១០:៣៩:៤០]

ប៉ុន្តែ នៅក្នុងករណីយើងនេះឃើញថា ក្រុមប្រឹក្សាធម្មនុញ្ញនៃប្រទេសកម្ពុជាដែលជាអង្គការកំពូលនោះ បានចេញសេចក្តីសម្រេចលេខ៤០ ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០០១ និងសេចក្តីសម្រេចលេខ៤៣ ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០០១ ដោយសម្រេចថា ច្បាប់ អ.វ.ត.ក ទាំងមូល ជាពិសេសមាត្រា៣ គឺស្របនឹងរដ្ឋធម្មនុញ្ញហើយ។ លើសពីនេះទៀត សេចក្តីសម្រេចនេះ ជាសេចក្តីសម្រេចស្ថាពរ ហើយបិទផ្លូវតវ៉ាផងដែរ។ ហើយចំណុចនេះ អង្គបុរេជំនុំជម្រះក៏បានសម្រេចដែរថា “អ.វ.ត.ក គឺជាស្ថាប័នមួយដាច់ដោយឡែក ហើយអង្គជំនុំជម្រះទាំងឡាយរបស់ អ.វ.ត.ក មិនមានសិទ្ធិពិនិត្យសេចក្តីសម្រេចទាំងឡាយរបស់តុលាការ ក្រៅពី អ.វ.ត.ក បានឡើយ”។

ដូច្នេះការប្រកាសរបស់ក្រុមប្រឹក្សាធម្មនុញ្ញថា មាត្រា៣ថ្មី និងច្បាប់ស្តីពីការបង្កើតឲ្យមាន អ.វ.ត.ក ស្របតាមរដ្ឋធម្មនុញ្ញ គឺជាការសម្រេចមួយច្បាស់លាស់ស្ថាពរ និងបានភ្ជាប់កាតព្វកិច្ចត្រូវតែ

គោរពផងដែរ ហើយក៏មិនអាចត្រូវពិនិត្យឡើងវិញដោយ អ.វ.ត.ក បានដែរ ពីព្រោះចៅក្រមព្រះរាជអាជ្ញាគ្មានសិទ្ធិបកស្រាយច្បាប់ដែលរដ្ឋសភាបានអនុម័តហើយនោះទេ។

[១០:៤១:១០]

ម្យ៉ាងទៀតសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ គឺមានភាពស្របគ្នានៃច្បាប់ អ.វ.ត.ក ជាមួយនឹងរដ្ឋធម្មនុញ្ញ ហើយនិងកាតព្វកិច្ចជាអន្តរជាតិរបស់កម្ពុជាផងដែរ។ ដូច្នេះក្នុងនាមជាអ្នកអនុវត្តច្បាប់ត្រូវធ្វើយ៉ាងណា ត្រូវគោរពកាតព្វកិច្ចរបស់ខ្លួន មានន័យថា "អ្នកអនុវត្តច្បាប់ គឺជាអ្នកទទួលខុសត្រូវក្នុងការប្រតិបត្តិតាមច្បាប់ដែលនៅជាធរមាន"។ ដូចដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញត្រង់មាត្រា៥១ថ្មីថា "អំណាចបែងចែកដាច់ពីគ្នារវាងអំណាចនីតិបញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ"។ ហើយក្នុងរដ្ឋធម្មនុញ្ញនេះ ក៏បានបញ្ជាក់ផងដែរថា "រដ្ឋសភា និងព្រឹទ្ធសភា គឺជាអង្គការដែលមានអំណាចនីតិបញ្ញត្តិ" មានន័យថាជា "អំណាចធ្វើច្បាប់"។ ហើយក្នុងមាត្រា១២៩ នៃរដ្ឋធម្មនុញ្ញហ្នឹងក៏បានចែងយ៉ាងច្បាស់ដែរថា "មានតែចៅក្រមទេ ដែលមានសិទ្ធិជម្រះក្ដី។ ចៅក្រមត្រូវបំពេញភារកិច្ចនេះដោយគោរពយ៉ាងម៉ឺងម៉ាត់ និងឲ្យអស់ពីដួងចិត្តៗ និងសម្បជញ្ញៈរបស់ខ្លួន"។

[១០:៤២:៣៥]

អ៊ីចឹងមានន័យថា បទប្បញ្ញត្តិទាំងឡាយណាដែលបានចូលជាធរមានហើយនោះ គឺអ្នកដែលត្រូវអនុវត្តត្រូវតែគោរពឲ្យអស់ពីដួងចិត្តរបស់ខ្លួន មិនអាចថាមិនគោរពបានទេ។

ជាសរុបទៅឃើញថា ច្បាប់ស្ដីបង្កើត អ.វ.ត.ក ជាពិសេសមាត្រា៣ ដែលអង្គនីតិបញ្ញត្តិនៃព្រះរាជាណាចក្រកម្ពុជាបានធ្វើហើយ ហើយដែលក្រុមប្រឹក្សាធម្មនុញ្ញបានពិនិត្យ និងសម្រេចថា ស្របតាមរដ្ឋធម្មនុញ្ញហើយនោះ គឺអាចយកមកអនុវត្តបាននៅចំពោះមុខ អ.វ.ត.ក យើងនេះ។

បាទ, ហើយជាបន្តទៀត សហការីរបស់ខ្ញុំ គឺលោក វ៉ាំងសង់ នឹងជម្រាបជូនលោក លោកស្រីអំពីអំណះអំណាងបន្តទៀត។ បាទ សូមអរគុណ។

[១០:៤៣:២៦]

**ប្រធានអង្គជំនុំ៖**

សូមអរគុណសហព្រះរាជអាជ្ញាជាតិដែលបានធ្វើការបទបង្ហាញ។ ឥឡូវនេះពេលវេលាសមល្មមនឹងឈប់សម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកម្ភៃនាទី ដែលចាប់ពីពេលនេះទៅរហូតដល់ម៉ោងដប់មួយ ហើយនិងប្រាំនាទី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការរបស់យើង។

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង១០:៥៤នាទី ដល់ម៉ោង ១១:០៧នាទី)*

[១១:០៧:៥៣]

**ប្រធានអង្គជំនុំ៖**

សូមអស់លោក លោកស្រីអង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ជាកិច្ចបន្តនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញារងអន្តរជាតិ ដើម្បីឡើងធ្វើសេចក្តីការណ៍តប។

សូមអញ្ជើញ!

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្ទ្ឋាងឈ៉ះ៖**

សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រមជាទីគោរព។ ខ្ញុំគ្រាន់តែចង់ប្រាប់ថា ខ្ញុំនឹងប្រើប្រាស់ពេលវេលាដែលបានផ្តល់ជូននេះគឺប្រហែលជា៣៥ ឬក៏៣៦នាទី ដើម្បីធ្វើសេចក្តីថ្លែង-ការណ៍។

[១១:០៨:៤៥]

ចាប់ពីពេលមានសេចក្តីសម្រេចលេខ E187 ចុះថ្ងៃទី២៦ កក្កដា ឆ្នាំ២០១០ នៅក្នុងសំណុំរឿង ០០១ គឺបញ្ហាដដែលនេះ គឺថាបានមានការផ្លាស់ប្តូរ ការស្រាវជ្រាវទៅលើយុត្តិធម៌ក្នុងអំឡុងពេល៧៩ ដល់៩៣ ហើយបានបន្ត ហើយនិងបានធ្វើឡើងលម្អិត ភាគីបានផ្លាស់ប្តូរទឡ្ហីករណ៍ថ្មីៗ។ ម្យ៉ាងវិញទៀត អង្គបុរេជំនុំជម្រះបានសម្រេចជាឯកច្ឆន្ទនៅថ្ងៃទី១១ មេសា នៅសេចក្តីសម្រេចមួយដែលគោរពទៅតាមគោលជំហររបស់ចៅក្រមជាតិបីនាក់នៃអង្គជំនុំជម្រះនេះ កាលពីមួយឆ្នាំមុន។

ធាតុផ្សំសំខាន់មួយទៀតបញ្ជាក់ថា អង្គជំនុំជម្រះគឺត្រូវក្រឡេកមើលជាថ្មីទៅលើបញ្ហានេះ គឺធាតុផ្សំនៅពេលដែលអង្គជំនុំជម្រះពិនិត្យពិចារណា សេចក្តីសម្រេចថ្ងៃទី២៦ កក្កដា ២០១០ ត្រូវបានធ្វើឡើងនៅថ្ងៃដែល កាំង ហ្កេកអ៊ាវ ហៅ ឌុច ត្រូវបានផ្តន្ទាទោស ហើយចៅក្រមអន្តរជាតិនៃអង្គជំនុំជម្រះក៏បានសរសេរនៅក្នុងយោបល់ដោយឡែកនៅកថាខណ្ឌ៥៥។ ហើយខ្ញុំសូមស្ងូត្រនូវកថាខណ្ឌនេះ "ដោយសារតែមានភាពត្រួតគ្នារវាងធាតុផ្សំនៃបទឧក្រិដ្ឋកម្មជាតិ និងបទឧក្រិដ្ឋកម្មអន្តរជាតិ ការរកឃើញនេះគឺមិនមានផលប៉ះពាល់ទៅដល់ការវាយតម្លៃរបស់អង្គជំនុំជម្រះ ចំពោះការទទួលខុសត្រូវព្រហ្ម-

ទណ្ឌទាំងស្រុងរបស់ជនជាប់ចោទ ឬក៏ការផ្តន្ទាទោសជាចុងក្រោយនោះទេ”។ សូមបញ្ចប់ការដកស្រង់។

[១១:១០:១៤]

ខ្ញុំសូមនិយាយជាបន្ថែម ដើម្បីបញ្ជាក់ជូនទៀតថា គឺថាឃ្លានេះហើយដែលបានធ្វើឲ្យសហព្រះរាជអាជ្ញាធ្វើមិនបានធ្វើបណ្តឹងឧទ្ធរណ៍ទៅលើបញ្ហានេះពាក់ព័ន្ធទៅនឹងបញ្ហាយុត្តាធិការទៅលើឧក្រិដ្ឋកម្មជាតិ ដោយសារតែចំណុចសំខាន់របស់យើង សម្រាប់យើងគឺការធ្វើបណ្តឹងឧទ្ធរណ៍ទៅ លើសាលក្រមនិយាយអំពីការកំណត់ទោស។ គឺយើងមិនមែនយល់ព្រមទៅលើសេចក្តីជំនុំជម្រះ ឬក៏ការមិនធ្វើសេចក្តីសម្រេចរបស់អង្គជំនុំជម្រះទៅលើបញ្ហាឧក្រិដ្ឋកម្មជាតិនោះទេ។

ដូច្នេះស្ថានភាព ហើយនិងពេលវេលាមានភាពខុសគ្នានៅទីនេះ នៅក្នុងឯកសារE51/7 ចុះថ្ងៃទី៥ មេសា ២០១០ គឺបានបញ្ជាក់នូវឆន្ទៈក្នុងការវិនិច្ឆ័យទៅលើអញ្ញត្រកម្មដោយមិនបង្អង់ពេលវេលា គឺមិនពេលទៅក្នុងពេលជាមួយគ្នានឹងសវនាការលើអង្គសេចក្តីនោះទេ។ ទស្សនវិស័យគឺវាមិនដូចគ្នាទេ ហើយបញ្ហាប្រឈមកាន់តែមានសារៈសំខាន់ទៅទៀតនៅថ្ងៃនេះ។

[១១:១១:១០]

អង្គជំនុំជម្រះគឺត្រូវតែសម្រេច ដោយមិនបានស្តាប់ទៅលើធាតុផ្សំនៃភស្តុតាង នៃសំណុំរឿង ហើយដោយមិនដឹងថាតើធាតុផ្សំជាក់លាក់នៃឧក្រិដ្ឋកម្មអន្តរជាតិគឺថាត្រូវបានរកឃើញ ឬអត់នោះទេ។ ជាក់ស្តែងធាតុផ្សំនៃឧក្រិដ្ឋកម្មជាតិ គឺមានន័យថាមនុស្សឃាត ទារុណកម្ម និងការធ្វើទុក្ខបុកម្នេញទៅលើសាសនា គឺមិនត្រូវបានច្រឡំគ្នាជាមួយនឹងឧក្រិដ្ឋកម្មអន្តរជាតិ ទោះបីជាក្នុងទិដ្ឋភាពជាច្រើនវាមានលក្ខណៈប្រហាក់ប្រហែលគ្នាក៏ដោយ។

[១១:១១:៣៩]

យើងខ្ញុំគិតថា អង្គហេតុនិងអង្គច្បាប់ដែលមានបង្ហាញនៅក្នុងសារណារបស់យើង ហើយបច្ចុប្បន្ននេះ គឺថាត្រូវបានលើកឡើងយ៉ាងគ្រប់គ្រាន់ ហើយនិងមានភាពពាក់ព័ន្ធគ្នា ដើម្បីបង្ហាញនៅថា សេចក្តីសម្រេចពាក់ព័ន្ធទៅអវត្តមាននៃអាជ្ញាយុកាលនៃឧក្រិដ្ឋកម្មជាតិនៅចន្លោះឆ្នាំ៩២ និង៩៣។

យើងសូមបញ្ជាក់ថា រយៈពេលនៃអាជ្ញាយុកាលនេះ គឺថាមិនបានចាប់ផ្តើមគិតនោះទេនៅមុនរយៈកាលនេះ ហើយនៅពេលដែលចាប់ផ្តើមគិតនោះ គឺថាយើងត្រូវពន្យារពេល២០ឆ្នាំ មុននឹងការផុតកំណត់គឺដោយប្រការបីនៃច្បាប់ស្តីពី អ.វ.ត.ក ឆ្នាំ២០០១ ហើយនិង១០ឆ្នាំបន្ថែម ដោយមាត្រា៣ថ្មីនៃច្បាប់ អ.វ.ត.ក ឆ្នាំ២០០៤ ដែលត្រូវបានធ្វើវិសោធនកម្ម។

[១១:១២:២៨]

ពាក់ព័ន្ធទៅនឹងសមត្ថកម្មដែលថា ថិរវេលានៃអាជ្ញាយុកាលបានផុតកំណត់មុនការអនុម័តច្បាប់ឆ្នាំ២០០១នេះ។ ខ្ញុំសូមឲ្យអង្គចៅក្រមទាំងមូលយោងទៅលើសារណារបស់យើង ដែលយើងបានផ្ញើជូនរួចមកហើយនោះ។ មុននឹងគិតទៅលើបញ្ហាសំខាន់ ខ្ញុំចង់បង្ហាញបញ្ហាអង្គច្បាប់ពីរ ដែលខាងមេធាវីការពារក្ដីបានបង្ហាញអម្បាញមិញនេះ គឺមាត្រា៣ ឬក៏មាត្រា៣ថ្មីនោះ មិនបានរំលោភទៅលើគោលការណ៍នីត្យានុកូលភាពនោះទេ។ ហើយទីពីរ មាត្រា៣ថ្មី នេះគឺក៏មិនបានរំលោភទៅលើគោលការណ៍នៃសមភាពនៅចំពោះមុខច្បាប់នោះដែរ។

[១១:១៣:០៧]

ពាក់ព័ន្ធទៅនឹងគោលការណ៍នៃអប្រតិសកម្មនៃ ឬក៏នីត្យានុកូលភាពនោះ គឺថាមានភាពច្បាស់លាស់ណាស់ ដ៏រាបណាអាជ្ញាយុកាលមិនទាន់ផុតរលត់នោះទេ គឺអាជ្ញាយុកាលនេះ គឺស្ថិតនៅក្រោមច្បាប់នេះជាបន្តបន្ទាប់ដែលបានកែប្រែថិរវេលា គឺមានន័យថាថិរវេលាអាជ្ញាយុកាល១០ឆ្នាំមិនទាន់ផុតនោះទេ គឺមានន័យថា ការបន្តថិរវេលាដោយមាត្រា៣ នៃច្បាប់ស្ដីពី អ.វ.ត.ក ឆ្នាំ២០០១ និងមាត្រា៣ថ្មី នៃឆ្នាំ២០០៤ គឺថាមិនអាចរំលោភទៅលើគោលការណ៍នៃអប្រតិសកម្មបានទេ។

[១១:១៣:៥៥]

ជាក់ស្ដែងផ្ទុយទៅនឹងអ្វីដែលខាងមេធាវីការពារក្ដីបានលើកឡើង គឺការពន្យារពេលនេះគឺថាមិនមានឥទ្ធពលអ្វីនៅក្នុងការធ្វើឲ្យទោសកាន់តែមានភាពធ្ងន់ធ្ងរនោះទេ។ ហើយគឺនៅពេលដែលឧក្រិដ្ឋកម្មនេះត្រូវបានប្រព្រឹត្ត ឬក៏កែប្រែនៅនិយមន័យនៃឧក្រិដ្ឋកម្មនេះ។

ដូច្នេះ មាត្រា៧ នៃអនុសញ្ញាសិទ្ធិមនុស្សអឺរ៉ុប និងមាត្រា១៥ នៃកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនេះ គឺថាមិនត្រូវអនុវត្តនោះទេ។ អ្វីដែលសំខាន់នោះគឺថា ឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ទៅលើជនជាប់ចោទនៅចំពោះមុខ អ.វ.ត.ក គឺថាមានលក្ខណៈដូចគ្នាទៅនឹងអ្វីដែលត្រូវបានផ្ដន្ទាទោសនៅចន្លោះឆ្នាំ៧៥ និង៧៩ ហើយនិងច្បាប់ ហើយនិងសិទ្ធិ និងទោសដែលត្រូវមានសម្រាប់ជនជាប់ចោទ ដែលអាចទស្សន៍ទាយបាននៅពេលនោះ។ គឺថាឧក្រិដ្ឋកម្មនោះមិនត្រឹមតែមាននៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ៥៦ នោះទេ ប៉ុន្តែក៏វាមានជាប់ពាក់ព័ន្ធនៅនឹងឧក្រិដ្ឋ ជនឧក្រិដ្ឋ យោងទៅតាមគោលការណ៍ទូទៅនៃសិទ្ធិដែលទទួលស្គាល់ដោយប្រជាជាតិទាំងមូលនៅលើពិភពលោក។

[១១:១៤:៥៧]

ចៅក្រមអន្តរជាតិនៃអង្គជំនុំជម្រះបានបញ្ជាក់ថា ចិរវេលានៃអាជ្ញាយុកាលអាចត្រូវបានពន្យារពេលបានដោយច្បាប់ជាក់លាក់មួយ ហើយគឺវាមានសមត្ថភាពជាមួយនឹងបទដ្ឋានអន្តរជាតិទាក់ទងទៅនឹងការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌ ដែលអនុវត្តនៅចំពោះមុខ អ.វ.ត.ក ដែលមានមាត្រា១៥ នៃកតិកាសញ្ញាអន្តរជាតិ គឺកថាខណ្ឌ៤៣ និង៤៧ នៃសេចក្តីសម្រេចរបស់អង្គជំនុំជម្រះថ្ងៃទី២ កក្កដា ២០១០។

ម្យ៉ាងវិញទៀត អាជ្ញាយុកាលគឺមិនប៉ះពាល់ទៅដល់និយមន័យនៃឧក្រិដ្ឋកម្មផ្ទាល់ ឬក៏ទោសនោះទេ គឺវាស្ថិតនៅក្នុងលក្ខខណ្ឌនីតិវិធីដើម្បីអនុវត្តនូវការចោទប្រកាន់។ នេះគឺជាវិធាននីតិវិធី ហើយមិនមែនជាប្រធាននៃគតិច្បាប់នោះទេ។

[១១:១៥:៣៨]

គោលការណ៍សមភាពនៅចំពោះមុខច្បាប់៖ ការពន្យារពេលអាជ្ញាយុកាលក៏មិនបង្កើតនូវវិសមភាពនៅចំពោះមុខច្បាប់យោងតាមមាត្រា២៦ នៃកតិកាអន្តរជាតិនោះដែរ ពីព្រោះថាឥទ្ធពលនៃការពន្យារពេលនោះ គឺកើតចេញមកពីការអនុវត្តនៃច្បាប់ព្រហ្មទណ្ឌតែមួយ។ គឺមានន័យថា ការអនុម័តច្បាប់ស្តីពី អ.វ.ត.ក និងការពន្យារចិរវេលានៃអាជ្ញាយុកាលគឺមិនប៉ះពាល់ទៅដល់សមភាពរបស់ជនជាប់ចោទនៅចំពោះមុខច្បាប់ ដោយសារតែការចោទប្រកាន់គឺមិនមែនធ្វើឡើងតាមបែបទំនើងចិត្តហើយ និងផ្អែកទៅលើលក្ខណៈវិនិច្ឆ័យសមហេតុផលនិងសត្យានុម័ត ហើយការពន្យារចិរវេលាគឺថា អនុវត្តចំពោះជនទាំងឡាយណាដែលត្រូវបានចោទប្រកាន់ចំពោះឧក្រិដ្ឋកម្មនៅក្នុងក្របខ័ណ្ឌដែលកំណត់ដោយច្បាប់នោះ។

[១១:១៦:២៦]

ហើយចាប់ពីពេលដែលជនណាមួយដែលបំពេញតាមលក្ខណៈវិនិច្ឆ័យនៃយុត្តាធិការបុគ្គលពេលវេលា និងដែនដីដែលបង្កើតឡើងដោយច្បាប់ អ.វ.ត.ក នោះ គឺថាការចោទប្រកាន់អាចត្រូវបានធ្វើឡើងយ៉ាងជាក់ស្តែងចំពោះជនសង្ស័យដែលត្រូវបានកំណត់ដោយសហព្រះរាជអាជ្ញា។ គឺបញ្ហានេះ គឺមិនមានន័យថាជាការ មិនប្រព្រឹត្តដោយមិនយុត្តិធម៌ដូចដែលខាងសហមេធាវីការពារក្តីបានលើកឡើងនោះទេ។

ដូច្នេះ យើងមានគោលការណ៍ជាមូលដ្ឋានដែលផ្អែកទៅលើច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ដែលនិយាយថាជនទទួលខុសត្រូវនៃអំពើរំលោភបំពានធ្ងន់ធ្ងរនៃសិទ្ធិមនុស្ស និងសិទ្ធិសង្គ្រាមត្រូវតែឆ្លើយតប

ទៅលើអំពើរបស់ខ្លួននៅចំពោះមុខតុលាការ។ ហើយបើតាមលក្ខណៈវិនិច្ឆ័យនៃយុត្តាធិការបុគ្គល ហើយ និងបន្ទាប់ពីការអនុវត្តនូវកាលានុប្បវត្តិភាពនៃការចោទប្រកាន់ដោយសហព្រះរាជអាជ្ញា បុគ្គលទាំងអស់នោះត្រូវតែទទួលខុស-- អ្នកទទួលខុសត្រូវទាំងអស់នោះគឺមានតែចំនួនតិចតួចបំផុត។

[១១:១៧:២៨]

អង្គជំនុំជម្រះទាំងមូល យើងចង់បន្តដោយឆ្លើយតបទៅនឹងអ្វីដែលខាងមេធាវីការពារក្ដីបាននិយាយនៅក្នុងចម្លើយតបរួមនៅថ្ងៃទី១៧ មិថុនា នៅកថាខណ្ឌ១០ ហើយវាគឺជាអំណះអំណាងសំខាន់របស់យើងនៅថ្ងៃនេះ។

មេធាវីការពារក្ដីបាននិយាយថា ក្រមព្រហ្មទណ្ឌឆ្នាំ៥៦ គឺនៅតែមានជាធរមាននៅក្នុងអំឡុងឆ្នាំ៧៩ ដល់ឆ្នាំ៨១ ហើយទោះបីជាក្រមនេះមិនត្រូវបានអនុវត្ត ឬក៏មិនបានអនុវត្តក៏ដោយ ពីព្រោះដោយសារតែក្រមនេះមិនត្រូវបានធ្វើនិរាករណ៍នោះទេ។ ហើយខាងមេធាវីការពាក្ដីក៏បានលើកឡើងថា ក្រឹត្យច្បាប់ថ្ងៃទី១៥មេសា ៨០ នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា គឺបាននិយាយអំពីទោសដែលទាក់ទងទៅនឹងឧក្រិដ្ឋកម្មក្បត់នឹងបដិវត្តន៍ ហើយនិងឧក្រិដ្ឋកម្មធម្មតាដូចជាមាន មនុស្សឃាត ការរំលោភផ្លូវការបង្ករបួសស្នាម ហើយនិងឧក្រិដ្ឋកម្មប្រឆាំងនឹងទ្រព្យសម្បត្តិ។

[១១:១៨:១៩]

ហើយនៅពេលដែលសហមេធាវីការពារក្ដីពន្យល់ថាតើក្រឹត្យច្បាប់នេះអាចអនុវត្តស្របជាមួយនឹងក្រមព្រហ្មទណ្ឌចាស់ឆ្នាំ៥៦ ក្នុងរយៈពេលនេះដែរឬទេ? ដូច្នេះ តាមន័យរបស់យើងនេះគឺមិនមែនជាការបកស្រាយសមហេតុផលនោះទេ។

យើងសូមឲ្យអង្គជំនុំជម្រះវិភាគយ៉ាងប្រុងប្រយ័ត្នទៅលើក្រឹត្យច្បាប់នៅមាត្រា១២ គឺឯកសារ D288/6.9/9.4 ហើយនិងអង្គជំនុំជម្រះនឹងកត់សម្គាល់ទៀត ឃើញថា នឹងគ្មានការសង្ស័យទៅលើចេតនារបស់អ្នកតាក់តែងច្បាប់ឡើយ។ វាគឺជាច្បាប់បដិវត្តន៍ដែលធ្វើឡើងក្នុងភាពប្រញាប់ប្រញាល់ ហើយវាជាមិនមែនជាច្បាប់ពេញលេញនោះទេ ហើយវាមិនបានគ្របដណ្ដប់ទៅលើប្រភេទនៃបទល្មើស ហើយនិងគ្រប់ទិដ្ឋភាពនៃច្បាប់ព្រហ្មទណ្ឌនេះទេ។ ឧក្រិដ្ឋកម្មភាគច្រើនត្រូវបានបញ្ចូលទៅក្នុងឧក្រិដ្ឋកម្មក្បត់ទៅនឹងបដិវត្តន៍ ហើយមិនមានការយោងទៅលើក្រមព្រហ្មទណ្ឌឆ្នាំ៥៦ ហើយផ្ទុយទៅវិញវាបង្ហាញថា ក្រុមប្រឹក្សាបដិវត្តន៍ប្រជាជនដែលជាអ្នកតាក់តែងសិទ្ធិ អ្នកតាក់តែងក្រិត្យនោះគឺមិនបានដឹង ឬក៏បានចាត់ទុកថាវាមិនមានជាធរមានទៀតនោះទេ។

ហើយយើងសូមកត់សម្គាល់ផងដែរថា ក្រឹត្យច្បាប់នោះគឺមានអានុភាពប្រតិសកម្ម ហើយតាមមាត្រា១២ គឺថាវាអនុវត្តចំពោះគ្រប់ឧក្រិដ្ឋកម្មទាំងអស់ គឺដែលត្រូវបានប្រព្រឹត្តចាប់ពីថ្ងៃទី៧ មករា ឆ្នាំ៧៩។ ដូច្នេះគ្មានការយោងទៅលើឧក្រិដ្ឋកម្មផ្សេងទៀតដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ៥៦ នោះឡើយ។ ហើយចាប់ពីពេលនោះមកប្រសិនបើក្រមព្រហ្មទណ្ឌឆ្នាំ៥៦ មិនត្រូវបានធ្វើនិរាករណ៍ជាផ្លូវការនោះយើងអាច បញ្ជាក់ដោយគ្មានការភ័យខ្លាចថា វាអាចត្រូវបានផ្អាកក្រោយថ្ងៃទី៧ មករា ៧៩។ ហើយបរិបទនេះ ក៏បានគាំទ្រចំពោះការបកស្រាយនោះដែរ គឺមានការផ្លាស់ប្តូរអំណាចដែលយើងហៅថាបដិវត្តន៍ គឺមានការផ្លាស់ប្តូររដ្ឋធម្មនុញ្ញ ហើយនិងការអនុម័តនូវច្បាប់មួយចំនួនដែលកាត់ផ្តាច់ពីរបបខ្មែរក្រហម ហើយនិងជាមួយនឹងរបបចាស់។

[១១:២០:០៣]

ទោះបីជាយើងមើលឃើញថាច្បាប់ ហើយនិងក្រឹត្យទាំងអស់នេះគឺថា មិនមានលក្ខណៈពេញលេញ ឬក៏មានចន្លោះប្រហោងក៏ដោយ។ ខ្ញុំសូមឲ្យយើងទៅមើលមាត្រា៩២ នៃរដ្ឋធម្មនុញ្ញខែមិថុនា ឆ្នាំ១៩៨១ ដែលបានបញ្ជាក់ថាក្រឹត្យច្បាប់ ហើយនិងសេចក្តីសម្រេចរបស់ក្រុម ប្រឹក្សាបដិវត្តន៍ប្រជាជន គឺមានអនុភាពជាច្បាប់ ហើយនឹងនៅតែជាធរមានរហូតទៅដល់ច្បាប់មកជំនួសក្រឹត្យច្បាប់ទាំងអស់នេះ ហើយនិងសេចក្តីសម្រេចទាំងអស់នេះ។ គឺមានន័យថា ទៅលើច្បាប់នៃរបបចាស់ៗ។ ផលវិបាកនៃការកត់សម្គាល់ឃើញថាក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ត្រូវផ្អាកឬក៏ធ្វើនិរាករណ៍នៅក្នុងអំឡុងឆ្នាំ៧៩ ដល់ឆ្នាំ៨១ គឺមានសារៈសំខាន់ណាស់។

[១១:២១:១៦]

ទាំងនៅក្នុងក្រឹត្យច្បាប់ឆ្នាំ៨០ ដែលខ្ញុំទើបតែលើកឡើងអម្បាញ់មិញនេះ ឬក៏នៅក្នុងក្រឹត្យឆ្នាំ ៨២ ស្តីពីការរៀបចំសាលាជម្រះក្តីនៅប្រទេសកម្ពុជានោះ គឺឯកសារ E51/7/3.1.1 ជាភាសាខ្មែរ ហើយទាំងក្រឹត្យពាក់ព័ន្ធទៅនឹងបង្កើតតុលាការកំពូលប្រជាជននៅឆ្នាំ១៩៨៥ និងឆ្នាំ១៩៨៧ នោះគឺថា យើងមិនមានរកឃើញនូវបទប្បញ្ញត្តិនីតិវិធីពាក់ព័ន្ធទៅនឹងអាជ្ញាយុកាលណាមួយឡើយ។

ដូច្នេះ បើតាមយើងដឹងគ្មានអាជ្ញាយុកាលដែលត្រូវបានអនុវត្តនៅចន្លោះថ្ងៃ៧ មករា ៧៩ ហើយ និងថ្ងៃដែលបទប្បញ្ញត្តិចុះថ្ងៃទី១០ កញ្ញា ៨២ ចូលជាធរមានពាក់ព័ន្ធទៅនឹងប្រព័ន្ធតុលាការ សិទ្ធិព្រហ្មទណ្ឌ ហើយនិងនីតិវិធីព្រហ្មទណ្ឌដែលអនុវត្តនៅប្រទេសកម្ពុជាក្នុងអន្តរកាលដែលបានរៀបចំឡើងដោយមានជំនួយពីអាជ្ញាធរបណ្តោះអាសន្ន អ.ប.ស នៅកម្ពុជាដែលយើងហៅជាភាសាអង់គ្លេសថា អ៊ុនតាក់។

មាត្រា៣០ នៃបទប្បញ្ញត្តិនេះនៃក្រមរបស់អ៊ុនតាក់ បានបង្កើត ឬក៏បង្កើតឡើងវិញនៅចិរវេលានៃអាជ្ញាយុកាលសម្រាប់បទមជ្ឈិម ហើយនិងបទឧក្រិដ្ឋដែលមានរយៈពេលពីបីនិងដប់ឆ្នាំ។ នេះហើយគឺជាការពិត គ្មានអ្វីដែលអាចបញ្ជាក់ថា អាជ្ញាធរដែលទទួលបន្ទុកខាងការចោទប្រកាន់ ហើយនិងតុលាការបដិវត្តន៍ក្នុងអំឡុងសម័យសាធារណរដ្ឋប្រជាមានិតកម្ពុជាបានធ្វើការស៊ើបអង្កេត ឬក៏ធ្វើការចោទប្រកាន់ក្នុងរយៈពេល១០ឆ្នាំ ក្រោយពីការបញ្ចប់របបខ្មែរក្រហមនោះឡើយ។ ពីព្រោះថាចិរវេលាអាជ្ញាយុកាល១០ឆ្នាំ គឺមិនមានកើតឡើងនោះទេ។

[១១:២៣:០០]

ដូច្នេះ រយៈពេល១០ឆ្នាំ នៃអាជ្ញាយុកាលនោះគឺថា មិនអាចផុតកំណត់នៅថ្ងៃទី៦ មករា ១៩៨៩ បានឡើយ គឺមិនដូចអ្វីដែលខាងមេធាវីការពារក្តីបានអះអាងនោះទេ។ ហើយអង្គជំនុំជម្រះក៏មិនអាចតម្រូវដោយអប្រតិសកម្មនៅចិរវេលាអាជ្ញាយុកាលទៅលើអាជ្ញាធរតុលាការ ដែលបានកាន់អំណាចនៅចន្លោះឆ្នាំ៧៩ និងខែកញ្ញាឆ្នាំ៩២ នោះដែរ។ ហើយនៅខណៈដែលក្រឹត្យហើយនិងច្បាប់ដែលអនុវត្តជាធរមាននោះ គឺមិនមានអាជ្ញាយុកាលនោះឡើយ។ ដូច្នេះ កាលបរិច្ឆេទជាដំបូងសម្រាប់រាប់អាជ្ញាយុកាលនោះ គឺ១០ឆ្នាំនោះ គឺថាគឺចាប់ពីពេលដែលចូលជាធរមាននៅមាត្រា៣០ នៃក្រមរបស់ អ៊ុនតាក់នៅខែកញ្ញា ឆ្នាំ៩២ គឺថាចូលជាធរមានពីរខែក្រោយពីការអនុម័ត គឺថានៅខែវិច្ឆិកា ឆ្នាំ៩២។

ដោយសារតែចិរវេលានៃអាជ្ញាយុកាលមិនទាន់បានផុតកំណត់នោះនៅពេល ដែលអនុម័តច្បាប់ស្តីពី អ.វ.ត.ក នៅឆ្នាំ២០០១ ដែលបានកំណត់អាជ្ញាយុកាលនោះរហូតទៅដល់៣០ឆ្នាំ សម្រាប់ឧក្រិដ្ឋកម្មច្បាប់ជាតិ ហើយមាត្រា៣ នៃច្បាប់នេះគឺថាមិនបានរំលោភទៅលើគោលការណ៍នីត្យានុកូលភាព ហើយក៏មិនបានធ្វើជាឧបសគ្គទៅដល់ការវិនិច្ឆ័យជនជាប់ចោទសម្រាប់ឧក្រិដ្ឋកម្មជាតិដែលខ្លួនត្រូវបានចោទប្រកាន់នោះឡើយ។

[១១:២៤:២៥]

នៅក្នុងផ្នែកទីពីរ ហើយជាបញ្ហាបន្ទាប់បន្សំនោះ ប្រសិនបើអង្គជំនុំជម្រះមិនពេញចិត្តក្នុងការនិយាយថា គ្មានកាលបរិច្ឆេទ គ្មានកាលអាជ្ញាយុកាលណាមួយដែលកើតមាននៅចន្លោះឆ្នាំ៧៩ និងនៅចុងឆ្នាំ៩២នោះ យើងសូមឲ្យអង្គជំនុំជម្រះផ្អែកទៅលើការផ្សំគ្នានៃគោលការណ៍ច្បាប់ ហើយនិងកាលៈទេសៈទាំងអស់ ដែលអាចធ្វើឲ្យអង្គជំនុំជម្រះសន្និដ្ឋានជាលក្ខណៈសត្យានុម័តថា ចិរវេលានៃអាជ្ញាយុកាល គឺមិនបានគិតចាប់ពីនោះទេ ហើយវាគិតចាប់ពីឆ្នាំ៩៣ ដោយសារតែវាមានមូលហេតុបី គឺថា

ដូចដែលសហសេវិករបស់ខ្ញុំបាននិយាយរួចមកហើយនោះ គឺថាមិនមានតុលាការដែលដំណើរការនោះទេ ហើយទីពីរគឺថា ដោយសារស្ថានភាពសង្គ្រាមស៊ីវិលដែលបានកើតឡើង។ ហើយនិងទីបី គឺថាសង្គ្រាម នោះត្រូវបានធ្វើឡើងដោយជនជាប់ចោទខ្លួនឯងផ្ទាល់។

គោលការណ៍ច្បាប់ ហើយនិងលក្ខណៈវិនិច្ឆ័យដែលអនុវត្តពាក់ព័ន្ធនឹងបញ្ហានេះគឺត្រូវបានកំណត់ដោយច្បាប់បស្ចិមប្រទេស។ ក៏ប៉ុន្តែបស្ចិមប្រទេសមិន ដែលមានស្ថានភាពដូចជាស្ថានភាពដែលបានកើតឡើងនៅក្នុងប្រទេសកម្ពុជាចាប់ពីក្រោយពីខែមករា ១៩៧៩ នោះទេ។

[១១:២៥:៤០]

ជាពិសេស គឺពាក់ព័ន្ធទៅនឹងប្រព័ន្ធតុលាការហើយនិងក្រោយពីសង្គ្រាមពិភពលោក។ ប្រទេសកម្ពុជាគឺជាប្រទេសដែលក្លាយទៅជាផេះផង់មានការបង្ហូរឈាម ហើយនិងញាំញីដោយសង្គ្រាមទៅដោយរបបកម្ពុជាប្រជាធិបតេយ្យ។ ហើយដោយក្នុងរបបនោះ គឺបញ្ញវន្តជាច្រើនគឺត្រូវបានសម្លាប់រង្គាល ឬក៏ត្រូវស្លាប់នៅក្នុងស្ថានភាពជាទាសករ គឺស្ថិតនៅក្នុងជំរុំជនភាសខ្លួននៅបរទេស ហើយប្រជាជនគឺត្រូវបានសម្លាប់អស់ប្រហែលជាមួយភាគបួន។ អត្ថិភាពរបស់មេដឹកនាំថ្មីនោះ គឺធ្វើយ៉ាងណាឲ្យមានស្ថិរភាពនៃអំណាចហើយនិងការសមប្រទេស គឺមិនបានគិតប្រព័ន្ធយុត្តិធម៌នោះឡើយ។ ក្នុងឋានៈជាអ្នកបស្ចិមប្រទេសនោះគឺ យើងមានការអាម៉ាស់ខ្លាំងណាស់ នៅចំពោះមុខស្ថានភាពនេះ ហើយយើងត្រូវតែគិតទៅលើបញ្ហាអង្គច្បាប់និងបញ្ហាអង្គហេតុ។

ខ្ញុំសូមត្រឡប់ទៅនឹងបញ្ហាដែលថា អត់មានពួកតុលាការដែលដំណើរការ។ ខ្ញុំសូមបញ្ជាក់ថាអត្ថិភាពនៃគោលការណ៍ច្បាប់ជាតិ និងអន្តរជាតិដែលកើតចេញពីលទ្ធិនៃការហាមឃាត់មិនឲ្យការធ្វើសកម្មភាព។ វាគឺជាគោលការណ៍ដែលនិយាយដោយសុភាសិតឡាតាំងមួយថា *កុងត្រាណុងវ៉ាឡង់តែម អាទ្រីណូឡាគូវីប្រេសគ្រីបតូ* (និយាយភាសាបារាំង) គឺមានន័យថា អាជ្ញាយុកាលមិនគិតប្រឆាំងទៅនឹងជនដែលស្ថិតនៅក្នុង អសមត្ថភាព អលទ្ធភាពក្នុងការធ្វើសកម្មភាពនោះឡើយ។

[១១:២៦:៥៨]

ដោយមិនបញ្ចេញឲ្យច្បាស់ គឺថាដោយយោងទៅលើគោលការណ៍នេះហើយដែលចៅក្រមទាំងមូលនៃអង្គបុរេជំនុំជម្រះ ហើយនិងអង្គជំនុំជម្រះសាលាដំបូងនោះបានសន្និដ្ឋានថា ការដឹកនាំកិច្ចស៊ើបសួរ ឬការចោទប្រកាន់ក្នុងអំឡុងកម្ពុជាប្រជាធិបតេយ្យ គឺមិនអាចធ្វើឡើងបានឡើយដោយអនុវត្តនូវ-- ដោយអវត្តមាននូវប្រព័ន្ធយុត្តិធម៌មួយដែលអាចដំណើរការបានគឺវាកើតចេញពីកថាខណ្ឌ១៤, ១៧ និង

២៧ នៃសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ហើយនិងកថាខណ្ឌ២៨៨ នៃសេចក្ដី សម្រេចខែមីនា របស់អង្គជំនុំជម្រះ។ នៅក្នុងកថាខណ្ឌដែលនោះ អង្គបុរេជំនុំជម្រះបានលើកឡើងយ៉ាងត្រឹមត្រូវថា ប្រសិនបើគោលបំណងនៃអាជ្ញាយុកាល គឺថាដើម្បីផ្ដល់នូវក្របខ័ណ្ឌពេលវេលា ដែលនៅក្នុងនោះការចោទប្រកាន់ឧក្រិដ្ឋកម្មត្រូវតែធ្វើឡើង ហើយនេះគឺជាការសន្មតិជាមុនថាស្ថាប័នយុត្តិធម៌ ពិតជាមានដំណើរមែន។ ដូច្នេះ តើប្រព័ន្ធតុលាការ ហើយនិងស្ថាប័នពិតជាបានដំណើរការពិតប្រាកដមែនទេ ចាប់ពីថ្ងៃទី៧ មករា ៧៩ មកនោះ?

[១១:២៨:១១]

សម្រាប់យើង គឺយើងមិនត្រូវច្រឡំគ្នាជាមួយនឹងប្រព័ន្ធតុលាការដែលមានប្រតិបត្តិការ ឬដំណើរការជាមួយនឹងប្រព័ន្ធតុលាការដែលមានលក្ខណៈល្អឥតខ្ចោះនោះទេ ហើយអ្វីដែលសហមេធាវីការពារក្ដីបាននិយាយនោះ គឺជាការបង្ហាញចេតនារបស់ខ្លួននៅក្នុងចម្លើយតបរបស់ខ្លួននៅក្នុងកថាខណ្ឌ៥។ ប៉ុន្តែគោលជំហររបស់យើង គឺថាប្រព័ន្ធយុត្តិធម៌ត្រូវតែបង្កើតឡើង ដើម្បីបំពេញទៅតាមលក្ខណៈវិនិច្ឆ័យអប្បបរមា និងជាមូលដ្ឋានដើម្បីឲ្យយើងអាចចាត់ទុកថា វាអាចដំណើរការបាន។ ហើយលក្ខណៈវិនិច្ឆ័យទាំងអស់នេះ គឺត្រូវតែជាវិនិច្ឆ័យជាលក្ខណៈរូបី គឺមិនមែនទៅលើ ផ្អែកទៅលើអង្គនីតិបញ្ញត្តិដែលមានស្រាប់នោះទេ។ ដូច្នេះ យើងត្រូវតែពិនិត្យមើលទៅលើលទ្ធភាពក្នុងការសិក្សាទៅលើសំណុំរឿងឲ្យបានច្បាស់លាស់ គឺថាយើងត្រូវធ្វើយ៉ាងម៉េចប្រមូលផ្ដុំនូវមធ្យោបាយទាំងអស់ដែលមាន ហើយនិងភស្តុតាងនៅក្នុងឯកសារហើយនិងស្ដាប់ចម្លើយសាក្សីទាំងដោះបន្ទុក និងដាក់បន្ទុកដោយមិនខ្លាចនូវការសងសឹកនោះឡើយ។ តុលាការដែលដំណើរការបែបនេះ គឺថាតម្រូវឲ្យមានអវត្តមាននៃភាពតាមទំនើងចិត្ត ហើយនិងភាពលម្អៀងហើយដែលមានការធានាមួយចំនួនផ្ដល់ជូនដល់ភាគីទាំងអស់ហើយជាពិសេសគឺខាងមេធាវីការពារក្ដី ហើយនិងខាងជនរងគ្រោះ។

ដូច្នេះ តុលាការដែលដំណើរការនោះ គឺដើម្បីអនុវត្តគោលការណ៍ថាអាជ្ញាយុកាលមិនអនុវត្ត។ ប្រព័ន្ធ ដែលបានបង្កើតឡើងដោយសាធារណរដ្ឋប្រជាមានិតកម្ពុជានៅឆ្នាំ៧៩ ហើយដែលបានកើតឡើងជាមួយនឹងការរៀបចំឲ្យមានកំណែទម្រង់ជាមូលដ្ឋាននៅឆ្នាំ៨២-៨៣ នោះមិនមែនជាប្រព័ន្ធតុលាការមួយដែលមានសុក្រិតភាពនោះទេ គឺវាមិនមានការធានាជាអប្បបរមា ដែលយើងអាចសន្និដ្ឋានបានថាតុលាការនោះមានដំណើរការនោះឡើយ។ យើងមិនត្រឡប់មកនិយាយអំពីយុត្តិធម៌ឆាកល្ខោនដែល គឺជាការកាត់ក្ដីដោយកំបាំងមុខទៅលើបន ប៉ុល ពត និង អៀងសារី នៅឆ្នាំ១៩៧៩ ដែលនៅក្នុងនោះគឺភាគី

បាននិយាយគ្នារួចមកហើយកាលពីថ្ងៃច័ន្ទ។

[១១:៣០:០៧]

អង្គជំនុំជម្រះនឹងកត់សម្គាល់ផ្ទាល់ទៅលើឯកសារដែលបានប្រគល់ជូនថា កម្រងនៃវិធាន នៃច្បាប់ព្រហ្មទណ្ឌ គឺថានៅសម័យនោះគឺមិនមានភាពពេញលេញនៅឡើយ។ ដូច្នេះ យើងត្រូវតែធ្វើការប្រៀបធៀបរដ្ឋធម្មនុញ្ញហើយនិងក្រឹត្យ និងច្បាប់ដែលនៅជាធរមានចាប់ពីឆ្នាំ៧៩ ជាមួយអ្វីដែលត្រូវបានអនុម័តចាប់ពីឆ្នាំ៩២មក។ ហើយសហសេវិករបស់ខ្ញុំបាននិយាយថា មុនកំណែទម្រង់ឆ្នាំ៩២-៩៣ ប្រព័ន្ធតុលាការហើយនិងតុលាការ គឺមិនមានការធានានោះទេសម្រាប់មេធាវីការពារក្តី ឬក៏សម្រាប់ជនរងគ្រោះ ហើយអតីតបុគ្គលិកតុលាការនោះគឺមិនមាននោះទេ ហើយបុគ្គលិកថ្មីគឺគ្មានសមត្ថភាព។

តុលាការសាលាឧទ្ធរណ៍ គឺមិនបានយល់ថា មានការចាំបាច់ក្នុងការវិនិច្ឆ័យឡើងវិញនោះទេ ពីព្រោះថាសាលក្រមទាំងអស់ត្រូវបានពិនិត្យដោយក្រសួងយុត្តិធម៌ ហើយការចាប់ខ្លួនគឺមិនបានធ្វើឡើងដោយផ្អែកលើមូលដ្ឋានគតិយុត្តិដែលអាចជឿបាននោះទេ។ ហើយសំណុំរឿងនៃភស្តុតាងនោះ ក៏មិនត្រូវបានបង្កើតឡើងនោះដែរ នៅមុននិងក្រោយពេលចាប់ខ្លួនលើកលែងតែមានសំណុំរឿងតិចតួចបន្តិចប៉ុណ្ណោះ។ ដូច្នេះ នេះជាការពិត១ ហើយនិងអង្គហេតុដែលអ្នកនិពន្ធនិងអ្នកវិភាគជាច្រើនបានសរសេរនៅក្នុងស្នាដៃរបស់ខ្លួន ហើយនិងក្នុងអត្ថបទដែលយើងបានភ្ជាប់ទៅក្នុងសារណារបស់យើង។ យើងត្រូវដឹងថា អយ្យការ ឬក៏តុលាការប្រជាជននោះ ថាតើគាត់បានធ្វើនូវកិច្ចស៊ើបសួរ ឬក៏ការចោទប្រកាន់ដែលផ្អាកអាជ្ញាយុកាលនោះទេ? យើងត្រូវតែពិនិត្យទៅលើប្រព័ន្ធតុលាការទាំងមូលហើយនិងសមាស-ភាពរបស់ប្រព័ន្ធតុលាការដើម្បីសួរសំណួរខ្លួនឯងថា តើលក្ខខណ្ឌអប្បបរមានៃការដំណើរការនោះត្រូវបានបំពេញដែរឬទេ?

[១១:៣១:៥៨]

ដូច្នេះ យើងឃើញថានៅក្នុងសារណារបស់ខ្លួនសហមេធាវីការពារក្តីបានធ្វើឱ្យយើងជឿថា គាត់បង្ហាញអំពីភាពប៉ិនប្រសព្វដោយបាននិយាយថា ចៅក្រមកម្ពុជានៃអ.វ.ត.ក គឺបានកាន់កាប់តំណែង នៅតុលាការនៅក្នុងឆ្នាំ ទសវត្សរ៍ឆ្នាំ៨០។ សហព្រះរាជអាជ្ញាសូមនិយាយថាគឺថា តុលាការកម្ពុជាគឺជាតុលាការដែលមានដឹងរឿងច្បាស់ដែលត្រូវបានដាក់ឱ្យវាយតម្លៃទៅលើស្ថានភាពនៃប្រព័ន្ធយុត្តិធម៌ ដែលកើតឡើងនៅក្នុងប្រទេសកម្ពុជាក្នុងចន្លោះឆ្នាំ៧៩ និងឆ្នាំ៩៣ ។ ហើយជាពិសេស គឺពួកគាត់បានស្គាល់ជាបន្តបន្ទាប់នូវស្ថានភាពនៃតុលាការនៅក្រោមសាធារណរដ្ឋប្រជាមានិតកម្ពុជា ហើយនិងប្រព័ន្ធតុលាការ

ក្នុងព្រះរាជាណាចក្រកម្ពុជា ដែលត្រូវបានបង្កើតឡើងដោយមានការជួយពីខាងអ៊ិនតាក់។

[១១:៣២:៤៨]

ដូច្នេះ យើងកត់សម្គាល់ឃើញថា ចៅក្រមកម្ពុជាដែលត្រូវតែសម្រេចទៅលើបញ្ហានៃអត្ថិភាព ឬក៏មិនមាន-- នីតិភាពនៃប្រព័ន្ធតុលាការ និងតុលាការដែលមានដំណើរការនៅចន្លោះឆ្នាំ៧៩ និងឆ្នាំ៩៣ នោះគឺ យើងអាចសន្និដ្ឋានបានថា នេះគឺជាសេចក្តីក្លាហានមួយដែលខ្ញុំគិតថា នេះមិនមែនជាករណីមួយដោយមានលក្ខណៈសត្យានុម័តនោះទេ។

[១១:៣៣:១១]

ហើយខាងមេធាវីការពារក្តីបានបញ្ជាក់ថា រដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋប្រជាមានិតកម្ពុជានៅឆ្នាំ៧៩នោះ គឺបង្ហាញពីអំពីអត្ថិភាពនៃប្រព័ន្ធតុលាការមួយដែលអាចដំណើរការបាន។ ហើយពាក់ព័ន្ធទៅនឹងរដ្ឋធម្មនុញ្ញឆ្នាំ៨១ យើងសូមឲ្យអង្គជំនុំជម្រះប្រៀបធៀបជាមួយរដ្ឋធម្មនុញ្ញឆ្នាំ៩៣។ ហើយយើងសូមបង្ហាញនូវចំណុចពីរ។ ទីមួយ បើយើងអានបុព្វកថារបស់រដ្ឋធម្មនុញ្ញនៅឆ្នាំ១៩៨១ នោះគឺវាមិនបញ្ជាក់អំពីឃ្លាដែលបញ្ជាក់ថា បន ប៉ុល ពត, អៀង សារី, ខៀវសំផន បានក្លាយជាបរិវាររបស់មេដឹកនាំវាតទីនិយម ហើយនិងអនុត្តរភាពនិយមនៃទីក្រុងប៉េកាំង។

នេះគឺជាឃ្លាដែលយើងបានឃើញមាននៅក្នុងបុព្វកថានៃរដ្ឋធម្មនុញ្ញ ហើយក៏វាមិនមែនជាភាសានៃរដ្ឋធម្មនុញ្ញសាមញ្ញ ហើយវាក៏មិនមែនជាការផ្តល់នូវគំនិតមួយនៃប្រភេទប្រព័ន្ធតុលាការដែលមាននៅក្នុងសម័យនោះដែរ។ នេះគឺវារំឭកឡើងវិញនូវការកត់សម្គាល់ដែលបានឃើញនៅក្នុងការកាត់ក្តី ប៉ុលពត និង អៀង សារី នៅខែសីហា ឆ្នាំ៧៩។

នេះគឺជាការកាត់ក្តីតាមបែបនយោបាយនៅក្នុងក្របខ័ណ្ឌមួយដែលបញ្ជាក់អំពីអំណាច ហើយនៅក្នុងបរិបទ សង្គ្រាមជាជាងឆន្ទៈនៅក្នុងការនាំមកវិញនូវយុត្តិធម៌ដែលអាចដំណើរការបាននោះ។

[១១:៣៤:២៨]

ហើយចំណុចទីពីរ គឺថារដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ បានបង្កើតនូវការបែងចែកអំណាចដាច់ពីគ្នា ហើយនិងអំណាចតុលាការ ដែលឯករាជ្យស្ថិតនៅក្រោមអាជ្ញាធររបស់តុលាការកំពូលជាមួយនឹងឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ហើយរដ្ឋធម្មនុញ្ញក៏បានផ្តល់អំណាចឲ្យចៅក្រមវិជ្ជាជីវៈបំពេញនូវភាតព្វកិច្ចវិនិច្ឆ័យទោសដោយផ្ទុយទៅនឹងរដ្ឋធម្មនុញ្ញឆ្នាំ៨១ ដែលនៅក្នុងអត្ថបទ នៅក្នុងមាត្រា៧៩ ដល់៨៦ គឺមិនបានបែងចែកអំណាចឲ្យដាច់ពីគ្នានោះទេ ហើយនិងក៏មិនបានបែងចែកទៅលើឋានានុក្រមតុលាការ

នោះដែរ ហើយក៏មិនបានលើកឡើងអំពីអត្ថិភាពនៃតុលាការប្រជាជន និងតុលាការយោធាដែរ គឺមាត្រា ៨០ ហើយរដ្ឋធម្មនុញ្ញនេះបានបញ្ជាក់អំពីអ្នកជំនួយទៅដល់ប្រជាជននៅអមជាមួយនឹងចៅក្រម ហើយមិនបានលើកឡើងអំពីសិទ្ធិដែលមានការកាត់បន្ថយចំពោះមេធាវីការពារក្តីនោះទេ។ ដូច្នេះ រដ្ឋធម្មនុញ្ញឆ្នាំ៨៩ នោះគឺថា បានលើកឡើងអំពីការធានាមួយចំនួនពាក់ព័ន្ធទៅនឹងការរៀបចំតុលាការ ហើយដែលត្រូវបានបដិសេធទៅដោយអង្គហេតុ។

[១១:៣៥:៣៦]

ខ្ញុំសូមនិយាយអំពីចំណុចដូចដែលយើងបាននិយាយហើយថា សង្គ្រាម គឺថាអាចធ្វើឱ្យមានការពន្យារពេល ឬក៏ផ្អាកនូវអាជ្ញាយុកាល ហើយការអនុវត្តជាតិ និងអន្តរជាតិជាច្រើនដែលត្រូវបានបញ្ជាក់ថា នៅក្នុងឋានៈ-- នៅពេលដែលមានសង្គ្រាមដែលនូវមានការអាក់ខាននូវប្រព័ន្ធតុលាការនោះ ត្រូវឱ្យមានការផ្អាកនូវអាជ្ញាយុកាល ហើយនៅលក្ខណៈអន្តរជាតិ គឺថានៅប្រទេសអាល្លឺម៉ង់ គឺនៅឆ្នាំ៣៣ ដល់៤៥នោះ គឺមានសេចក្តីសម្រេចរបស់តុលាការដែលមានចែងនៅក្នុងន័យនេះ ហើយនៅអាមេរិកក៏មាន នៅបារាំងក៏មាន ឬក៏នៅប្រទេសផ្សេងទៀតនៅអឺរ៉ុបផងដែរ។ នៅក្នុងក្របខ័ណ្ឌអន្តរជាតិ គឺមានគោលការណ៍ក្នុងការពន្យារអាជ្ញាយុកាលសម្រាប់ពលរដ្ឋ ឬក៏អាណិកជននៃមហាអំណាចពីរ ឬក៏ប្រទេសពីរដែលកំពុងតែមានសង្គ្រាម។

[១១:៣៦:២៩]

ប្រទេសកម្ពុជាបានស្ថិតនៅក្នុងករណីនេះ ជាមួយនឹងសង្គ្រាមដែលកើតមានរវាងសាធារណរដ្ឋប្រជាមានិតកម្ពុជា ហើយនិងកម្ពុជាប្រជាធិបតេយ្យនៅខែមករា ៧៩ រហូតទៅដល់ពេលទៅដល់កិច្ចព្រមព្រៀងសន្តិភាពទីក្រុងបារីស នៅខែតុលា ឆ្នាំ៩១ ហើយជាការពិតរហូតដល់ឆ្នាំ៩៨ ជាមួយនឹងប្រទេសដែលកំពុងមានសង្គ្រាមនោះ គឺមានការផ្លាស់ប្តូរឈ្មោះ។ ប្រសិនបើវាមិនមែនជា-- បើវាជាសង្គ្រាមរដ្ឋរវាងមហាអំណាចពីរនោះ អង្គការសហប្រជាជាតិក៏មិនបានពិនិត្យទៅលើធម្មនុញ្ញរបស់មេដឹកនាំរបស់កម្ពុជាប្រជាធិបតេយ្យ និងបដិសេធវៀតណាមដែលជាមហាអំណាចកាន់កាប់វាតទីនោះដែរ។

[១១:៣៧:១២]

បន្ថែមទៅលើប្រព័ន្ធតុលាការដែលមិនមានការដំណើរការនៅសម័យនោះ រាល់ការចោទប្រកាន់ ឬក៏ការស៊ើបអង្កេត គឺថាត្រូវបានបំផ្លាញទៅដោយសង្គ្រាម ហើយនិងការកាន់កាប់ទឹកដីកម្ពុជាដោយ

ផ្នែក ជាមួយនឹងអលទ្ធភាពដាច់ខាត ដែលថា យើងមិនអាច មិនត្រឹមតែមិនអាចចាប់ជនជាប់ចោទបាននោះទេ ហើយក៏យើងមិនអាចជូនដំណឹងអំពីសាលក្រមកំបាំងមុខទៅដល់ជនជាប់ចោទ ឬក៏យើងផ្តល់នូវដីកាកោះទៅឲ្យសាក្សីរបស់ខាងមេធាវីការពារក្តីនោះដែរ។

[១១:៣៧:៤៧]

ដូច្នេះ អត្ថិភាពនៃសម័យនោះគឺថា ត្រូវតែធ្វើសង្គ្រាមជាមួយនឹងជនជាប់ចោទ ហើយគឺធ្វើយ៉ាងណាដើម្បីឲ្យឈ្នះគាត់។ ហើយជាចុងក្រោយគឺយើងនិយាយថា ក្រៅពីតុលាការដែលស្ថិតនៅក្នុងបរិបទសង្គ្រាមនោះ គឺយើងមានបញ្ហាបីមួយទៀត ដែលបញ្ជាក់អំពីការពន្យារពេលនៃអាជ្ញាយុកាល។ វាគឺជាគោលការណ៍មួយដែលសង្ខេបឡើងដោយភាសិតឡាតាំងមួយ ដែលមានន័យថា គ្មានជនណាម្នាក់អាចសំអាងទៅលើកំហុសរបស់ខ្លួនផ្ទាល់នោះឡើយ។ ដោយសារតែមូលហេតុនេះហើយ អាជ្ញាយុកាលគឺថាមិនអាចត្រូវបានលើកឡើងជាស្របច្បាប់ទៅដោយជនជាប់ចោទនោះឡើយ។ ហើយដូចដែលអង្គបុរេជំនុំជម្រះបានលើកឡើងរួចមកហើយនូវកថាខណ្ឌ២៨៦ គឺមានការចោទថា ជនជាប់ចោទ គឺគាត់ទទួលខុសត្រូវនៅក្នុងការអលទ្ធភាពរបស់ប្រព័ន្ធតុលាការក្នុងការធ្វើការស៊ើបអង្កេត ហើយនិងការចោទប្រកាន់ នៅក្នុងអំឡុងខែមករា ឆ្នាំ៧៩ ដល់ខែកញ្ញា ឆ្នាំ៩៣ ហើយដែលពួកគេមិនអាចទទួលបាន។ ហើយចំពោះយើង គឺគាត់ជាអ្នកទទួលខុសត្រូវពីរជាន់។ គឺថាទីមួយ គាត់បានបំផ្លាញប្រព័ន្ធតុលាការទាំងអស់នៅចន្លោះឆ្នាំ៧៥ និងឆ្នាំ៧៩ ហើយវាបណ្តាលឲ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរ និងយ៉ាងយូរអង្វែងទៅលើប្រព័ន្ធតុលាការរបស់ប្រទេសកម្ពុជា ក្នុងចន្លោះជាងដប់ឆ្នាំជាងបន្ទាប់ពីប្រព្រឹត្តអំពើ ហើយនិងបានកើតឡើងរហូតមកដល់សព្វថ្ងៃនេះ។ ហើយទីពីរ ជនជាប់ចោទ ក៏ត្រូវតែទទួលខុសត្រូវដោយផ្នែកទៅលើសង្គ្រាមដែលបានបង្កឧបសគ្គទៅដល់ការចោទប្រកាន់នៅក្នុងចន្លោះឆ្នាំ៧៩ រហូតដល់ពេលដែលខ្លួនបានចុះចូល។

[១១:៣៩:៣៩]

ដូច្នេះ ចំពោះយើង គឺថាវាមិនអាចទទួលយកបានទេ ដោយសារតែលើទំនួលខុសត្រូវរបស់ជនជាប់ចោទក្នុងការដែលមិនអាចធ្វើឲ្យមានការចោទប្រកាន់បាន ដែលជនជាប់ចោទអាចទាញចំណេញបាន គឺការទាញចំណេញនេះមិនមែនជាការទាញចំណេញគ្រប់រឿងនោះទេ គឺជាការទាញចំណេញអំពីនិទ្ទណ្ឌភាពរបស់ខ្លួនធៀបទៅនឹងឧក្រិដ្ឋកម្មជាតិ។

ដូច្នេះ លោកប្រធាន លោក លោកស្រីចៅក្រមទាំងអស់ជាទីគោរព ខ្ញុំសូមបញ្ចប់ដោយសុំឲ្យ

អង្គជំនុំជម្រះប្រកាសថា ខ្លួនមានយុត្តាធិការទៅលើការចោទប្រកាន់ប្រឆាំងទៅនឹងជនជាប់ចោទអំពីបទឧក្រិដ្ឋកម្មជាតិ ដូចជាមនុស្សឃាត ទារុណកម្ម ការធ្វើទុក្ខបុកម្នេញខាងសាសនា ដោយសារតែមានការបង្ហាញថា អាជ្ញាយុកាល គឺមិនមានការកើតឡើងទេនៅក្នុងចន្លោះឆ្នាំ៧៩ និងឆ្នាំ៩២ ហើយខ្ញុំសូមរំឭកម្តងទៀតថា គឺបញ្ហានេះ គឺជាបញ្ហានីតិវិធី ហើយជាបន្ទាប់បន្សំ យើងសុំឲ្យប្រព័ន្ធ កត់សម្គាល់ថា ប្រព័ន្ធតុលាការកម្ពុជា គឺមិនមានលទ្ធភាពក្នុងការបើកកិច្ចស៊ើបសួរ ឬក៏ធ្វើការចោទប្រកាន់នៅក្នុងអំឡុងរយៈពេលដែលបានកើតឡើងក្រោយពីការដួលរំលំនៃកម្ពុជាប្រជាធិបតេយ្យ ហើយនិងរហូតមកដល់ឆ្នាំ១៩៩៣។ ដូច្នេះ ច្បាប់ឆ្នាំ២០០១ នៅក្នុងមាត្រា៣ ដោយពន្យារពេលអាជ្ញាយុកាល គឺមិនរំលោភទៅលើគោលការណ៍នៃអប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌដែរ។

ខ្ញុំសូមបញ្ចប់ត្រឹមនេះ។ សូមអរគុណលោកប្រធាន។

[១១:៤១:១១]

**ប្រធានអង្គជំនុំ៖**

អរគុណសហព្រះរាជអាជ្ញារងអន្តរជាតិ ហើយជាកិច្ចបន្តអង្គជំនុំជម្រះផ្តល់វេទិកាទៅសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីមានឱកាសក្នុងការធ្វើសេចក្តីថ្លែងការណ៍តបទៅនឹងអំណះអំណាងរបស់មេធាវីការពារក្តី។

**លោក ពេជ អង្គ៖**

លោកប្រធាន និងអង្គសវនាការទាំងមូល នៅក្នុងរយៈពេលដែលផ្តល់ដោយអង្គសវនាការនេះ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីសូមបែងចែកពេលវេលាដែលផ្តល់ជូននោះ នៅក្នុងចំណោមមេធាវីដើមបណ្តឹងរដ្ឋប្បវេណីដែលមានលោក ឡោ ជុនធី លោកមេធាវី គឹម ម៉េងឃី លោកស្រីមេធាវី ជេត វណ្ណលី ហើយនិងខ្ញុំបាទមេធាវីនាំមុខ ពេជ អង្គ នៅពេលបន្ទាប់ពីមេធាវីទាំងបីរូបនេះបានធ្វើបទអន្តរាគមន៍ឆ្លើយតប។ សូមលោកប្រធានអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាតតាមសំណើសុំ ហើយផ្តល់ជូនវេទិកាទៅលោកមេធាវី ឡោ ជុនធី។

សូមអញ្ជើញ!

**លោក ឡោ ជុនធី៖**

បាទ, ជាដំបូងខ្ញុំបានសូមគោរពអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ ខ្ញុំបាទជាមេធាវី

តំណាងដើមបណ្តឹងរដ្ឋប្បវេណី នៅពេលនេះ គឺសូមលើកឡើងអំពីតាមប្រធានបទដែលបានលើកឡើងនៅពេលនេះ គឺពាក់ព័ន្ធនឹងអញ្ញត្រកម្មដែលលើកឡើងនៅក្នុងច្បាប់ជាតិ។

[១១:៤៣:០៩]

ខ្ញុំសូមលើកឡើងនូវបរិបទមួយចំនួន ដែលជាបរិបទរបស់ប្រទេសកម្ពុជាយើង ថាតើប្រទេសកម្ពុជាយើងក្រោយពីឆ្នាំ១៩៧៩មក ដែលក្រោយពីរបបកម្ពុជាប្រជាធិបតេយ្យហ្នឹងបានផុតរលត់ទៅថា តើប្រទេសកម្ពុជាយើងហ្នឹងវាស្ថិតនៅក្នុងបរិបទយ៉ាងដូចម្តេច? ដូច្នេះ ការណ៍ដែលនៅក្នុងក្រោយឆ្នាំ១៩៧៩ មក គឺមានន័យថា ប្រជាជនកម្ពុជាដែលត្រូវបានវិលត្រឡប់ពីកន្លែងដែលត្រូវរបបកម្ពុជាប្រជាធិបតេយ្យជម្លៀសទៅហ្នឹង គឺថា គាត់វិលត្រឡប់ចូលភូមិកំណើត ឬមួយវិលមកនៅក្នុងប្រទេស-- នៅក្នុងទីកន្លែងដើមរបស់ខ្លួនវិញ។ អ៊ីចឹងមានន័យថា នៅពេលដែលប្រជាជនដែលវិលត្រឡប់មកវិញនេះ គឺមានការខ្វះខាត ខ្វះសព្វ ខ្វះគ្រប់ទាំងអស់ ហើយនៅពេលនោះ គឺមានបង្កើតឡើងនូវរដ្ឋាភិបាលមួយ ដែលជារដ្ឋាភិបាលដែលកកើតឡើងនៅក្នុងរបបសាធារណៈរដ្ឋប្រជាមានិតកម្ពុជា។ អ៊ីចឹងហើយនៅក្នុងរបបនេះ គឺបានជាការចាប់ផ្តើមដំបូង គឺធ្វើឲ្យការកសាងនូវធនធានមួយចំនួនតាំងពីអត់មានអ្វីទាល់តែសោះ។ បានន័យថា តាំងពីនោះ គឺយើងបានកសាងនូវប្រព័ន្ធការគ្រប់គ្រងរដ្ឋបាលសាធារណៈនានា គឺថាចាប់ពីអត់មានអីទាល់តែសោះ។

[១១:៤៤:៤៥]

ក្រោយមកទៀត គឺការវិវឌ្ឍន៍នៃប្រវត្តិនេះ គឺបានចូលទៅដល់នៅក្នុងរដ្ឋកាលមួយដែលហៅថា ការវិវឌ្ឍន៍ថ្មីនៃសង្គមកម្ពុជាយើង គឺឈានទៅដល់ការវិវឌ្ឍន៍នូវច្បាប់ថ្មីៗបន្តបន្ទាប់ គឺនៅក្នុងដំណាក់កាលមួយនោះ គឺគេហៅថា រដ្ឋកម្ពុជាបានន័យថា មានអត្ថិភាពនៅក្នុងឆ្នាំ១៩៨៩។ អ៊ីចឹង នៅពេលដែលកកើតនូវរដ្ឋថ្មីកម្ពុជានេះ គឺស្ថិតនៅក្នុងលក្ខខណ្ឌនៃរបបសង្គមនិយមដដែល។ អ៊ីចឹងហើយបានន័យថា ប្រព័ន្ធនៃការគ្រប់គ្រងប្រព័ន្ធច្បាប់វាអត់ទាន់មានការរីកចម្រើនអីទេ។ អ៊ីចឹងហើយបានយើងសួរថាតើការអនុវត្តនូវអាជ្ញាយុកាលនេះយ៉ាងដូចម្តេចកើត?

[១១:៤៥:៤៨]

នៅការវិវឌ្ឍន៍មួយទៀត គឺថានៅក្នុងសម័យបន្ទាប់មកទៀតនៅក្នុងឆ្នាំ១៩៩១ ទៅដល់១៩៩៣ នេះឯង ដែលជាការវិវឌ្ឍន៍ថ្មីមួយ ដែលប្រទេសកម្ពុជាយើងបានក្លាយទៅជាព្រះរាជាណាចក្រកម្ពុជា បានន័យថា មានរដ្ឋធម្មនុញ្ញមួយសម្រាប់ធ្វើការអនុវត្ត។ ហើយយើងសួរថា តើនៅពេលដែលយើងមាន

ការបោះឆ្នោតបានជារដ្ឋធម្មនុញ្ញមួយថ្មីនេះហើយ សួរថា តើយើងអាចអនុវត្តនូវពាក់ព័ន្ធនឹងអញ្ញត្រកម្ម ហើយពាក់ព័ន្ធនឹងអាជ្ញាយុកាលនៃក្រម១៩៥៦ហ្នឹង បានដែរ ឬមួយយ៉ាងម៉េច?

[១១:៤៦:៣៨]

យើងពិនិត្យឃើញថា នៅពេលនោះវានៅតែមានសង្គ្រាមស៊ីវិលកើតឡើងដដែល។ អ៊ីចឹង បានន័យថា សង្គ្រាមស៊ីវិលសួរថា សង្គ្រាមស៊ីវិលកើតឡើងរវាងនរណា? រវាងខាងខ្មែរក្រហមជាមួយនឹងរដ្ឋភិបាលថ្មី ហើយកាលពីរឿងចរចាដំបូងថា ចូលរួមជាមួយគ្នាដើម្បីកសាងប្រទេសជាតិឡើងវិញ ប៉ុន្តែចុងក្រោយបំផុត គឺធ្វើការពហិការមិនព្រមចូលនៅក្នុងការបោះឆ្នោត។ អ៊ីចឹងហើយចប់ពីការបោះឆ្នោត គឺមានសង្គ្រាមស៊ីវិលកើតឡើងដដែល។ ហេតុដូច្នេះ បើមានសង្គ្រាមស៊ីវិលកើតឡើងអ៊ីចឹងបានន័យថា វារាំងស្ទះដល់ប្រព័ន្ធនៃការគ្រប់គ្រងទូទៅប្រព័ន្ធច្បាប់ដដែល។

យើងពិនិត្យមើលថា តើរបបកម្ពុជាប្រជាធិបតេយ្យនេះវាផ្តល់នូវឥទ្ធិពលយ៉ាងម៉េចមកដល់ប្រជាជនកម្ពុជាហើយនិងធនធានមនុស្ស? ពាក់ព័ន្ធនឹងរឿងនេះ គឺថា ពីឆ្នាំ១៩៧៩មក ពេលដែលមុនឆ្នាំ ១៩៧៩ ពី៧៥ ដល់៧៩ គឺថា បំផ្លាញខ្ទេចនូវធនធានមនុស្សទាំងអស់។ អ៊ីចឹងហើយនៅពេលដែលយើងបានរំដោះមក គឺក្រោយ៧៩ គឺថាយើងត្រូវកសាងធនធានមនុស្សឡើងវិញ ហើយធនធានមនុស្សហ្នឹង គឺយើងបានន័យថា អង្កាល់ហ្នឹង គឺប្រទេសសង្គមនិយមបញ្ជូនមនុស្សទៅរៀននៅប្រទេសសង្គមនិយមនានា ដូចជាប្រទេសរុស្ស៊ី វៀតណាមជាដើម។

[១១:៤៨:១៥]

អ៊ីចឹង ពេលដែលកសាងបាននូវធនធានមនុស្សអស់នេះហើយ បានជាយើងធ្វើការវិវឌ្ឍន៍ជាបណ្តើរៗទៀត ដែលធ្វើឱ្យយើងអាចមានកិច្ចព្រមព្រៀងថ្មីមួយដែលបង្កើតនូវប្រព័ន្ធយុត្តិធម៌ ដើម្បីរកយុត្តិធម៌ឱ្យប្រជាជនកម្ពុជាដែលបានស្លាប់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនេះ គឺច្បាប់បង្កើត អ.វ.ត.ក យើងនេះឯង។ អ៊ីចឹងហើយខ្ញុំទាញមកវិញថា ដោយសាររបបនេះបានបំផ្លិចបំផ្លាញនូវរាល់ធនធានទាំងអស់ ទាំងហេដ្ឋារចនាសម្ព័ន្ធ ទាំងធនធានមនុស្សទាំងអស់ អ៊ីចឹងហើយបានន័យថា វាមិនអាចអនុវត្តបាននូវអ្វីដែលជាក្រមបានចែងពីអាជ្ញាយុកាលនេះ។

[១១:៤៩:១២]

ដូច្នេះ ដោយសារមានការសន្និដ្ឋានឡើងលើនេះ ខ្ញុំបាទយល់ឃើញថា អាជ្ញាយុកាលដែលលើកឡើងដោយខាងមេធាវីការពារនេះ អញ្ញត្រកម្មនេះ មិនត្រូវបានអនុវត្តទេ ដោយសារទីមួយ វាពាក់ព័ន្ធ

នឹងការបំផ្លិចបំផ្លាញហេដ្ឋារចនាសម្ព័ន្ធ។ ទីពីរ គឺពាក់ព័ន្ធនឹងគ្មានធនធានមនុស្ស។ ទីបី គឺប្រព័ន្ធច្បាប់ដែលទើបតែកកើតឡើងចាប់ពីឆ្នាំ១៩៩៣ ដែលយើងបានបោះឆ្នោតនេះហើយ ប៉ុន្តែនៅក្នុងចន្លោះ ៩៣ និង៩៨ហ្នឹង មានបញ្ហាតទៅទៀត គឺថាសង្គ្រាមវាកកើតដល់៩៨ ទើបយើងមានហៅថា សមាហរណកម្មចូលមកបានមានសន្តិភាព។

[១១:៥០:០០]

អ៊ីចឹង បានយើងមានឱកាសនៅធ្វើអង្គសវនាការនៅ អ.វ.ត.ក យើងនេះ។ ដូច្នេះខ្ញុំបាទសូមទាញនូវសេចក្តីសន្និដ្ឋានប៉ុណ្ណេះ។ សូមអរគុណ។

**លោក ម៉ៃខល កាណាវាស៖**

លោកប្រធានដោយសារខ្ញុំមិនចង់រំខានទេ ក៏ប៉ុន្តែអ្វីដែលគាត់លើកឡើងនោះដូចជាបង្ហាញពីសក្ខីកម្ម ហើយខ្ញុំយល់ថា មានការចាំបាច់ដើម្បីលើកឡើងអំពីអង្គហេតុជាសេចក្តីអធិប្បាយ ប៉ុន្តែយើងនិយាយអំពីបញ្ហាអង្គច្បាប់ទេ យើងមិននិយាយអំពីអង្គហេតុនោះទេ។ អំពីរបៀបប្រព័ន្ធច្បាប់ដំណើរការម៉េច? អង្គហេតុនោះគឺថាយើងមិនអាចធ្វើបែបនោះទេ ប៉ុន្តែនៅក្នុងពេលនេះយើងគប្បីតែលើកឡើងអំពីបញ្ហាអង្គច្បាប់ដែលទាក់ទងទៅនឹងអាជ្ញាយុកាល។ ហើយមិននិយាយពីបទពិសោធន៍នៃបុគ្គលណាម្នាក់ៗជនជាប់ចោទណាម្នាក់ៗនៅក្នុងតំណាក់កាលនោះទេ។ ដូច្នេះ ខ្ញុំសូមជំរុញឲ្យអង្គជំនុំជម្រះមេត្តាប្រុងប្រយ័ត្នក្នុងការឲ្យភាគីលើកនូវសេចក្តីសន្និដ្ឋានឲ្យគោរពទៅតាមគោលការណ៍ច្បាប់ និងប្រធានបទដែលយើងបានលើកឡើងនាពេលនេះ។

**ប្រធានអង្គជំនុំ៖**

អូខេ សូមអញ្ជើញលោកមេធាវីបន្តទៀត មេធាវីបន្ទាប់ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីដែលបានទទួលសិទ្ធិពីមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី។ បន្តទៀតអង្គជំនុំជម្រះផ្តល់វេទិកាមួយទៀត មុននឹងសម្រាកពិសាអាហារថ្ងៃត្រង់។ សូមអញ្ជើញ!

[១១:៥០:១៩]

**លោក គីម ម៉េងឃី៖**

បាទ, សូមអរគុណលោកប្រធាន។ លោកប្រធាន លោក លោកស្រីចៅក្រមជាតិ និងអន្តរជាតិជាទីគោរព អង្គសវនាការទាំងមូលជាទីគោរព។ ហើយសូមអរគុណចំពោះការកត់សម្គាល់របស់សហមេធាវីការពារក្តីលោក អៀង សារី មុននេះបន្តិច ក៏ប៉ុន្តែក្នុងនាមមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី

ខ្ញុំសូមបញ្ជាក់ថាអញ្ញាត្រកម្មនេះលើកឡើងគួរតែត្រូវគួបផ្សំជាមួយនឹងអង្គហេតុ និងអង្គច្បាប់ដើម្បីធានាឲ្យមានការសិទ្ធិរបស់ភាគីដែលពាក់ព័ន្ធនៅក្នុងនីតិវិធី ស្ដីអំពីអាជ្ញាយុកាលនៃបទល្មើសនៅក្នុងច្បាប់ជាតិនេះ។

[១១:៥២:៥០]

សហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីសូមធ្វើការឆ្លើយតបចំពោះអញ្ញត្រកម្មរបស់សហមេធាវីពាក់ព័ន្ធទៅនឹងអាជ្ញាយុកាលនៃបទល្មើសជាតិក្នុងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ដូចតទៅ៖

ជាបឋម សហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីយល់ឃើញថា បញ្ញត្តិព្រហ្មទណ្ឌឆ្នាំ១៩៥៦ នៅស្ថិតជាធរមានសម្រាប់អង្គហេតុដែលកើតឡើងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ចំណែក ឯអាជ្ញាយុកាលនៃបទល្មើសក្នុងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ដែលត្រូវបានពន្យារដោយមាត្រា៣(ថ្មី) នៃច្បាប់ អ.វ.ត.ក នៅមានអានុភាពនៅចំពោះមុខ អ.វ.ត.ក ហើយការពន្យារចិរវេលានៃអាជ្ញាយុកាលនេះ ដោយចាប់គិតពីឆ្នាំ១៩៧៥ ដល់ ឆ្នាំ១៩៩៣ ជាមូលហេតុត្រឹមត្រូវសម្រាប់យុត្តិធម៌ស្របតាមនិយាមអន្តរជាតិ។

ចន្លោះឆ្នាំ១៩៧៥ ដល់ ឆ្នាំ១៩៧៩ ជនរងគ្រោះប្រមាណជាង៣លាននាក់ ដែលក្នុងនោះមានមន្ត្រីរាជការ ទាហាន មេធាវី ចៅក្រម រដ្ឋអាជ្ញា ព្រះសង្ឃ បញ្ញវន្ត និងប្រជាជនផ្សេងទៀតត្រូវបានកាប់សម្លាប់ប្រហារក្រោមរូបភាព គ្រប់រូបភាពទាំងអស់។ ហើយក្នុងសម័យនោះ អ្នកដែលរួចផុតពីការកាប់សម្លាប់ផ្សេងទៀតរួមទាំងកុមារផងត្រូវបានលុបបំបាត់សិទ្ធិសេរីភាពគ្រប់បែបយ៉ាង និងដាក់ឲ្យរស់ក្នុងរបបទាសភាពនៃគុកឥតជញ្ជាំង។

[១១:៥៤:៣៤]

នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេតបានរកឃើញថា អំពើដែលប្រព្រឹត្តនៅក្នុងសម័យកាលដែលគ្រប់គ្រងដោយរបបកម្ពុជាប្រជាធិបតេយ្យជាធាតុផ្សំក្រោមបទចោទប្រកាន់នៃអំពើមនុស្សឃាត អំពើទារុណកម្ម និងការវាយប្រហារលើសាសនា ដែលមានចែង និងផ្ដន្ទាទោសតាមក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦។ យើងខ្ញុំយល់ស្របលើការបកស្រាយរបស់ក្រុមមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី សហព្រះរាជអាជ្ញា និងមតិចៅក្រមជាតិ ក្នុងសំណុំរឿង០០១ ថាចិរវេលានៃអាជ្ញាយុកាលដែលបានពន្យារដោយមាត្រា៣ថ្មី ជាច្បាប់ដែលមានលក្ខណៈជានីតិវិធី ហើយមិនចាត់ទុកថាជាច្បាប់សារធាតុនោះទេ។

លើសពីនេះ យើងខ្ញុំយល់ឃើញថា ការពន្យារចិរវេលានៃអាជ្ញាយុកាលនេះមិនរំលោភលើគោល

ការណ៍អប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌដែលមានចែងដោយច្បាប់រដ្ឋធម្មនុញ្ញឡើយ។ ហើយក្រុមប្រឹក្សារដ្ឋធម្មនុញ្ញក៏បានប្រកាសដែលថា ការពន្យារអាជ្ញាយុកាលដោយមាត្រា៣(ថ្មី) នៃច្បាប់ អ.វ.ត.ក មិនផ្ទុយនឹងរដ្ឋធម្មនុញ្ញទេ។

[១១:៥៥:៥០]

ការពន្យារ និងការព្យួរថិរវេលាអាជ្ញាយុកាល ជាការធានានូវការអនុវត្តនូវគោលការណ៍រឿងក្តីប្រកបដោយសមធម៌ និងធានានូវការគោរពសមភាពចំពោះមុខច្បាប់ស្របតាមបទដ្ឋានអន្តរជាតិ។ ការពន្យារ និងការព្យួររយៈពេលអាជ្ញាយុកាលចន្លោះពីឆ្នាំ១៩៧៥ ដល់ ឆ្នាំ១៩៩៣ ត្រូវបានធ្វើឡើងដោយមិនផ្តោតត្រឹមតែការចោទប្រកាន់លើមេដឹកនាំ ឬអ្នកទទួលខុសត្រូវខ្ពស់បំផុតនៃរបបកម្ពុជាប្រជាធិបតេយ្យនោះទេ ក៏ប៉ុន្តែការពន្យារ និងការព្យួរនោះគឺផ្តោតសំខាន់ផងដែរនៅក្នុងការស្វែងរកការពិត និងយុត្តិធម៌សម្រាប់ជនរងគ្រោះនៃរបបកម្ពុជាប្រជាធិបតេយ្យ ដើម្បីឲ្យមាននីតិវិធីមួយដែលអាចនាំឲ្យមានការបង្រួបបង្រួមជាតិ និងការផ្សះផ្សាជាតិរវាងជនរងគ្រោះ និងអតីតខ្មែរក្រហមថ្នាក់ក្រោម។

យោងតាមរបាយការណ៍ស្ទាបស្ទង់មតិមួយដោយមជ្ឈមណ្ឌលសិទ្ធិមនុស្សនៃសកលវិទ្យាល័យ *ប៊ើកឡេ* បានពិពណ៌នាក្នុងន័យមួយថាយុត្តិធម៌មិនមែនជាកិច្ចការអាទិភាព ហើយកិច្ចអាទិភាពសម្រាប់ប្រជាពលរដ្ឋ គឺជាបញ្ហាសេដ្ឋកិច្ច។ ការលើកយករបាយការណ៍នេះ គឺគ្រាន់តែចង់បញ្ជាក់ជូនលោក លោកស្រីចៅក្រមមេត្តាជ្រាបថា យុត្តិធម៌របស់ជនរងគ្រោះពិតជាបានត្រូវរារាំងដោយបញ្ហាអស្ថិរភាពនយោបាយផង និងបញ្ហាសេដ្ឋកិច្ចដែលប្រជាពលរដ្ឋ-- ដែលជនរងគ្រោះនៅក្នុងរបបខ្មែរក្រហមចាប់តាំងពីឆ្នាំ១៩៧៩ មកដល់ ឆ្នាំ១៩៩៣ ហ្នឹង គឺជួបនូវគ្រោះស្រេកឃ្លានដែលមិនអាចគិតគូរជាអទិភាពនៅក្នុងការស្វែងរកយុត្តិធម៌ ចំពោះអំពើដែលបានប្រព្រឹត្តដោយរបបកម្ពុជាប្រជាធិបតេយ្យឡើង។

[១១:៥៧:៥៥]

លើសពីនេះទៀត វត្តមានរបស់កងទ័ពខ្មែរក្រហមដ៏សម្បើមនៅមួយផ្នែកនៃដែនដីកម្ពុជា សមាជិកខ្មែរក្រហមនៅក្នុងឧត្តមក្រុមប្រឹក្សាជាតិ ហៅកាត់ថា អេស. អ៊ិន. ស៊ី កង្វះឆន្ទៈនយោបាយនៅក្នុងការស្វែងរកយុត្តិធម៌ និងសំណងជនរងគ្រោះ គឺសុទ្ធសឹងតែជាបុព្វហេតុចម្បងដែលរារាំងមិនឲ្យជនរងគ្រោះដោយរបបកម្ពុជាប្រជាធិបតេយ្យទទួលបាននូវយុត្តិធម៌ក្នុងអំឡុងពេលសមស្រប។ ហេតុនេះ ការពន្យារអាជ្ញាយុកាលសម្រាប់ការកាត់ទោសមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរលើក្រមព្រហ្មទណ្ឌកម្ពុជា គឺជាមូលហេតុ

ចាំបាច់ដើម្បីធានាសិទ្ធិទទួលបានការពិតនិងយុត្តិធម៌ សម្រាប់ជនរងគ្រោះនៃរបបកម្ពុជាប្រជាធិតេយ្យ។

[១១:៥៨:៥៦]

សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីសូមបញ្ជាក់អំពីគោលជំហរគាំទ្រចំពោះអង្គហេតុ និងអង្គច្បាប់របស់សហព្រះរាជអាជ្ញា និងមតិចៅក្រមជាតិនៅក្នុងសំណុំរឿង០០១ ដែលលើកឡើងថា ថិរវេលានៃអាជ្ញាយុកាលត្រូវផ្អាកអនុវត្តចាប់ពីឆ្នាំ១៩៧៥ ដល់ ឆ្នាំ១៩៩៣ ក្នុងអំឡុងពេលដែលគ្មានប្រព័ន្ធតុលាការដែលអាចដំណើរការបាន បញ្ហាសង្គ្រាមស៊ីវិល ការរារាំងរបស់ជនជាប់ចោទចំពោះការកាត់សេចក្តីលើពួកគេក្នុងអំឡុងពេលនោះ។

លើសពីនេះទៀត មតិរបស់ចៅក្រមអន្តរជាតិនៅក្នុងសំណុំរឿង០០១ លើកឡើងថា រហូតមកទល់បច្ចុប្បន្ននេះមិនមានវិធានការប្រហាក់ប្រហែលណាមួយត្រូវបានអនុម័ត ដោយអង្គនីតិបញ្ញត្តិកម្ពុជានោះទេ។ ហើយមិនមានយុត្តិសាស្ត្រកម្ពុជាបង្ហាញអំពីថិរវេលានៃអាជ្ញាយុកាលដែលព្យួរ ឬផ្អាច់ដោយសារតែអសមត្ថភាពនៃប្រព័ន្ធតុលាការមុនឆ្នាំ១៩៩៣ ដាក់ជូនអង្គជំនុំជម្រះទេ។ ហើយមតិនេះ ទំនងជាត្រូវបានគាំទ្រដោយមេធាវីការពារក្តីផងដែរ។

[១២:០០:១២]

សហមេធាវីយល់ឃើញថា ថ្វីត្បិតតែគ្មានការអនុម័តដោយសភាជាតិ និងគ្មានយុត្តិសាស្ត្រតុលាការក៏ពិតមែន យើងខ្ញុំយល់ឃើញថាការខកខានបែបនេះមិនអាចលើកយកមកជាមូលហេតុសម្រាប់បដិសេធសិទ្ធិទទួលបានការពិត យុត្តិធម៌ និងសំណងរដ្ឋប្បវេណីរបស់ជនរងគ្រោះដែលបានខូចខាតដោយការបំផ្លិចបំផ្លាញនៃរបបកម្ពុជាប្រជាធិបតេយ្យ ជាពិសេស សិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង០០២នេះឡើយ ពីព្រោះថា ស្មារតីនៃការបង្កើតក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ មានគោលបំណងទប់ស្កាត់មិនឲ្យមានបទល្មើសកើតឡើងផង និងមានគោលបំណងដាក់ទណ្ឌកម្មចំពោះឧក្រិដ្ឋកម្មដែលបានកើតឡើងក្រោយពីច្បាប់នោះនៅជាធរមានផង។ ដើម្បីផ្តល់ការពិតនិងសំណងដល់ជនរងគ្រោះក្នុងអំឡុងពេលដែលច្បាប់នោះនៅជាធរមាន។

[១២:០១:១៦]

ជាក់ស្តែង ក្នុងរឿងក្តី *អាល់ហ្វ្រេតតូ ហ្វ៊រទី* ជាមួយនិង *កាឡូស ហ្គីយ៉ាម៉ូ ហ្សូរ៉េសមែនសុន* តុលាការអាមេរិកបានសម្រេចថា បើទោះបីជាអាជ្ញាយុកាល បណ្តឹងអាជ្ញាបានផុតកំណត់ហើយក៏ដោយ ការព្យួរបែបសមធម៌នូវថិរវេលាអាជ្ញាយុកាលតម្រូវឲ្យមានក្នុងខណៈដែលជនរងគ្រោះនៃរបប

យោធាផ្តាច់ការ អាហ្សង់ទីន មិនអាចស្វែងរកការពឹងពាក់តាមផ្លូវច្បាប់បាន។

[១២:០១:៥០]

ហើយដូចដែលសហព្រះរាជអាជ្ញា និងសហមេធាវីបានលើកឡើងរួចហើយ ប្រទេសកម្ពុជាបានឆ្លងកាត់នូវរបត់នយោបាយជាច្រើនពេលគឺ នៅក្នុងឆ្នាំ១៩៧៩ ដល់ ឆ្នាំ១៩៨៩ ប្រទេសកម្ពុជាប្រកាន់នូវលទ្ធិសង្គមនិយម ដែលមានរចនាសម្ព័ន្ធដឹកនាំដោយប្រជាមានិតកម្ពុជានិងរដ្ឋកម្ពុជា។ ហើយក្នុងលទ្ធិសង្គមនិយមនោះទៀតសោត គេមានទ្រឹស្តីមួយថា "រដ្ឋជាអ្នកគ្រប់គ្រង បក្សជាអ្នកដឹកនាំ" មានន័យថា រាល់ទ្រព្យសម្បត្តិ រាល់វត្ថុសុទ្ធតែជារបស់រដ្ឋទាំងអស់។ ហើយរាល់កិច្ចរដ្ឋបាលទាំងអស់គឺបក្សជាអ្នកដឹកនាំ ទោះបីជាមានតុលាការនៅក្នុងសម័យនោះក៏ដោយ ការសម្រេចដោយតុលាការនឹងត្រូវជាកម្មវត្ថុនៃការត្រួតពិនិត្យឡើងវិញដោយមជ្ឈិមបក្សនៅក្នុងសម័យនោះ។

[១២:០២:៥៣]

លើសពីនេះទៀត នៅក្នុងរយៈពេលនៃការចរចាកិច្ចព្រមព្រៀងក្រុងប៉ារីសក៏ជាមូលហេតុមួយដែរ ដែលធ្វើឲ្យប្រព័ន្ធយុត្តិធម៌មិនដំណើរការ។ ហើយការវិវឌ្ឍន៍សម័យកាលនីមួយៗនៅក្នុងពេលនោះគឺថា មេធាវី ចៅក្រម ព្រះរាជអាជ្ញា គឺមានបញ្ហាកង្វះខាតជាសត្យានុម័ត។

ក្នុងករណីជាក់ស្តែងការកាត់ទោសលោក អៀង សារី និង ប៉ុល ពត នៅក្នុងសម័យឆ្នាំ១៩៧៩ សិទ្ធិរបស់ជនរងគ្រោះ និងសិទ្ធិរបស់ជនជាប់ចោទមិនត្រូវបានធានា ដោយរឿងក្តីប្រកបដោយសមធម៌នោះទេ ពីព្រោះថាការកាត់ទោសនោះមានចរិតជាលក្ខណៈនយោបាយច្រើនជាងការរកយុត្តិធម៌ និងការពិតសម្រាប់ជនរងគ្រោះ។

ដូចដែលមានជម្រាបជូនខាងលើសហមេធាវីយល់ឃើញថា ប្រព័ន្ធច្បាប់កម្ពុជាមិនមានសមត្ថភាពដោយសត្យានុម័តគ្រប់គ្រាន់ដើម្បីផ្តើមធ្វើការស៊ើបសួរ និងធ្វើការចោទប្រកាន់មេដឹកនាំកម្ពុជាប្រជាធិបតេយ្យនៅចន្លោះឆ្នាំ១៩៧៥ ដល់ ឆ្នាំ១៩៩៣ នោះទេ ហើយនេះជាមូលហេតុត្រឹមត្រូវនៃការព្យួរអាជ្ញាយុកាល។

[១២:០៤:២៥]

ដូចដែលបានបញ្ជាក់នៅក្នុងសាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយដោយអង្គបុរេជំនុំជម្រះថា ការព្យួរអាជ្ញាយុកាលនៅពេលដែលស្ថាប័នមិនដំណើរការក៏ត្រូវបានចាត់ទុកជាការចាំបាច់ផងដែរ ដើម្បីធានាការពារសិទ្ធិជនរងគ្រោះក្នុងការទទួលបានសំណង

អំពីការរំលោភយ៉ាងធ្ងន់ធ្ងរ ដោយសារតែឧក្រិដ្ឋកម្មនានាដូចជាឧក្រិដ្ឋកម្មដែលជាកម្មវត្ថុនៃយុត្តាធិការរបស់ អ.វ.ត.ក។

[១១:០៥:០៥]

ក្នុងន័យនេះ មេធាវីដើមបណ្តឹងរដ្ឋប្បវេណីយល់ឃើញផងដែរថា ចាប់តាំងពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៩៣ មិនមានច្បាប់កម្ពុជាណានិងកាលៈទេសៈណាអំណោយផល ដែលអនុញ្ញាតឲ្យភាគីដើមបណ្តឹងរដ្ឋប្បវេណីដែលជាជនរងគ្រោះ ឬសាច់ញាតិជនរងគ្រោះមានលទ្ធភាពក្នុងការទាមទារទៅស្ថាប័នតុលាការដើម្បីទទួលបានសំណងផ្លូវចិត្តនិងសមូហភាព ដូចដែលមានចែងនៅក្នុងច្បាប់ អ.វ.ត.ក និងវិធានផ្ទៃក្នុងនៃ អ.វ.ត.ក នោះទេ។

ការព្យួរអាជ្ញាយុកាលពីឆ្នាំ១៩៧៥ ដល់ ឆ្នាំ១៩៩៣ គឺជាការធានាផងដែរនូវសិទ្ធិទទួលបានសំណងសម្រាប់ជនរងគ្រោះស្របតាមក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ផង និងស្របតាមច្បាប់ អ.វ.ត.ក ផង។

សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីសូមគាំទ្រផងដែរ ចំពោះការយល់ស្របដោយអង្គបុរេជំនុំជម្រះកំណត់ថា ចិរវេលានៃអាជ្ញាយុកាលបទល្មើសជាតិ ត្រូវរាប់ចាប់ពីថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ ពោលគឺជាថ្ងៃដែលប្រកាសឲ្យប្រើរដ្ឋធម្មនុញ្ញកម្ពុជា ហើយជាថ្ងៃដែលអំណាចនីតិបញ្ញត្តិ នីតិប្រតិបត្តិ និងអំណាចតុលាការ ត្រូវបានបែងចែកដាច់ពីគ្នានិងឯករាជ្យពីគ្នាតាមស្មារតីនៃរដ្ឋធម្មនុញ្ញ។

[១២:០៦:៥៥]

មាត្រា៣(ថ្មី) នៃច្បាប់ អ.វ.ត.ក ត្រូវបានតាក់តែងឡើងស្របតាមស្មារតីរដ្ឋធម្មនុញ្ញ ហើយការពន្យារពេលអាជ្ញាយុកាលដើម្បីធានាថា ការចោទប្រកាន់បទល្មើសជាតិទាំងឡាយនឹងមិនត្រូវបានរារាំងដោយបញ្ហាអាជ្ញាយុកាល ដែលមានចែងនៅក្នុងច្បាប់ព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ នោះទេ។

ការវិវឌ្ឍន៍នៃការការពារសិទ្ធិជនរងគ្រោះ និងពាក់ព័ន្ធនឹងការសម្រេចការពន្យារអាជ្ញាយុកាលមានដូចជានៅក្នុងរឿងក្តី *បារីយ៉ូសាតូស* ប្រឆាំងទៅប្រទេសប៉េរូ។ តុលាការអន្តរអាមេរិកាំងបានចាត់ទុកថា មិនអាចទទួលយកនូវបដិបញ្ញត្តិ (សូមទោស)មិនអាចទទួលយកនូវបញ្ញត្តិ ស្តីពីរយៈពេលនៃការលើកលែងទោស ឬរយៈពេលនៃការគ្រប់គ្រងវិធានការទាំងអស់ ដែលរាំងស្ទះដល់ការស៊ើបអង្កេត និងដាក់ទណ្ឌកម្មចំពោះអ្នកដែលរំលោភបំពានធ្ងន់ធ្ងរលើសិទ្ធិមនុស្ស។

[១២:០៨:០២]

ក្នុងន័យនេះ ការទទួលស្គាល់នៃការរលត់អាជ្ញាយុកាលមិនគិតពីមូលហេតុនៃការរារាំងចំពោះការចោទប្រកាន់ ជាការប្រឆាំងនឹងការវិវត្តន៍នៃនីតិអន្តរជាតិ ហើយការបកស្រាយលើការពន្យារអាជ្ញាយុកាល ត្រូវធានាសិទ្ធិទទួលបានយុត្តិធម៌របស់ភាគីទាំងអស់។

អាជ្ញាយុកាល ត្រូវបានពន្យារនៅក្នុងមាត្រា៣(ថ្មី) នៃច្បាប់ អ.វ.ត.ក ជាអាជ្ញាយុកាលពិសេស ខុសពីអាជ្ញាយុកាលដែលមានចែងនៅក្នុងច្បាប់ជាតិ។

[១២:០៨:៣៧]

ចំណែក អ.វ.ត.ក ជាតុលាការពិសេសដែលបង្កើតឡើងដោយច្បាប់ពិសេស ហេតុដូច្នេះ អ.វ.ត.ក មិនត្រូវចងកាតព្វកិច្ចអនុវត្តគោលការណ៍បកស្រាយការពន្យារអាជ្ញាយុកាលតាមថិរវេលាដូចមានចែងក្នុងច្បាប់ជាតិនោះទេ។

ហើយមាត្រា១ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ចែងថា អ.វ.ត.ក មានសមត្ថកិច្ចដើម្បីវិនិច្ឆ័យជនទាំងឡាយដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មនានា ដូចមានចែងនៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ពោលគឺ បទឧក្រិដ្ឋនានាដែលបានប្រព្រឹត្តនៅក្នុងចន្លោះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ ថ្ងៃ០៦ ខែមករា ឆ្នាំ ១៩៧៩ មានដូចជា អំពើមនុស្សឃាត ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញខាងជំនឿសាសនាជាដើម។

[១២:០៩:២៩]

ដោយផ្អែកតាមការបកស្រាយខាងលើនេះ ការពន្យារ និងការព្យួរអាជ្ញាយុកាល ត្រូវធ្វើឡើងស្របជាមួយនឹងគោលបំណងថ្លឹងថ្លែងអំពីសិទ្ធិភាគីពាក់ព័ន្ធ ហើយការពន្យារ និងការព្យួរអាជ្ញាយុកាល ជាវិធានពិសេសដែលត្រូវបដិបញ្ញត្តិនឹងវិធានទូទៅ ហើយនិងជាករណីលើកលែងនៃវិធានពាក់ព័ន្ធនឹងអាជ្ញាយុកាលផងដែរ។

ស្របគ្នានឹងការលើកឡើងក្នុងសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ បញ្ជាក់ថា ច្បាប់ អ.វ.ត.ក រួមទាំងមាត្រា៣(ថ្មី) ផង បានអនុវត្តយ៉ាងស្មើភាពគ្នាចំពោះបុគ្គលដែលស្របតាមលក្ខខណ្ឌ ដែលត្រូវបានបង្កើតឡើង ដោយមានលក្ខណៈវិនិច្ឆ័យប្រកបដោយសត្យានុម័ត និងសមហេតុផលដែលស្ថិតក្រោមយុត្តាធិការរបស់ អ.វ.ត.ក ទៅលើបុគ្គល និងពេលវេលា។

[១២:១០:៤០]

លើសពីនេះទៀត ថ្មីៗនេះសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី សូមថ្លែងអំណរគុណ និងយល់

ស្របចំពោះគោលជំហររបស់អង្គបុរេជំនុំជម្រះ ដែលបានសម្រេចទទួលស្គាល់ដើមបណ្តឹងរដ្ឋប្បវេណីរហូតដល់៩៨ភាគរយ នៃដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ដែលត្រូវបានបដិសេធដោយសហចៅក្រមស៊ើបអង្កេត និងសូមគាំទ្រគោលជំហរផ្សេងទៀតក្នុងសាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេត លើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដោយសុំដកស្រង់ចំណុចមួយនៅក្នុងកថាខណ្ឌទី៣៥ នៃសាលដីកានោះថា អនុលោមតាមវិធាន២១ នៃវិធានផ្ទៃក្នុង អង្គបុរេជំនុំជម្រះមានកាតព្វកិច្ចធានាថា ដំណើរការនីតិវិធីក្នុងអង្គជំនុំជម្រះវិសាមញ្ញត្រូវតែមានយុត្តិធម៌។ ផ្នែកនេះ គឺពាក់ព័ន្ធនឹងបុគ្គលទាំងឡាយដែលស្ថិតក្នុងភាពស្រដៀងគ្នា ដែលត្រូវបានប្រព្រឹត្តដោយស្មើគ្នានៅចំពោះមុខសាលាក្តីនេះ។

គោលការណ៍ជាសារវន្តនៃនីតិវិធីចំពោះមុខ អ.វ.ត.ក ដែលមានចែងក្នុងវិធាន២១ នៃវិធានផ្ទៃក្នុងតម្រូវថា ត្រូវបកស្រាយច្បាប់ក្នុងន័យការពារជានិច្ចដល់ផលប្រយោជន៍របស់ភាគីពាក់ព័ន្ធទាំងអស់ថាត្រូវប្រុងប្រយ័ត្នដើម្បីរក្សាឱ្យបានតុល្យភាពរវាងសិទ្ធិភាគីទាំងឡាយ។

[១២:១២:២៤]

សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីយល់ច្បាស់ថា ការបកស្រាយរបស់អង្គបុរេជំនុំជម្រះមិនចងកាតព្វកិច្ចដល់អង្គជំនុំជម្រះសាលាដំបូងនោះទេ។ ក៏ប៉ុន្តែ សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីសង្ឃឹមថា អង្គជំនុំជម្រះសាលាដំបូង នឹងបកស្រាយវិធានអាជ្ញាយុកាល ដែលជាគោលការណ៍សារវន្តនៃនីតិវិធី អ.វ.ត.ក ក្នុងគោលដៅមួយដើម្បីធានាការពារជានិច្ចដល់ផលប្រយោជន៍របស់ភាគីពាក់ព័ន្ធទាំងអស់និងរក្សាឱ្យបានតុល្យភាពរវាងសិទ្ធិរបស់ភាគីទាំងឡាយ។

អាស្រ័យហេតុនេះ សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីសូមស្នើដល់ជូនលោកចៅក្រមជាតិនិងអន្តរជាតិមេត្តាពិចារណាថា ការពន្យារអាជ្ញាយុកាល និងការព្យួរអាជ្ញាយុកាលពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៩៣ មានលក្ខណៈត្រឹមត្រូវ និងធានាសិទ្ធិទទួលបានយុត្តិធម៌ សិទ្ធិទទួលបានការពិត សិទ្ធិទទួលបានសំណង ស្របតាមគោលការណ៍នៃរឿងក្តីប្រកបដោយសមធម៌ ដែលនាំទៅរកការផ្សះផ្សាជាតិ និងសះជាផ្លូវចិត្តរបស់ជនរងគ្រោះចំពោះឧក្រិដ្ឋកម្ម ដែលបង្កឡើងដោយកម្ពុជាប្រជាធិបតេយ្យ។

[១២:១៣:៤៦]

ជាចុងក្រោយ ក្នុងនាមដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ ក៏ដូចជាជនរងគ្រោះនៃរបបកម្ពុជាប្រជាធិបតេយ្យផ្សេងទៀត មេធាវីដើមបណ្តឹងរដ្ឋប្បវេណី សូមស្នើលោកចៅក្រមជាតិ និងអន្តរជាតិ

មេត្តាបដិសេធចោលនូវអំណះអំណាងដែលលើកឡើងដោយមេធាវីការពារក្តីពាក់ព័ន្ធទៅនឹងអញ្ញត្រកម្មស្តីអំពីអាជ្ញាយុកាលបទល្មើសជាតិក្នុងក្រមព្រហ្មទណ្ឌក្នុងឆ្នាំ១៩៥៦។

សូមអរគុណ។

[១២:១៤:២០]

**ប្រធានអង្គជំនុំ៖**

សូមអរគុណលោកមេធាវី។

ឥឡូវនេះដល់ម៉ោងសមល្មមនឹងសម្រាកដើម្បីពិសាអាហារថ្ងៃត្រង់ហើយ។ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់បី និងសាមសិបនាទី ដើម្បីពិសាអាហារថ្ងៃត្រង់ ហើយសូមអញ្ជើញភាគី ព្រះតេជគុណគ្រប់ព្រះអង្គ និងសាធារណជនទាំងអស់អញ្ជើញចូលរួមនៅក្នុងកិច្ចដំណើរការនៅរសៀលនេះឲ្យបានមុនម៉ោងកំណត់។

អនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទពីររូប លោក ខៀវ សំផន និងលោកស្រី អៀង ធីរិទ្ធ ទៅកាន់បន្ទប់រង់ចាំ ហើយឲ្យនាំគាត់ត្រឡប់មកកាន់សាលសវនាការនេះវិញនៅរសៀលនេះឲ្យបានមុនម៉ោងដប់បី និងសាមសិបនាទី។

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១២:១៥ នាទី ដល់ម៉ោង ១៣:៣៨ នាទី)*

[១៣:៣៨:០៦]

**ប្រធានអង្គជំនុំ៖**

សូមព្រះតេជគុណគ្រប់ព្រះអង្គនិមន្តគង់ ហើយនិងអស់លោក លោកស្រីអង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការបឋមតទៅទៀត។ ហើយកាលពីមុនពេលអាហារថ្ងៃត្រង់ គឺយើងបានដល់ដំណាក់កាលនៃសេចក្តីថ្លែងការណ៍តបរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដែលបានចាត់តាំងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីចំនួនបួនរូបដើម្បីធ្វើការឆ្លើយតប។ ហើយកាលពីព្រឹកមិញ អង្គជំនុំជម្រះបានស្តាប់នូវសេចក្តីថ្លែងការណ៍តបរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីចំនួនពីររូបរួចហើយ។ ហើយនៅរសៀលនេះនឹងបន្តនីតិវិធីទៅទៀត ប៉ុន្តែដោយសារ ដោយមានហេតុផលមួយចំនួន។ ដូច្នេះអង្គជំនុំជម្រះមុននឹងផ្តល់វេទិកាទៅឲ្យ

មេធាវីបន្តការងាររបស់ខ្លួន អង្គជំនុំជម្រះសូមជម្រាបដល់មេធាវីទាំងអស់បានជ្រាបថា មេធាវីដែលតំណាងឲ្យភាគីត្រូវឡើងនិយាយករណីណាមួយលើសពីម្នាក់ ដូចមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីក្រុមរួមជាដើម។ មេធាវីត្រូវធានាថា សេចក្ដីថ្លែងការណ៍របស់មេធាវីមិនច្រំដែល។

[១៣:៣៩:៤៣]

ដូច្នេះដើម្បីកាត់បន្ថយនូវភាពច្រំដែល ត្រូវកំណត់ចំនួនមេធាវីដើម្បីនិយាយលើប្រធានបទមួយមិនឲ្យលើសពីពីរនាក់ឡើយ។ អង្គជំនុំជម្រះសាលាដំបូងសូមជម្រាបដល់មេធាវីទាំងអស់ សូមឲ្យគោរពនូវតាមការណែនាំនេះ។

ជាកិច្ចបន្តសូមអញ្ជើញមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីបន្តទៀត។ ប៉ុន្តែបានស្ដាប់ហើយអំមិញ គឺធ្វើយ៉ាងណាចៀសអំពីការលើកឡើងនូវអ្វីដែលមានលក្ខណៈច្រំដែល ទៅនឹងសារណាលាយលក្ខណ៍អក្សរ ឬក៏ច្រំដែលទៅនឹងមេធាវីពីររូប ដែលបានលើករួចហើយកាលពីព្រឹកមិញ។

សូមអញ្ជើញ!

[១៣:៤០:៣៧]

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

ខ្ញុំសូមកត់បំភ្លឺមួយ ពីព្រោះថាខ្ញុំមិនច្បាស់ថា ពាក្យសម្ដីរបស់លោកចៅក្រមនោះ ត្រូវបានគេបកប្រែនោះទេ លោកប្រធាន។ ចៅក្រមមានការព្រួយបារម្ភលើការ-- ធ្វើសេចក្ដីថ្លែងការណ៍មួយចំនួននោះ គឺថាមានភាពច្រំដែល។ ជាពិសេស គឺថានៅពេលដែលមេធាវីច្រើននោះ ឡើងមកធ្វើអន្តរាគមន៍លើប្រធានបទតែមួយ។

[១៣:៤១:០៦]

ដូច្នេះ ដើម្បីចៀសវាងការច្រំដែលៗនេះ គឺថា សូមកុំឲ្យមានលើសមេធាវីជាពីរនាក់ឡើងទៅដែលធ្វើអន្តរាគមន៍នេះ គឺថាដោយសារយើងចង់ឲ្យមានប្រសិទ្ធភាព។ ដូច្នេះយើងសូមឲ្យមេធាវី ក៏ដូចជាភាគីទាំងអស់នោះ សូមឲ្យគោរពសេចក្ដីណែនាំនេះ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញមេធាវី!

[១៣:៤១:០០]

**លោកស្រី ជេត វណ្ណលី៖**

សូមគោរពលោក លោកស្រី ចៅក្រមជាតិ និងអន្តរជាតិនៃអង្គជំនុំជម្រះសាលាដំបូងជាទីគោរព។ សូមគោរពអង្គសវនាការទាំងមូល។ នាងខ្ញុំឈ្មោះ ជេត វណ្ណលី ជាមេធាវីដើមបណ្តឹងរដ្ឋប្បវេណី សូមអនុញ្ញាតថ្លែងនូវការគាំទ្រចំពោះទឡ្ហីករណ៍របស់សហព្រះរាជអាជ្ញា ប្រឆាំងនឹងជនជាប់ចោទដែលថា៖ ប្រព័ន្ធតុលាការមួយអាចចាត់ទុកថាមានសមធម៌ គឺនៅពាក់កណ្តាលទសវត្សរ៍ឆ្នាំ ១៩៩០។ មួយ សង្គ្រាមស៊ីវិលកម្ពុជា ជាឧបសគ្គនៃការកាត់ទោសជនល្មើសក្នុងតុលាការមួយដោយយុត្តិធម៌។ ពីរ ការរារាំងរបស់ជនជាប់ចោទ ក្នុងការកាត់សេចក្តីលើពួកគេ។ និងបួន អានុភាពនៃមាត្រា ៣ របស់ច្បាប់ស្តីពី អ.វ.ត.ក។

[១៣:៤២:៣០]

នាងខ្ញុំសូមលើកឡើងបំភ្លឺបីចំណុច ដែលជាជំហររបស់នាងខ្ញុំ ក្នុងនាមជាមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ពាក់ព័ន្ធនឹងការផុតរលត់នៃបណ្តឹងអាជ្ញា គឺ៖

មួយ សមភាពចំពោះមុខច្បាប់។ បើផ្អែកឡើងតាមការលើកឡើងរបស់ភាគីការពារក្តី ពិតជាមានបំណងឲ្យជនល្មើសរួចផុតពីអាជ្ញាយុកាលនៃបទល្មើស ដែលខ្លួនបានប្រព្រឹត្ត។ នេះបើយោងតាមបទប្បញ្ញត្តិនៃក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦។ ប៉ុន្តែតើពិតជាមានយុត្តិធម៌ពិតប្រាកដទេ បើអំពើល្មើសនោះមិនមានអ្នកទទួលខុសត្រូវ? បើជនរងគ្រោះមិនទទួលបានសមភាពដូចជាអ្វីដែលច្បាប់បានប្រកាសទទួលស្គាល់ថា បុគ្គលគ្រប់រូប កើតមកមានសិទ្ធិសេរីភាព និងស្មើភាពគ្នាចំពោះមុខច្បាប់។ សមភាពនៅទីនេះ សំដៅដល់សិទ្ធិទទួលបានការប្រព្រឹត្តដូចៗគ្នាចំពោះមុខច្បាប់ ទាំងច្បាប់រដ្ឋធម្មនុញ្ញ និងទាំងច្បាប់អន្តរជាតិ។

[១៣:៤៣:៣៣]

តែនេះជនរងគ្រោះមិនទាន់ទទួលបានសមភាពនោះឡើយ ទាំងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ទាំងក្នុងពេលបច្ចុប្បន្ន។ ច្បាប់របស់ អ.វ.ត.ក ត្រូវតែបានឆ្លើយតបនឹងការឈឺចាប់របស់ជនរងគ្រោះ នៃសង្គមកម្ពុជាទាំងមូល ដែលទន្ទឹងរង់ចាំយ៉ាងស្ងប់ស្ងៀម ហើយសង្ឃឹមថាថ្ងៃណាមួយ អ្នកប្រព្រឹត្តឧក្រិដ្ឋកម្មនេះ នឹងត្រូវទទួលការកាត់ទោសយ៉ាងស័ក្តិសមបំផុត។

អង្គជំនុំជម្រះជាទីគោរព! នាងខ្ញុំសូមលើកឡើងនូវវិសមភាពនៃប្រព្រឹត្តកម្ម ដែលជនជាប់ចោទបានទទួលខុសត្រូវលើជនរងគ្រោះ ក្នុងពេលដែលខ្លួនកំពុងកាន់អំណាច។ គ្មានប្រជាជនខ្មែរណាម្នាក់

ដែលមិនបាត់បង់សាច់ញាតិជាទីស្រឡាញ់របស់ខ្លួន ក្នុងរបបកម្ពុជាប្រជាធិបតេយ្យនេះទេ។ ក្រោយរបបនេះដួលរលំទៅ ជនរងគ្រោះតែងប្រកាន់ភ្ជាប់នូវទស្សនៈ"ពៀររំងាប់ដោយការមិនចង់ពៀរ"។

[១៣:៤៤:៣៥]

ជាទិសកំណត់នៃការអត់ភាពធ្មត់ ការតាំងចិត្តជំនួសការគុំកួន ការចងពៀរ និងការសងសឹក។ ព្យសនកម្មដែលប្រជាជនខ្មែររាប់លាននាក់ ក្នុងនោះមានជនរងគ្រោះរបស់យើងខ្ញុំ បានទទួលរងការកាប់សម្លាប់ ទារុណកម្ម ខ្នោះឃ្នាង គុកច្រវាក់ ការធ្វើបាបព្រៃផ្សៃ គ្មានអាណិតអាសូរ។ ជាចំណុចអង្គហេតុដ៏ក្តៅគគុកក្នុងការផ្តល់សក្ខីកម្មដល់តុលាការ។ ទោះបីអត្ថិភាពរបស់ជនរងគ្រោះដែលតុលាការ អ.វ.ត.ក ទទួលស្គាល់ជាដើមបណ្តឹងរដ្ឋប្បវេណី មិនបានឆ្លើយតបនឹងសមាមាត្រនៃចំនួនជនរងគ្រោះទាំងអស់ក៏ដោយ។ តើប្រជាជនខ្មែរណាមួយមិនឈឺចាប់ ហើយទន្ទឹមរង់ចាំថ្ងៃសវនាការនេះ? ព្រោះគេយល់ថា តុលាការ អ.វ.ត.ក នឹងផ្តល់នូវពន្លឺយុត្តិធម៌ដល់ពួកគេ ក្នុងការប៉ះប៉ូវការខូចខាតផ្លូវចិត្ត ផ្លូវកាយ និងសម្ភារៈដែលគេបានបាត់បង់អស់ទៅកាលពី៣០ឆ្នាំមុន។ សួរថា ហេតុអីក៏គេមិនយកជនជាប់ចោទទាំងបួននាក់ យកមកកាត់ទោសនៅក្នុងពេលដែលពួកគេនៅកាន់អំណាច? ចម្លើយ៖ គ្រប់ៗគ្នាអាចយល់បានថា ពួកគេពិតជាមិនឲ្យយើងចាប់ខ្លួនពួកគេជាដាច់ខាត។ ដូចជា ករណី សាដាម ហ៊ូសេន។

ចំពោះករណី ហ្គាដាហ្វី ដែល អាយ.ស៊ី.ស៊ី ចេញដីកាចាប់ខ្លួន តើគាត់នឹងព្រមឲ្យចាប់ខ្លួនដោយងាយៗនោះទេ? បទពិសោធន៍នៃតុលាការព្រហ្មទណ្ឌអន្តរជាតិនានា តែងបាននាំយកមកនូវការកាត់ទោស អ្នកទទួលខុសត្រូវខ្ពស់បំផុតនៃឧក្រិដ្ឋកម្មដែលពួកគេប្រព្រឹត្ត ក្រោយពេលដែលពួកគេអស់អំណាច។ នេះក៏ជាអ្វីដែល អ.វ.ត.ក កំពុងតែធ្វើដែរ ហើយការនាំយកជនល្មើសទាំងបួនរូបមកកាត់ទោសនៅពេលនេះ គឺឆ្លើយតបទៅនឹងទស្សនៈនៃសង្គមយុត្តិធម៌មួយដែលថ្លែងថា អ្នកអាចប្រព្រឹត្តបទល្មើសបាន ប៉ុន្តែអ្នកមិនអាចរួចខ្លួនបានឡើយ។

[១៣:៤៦:៤០]

តុលាការជាទីគោរព។ យុត្តិធម៌ និងការទទួលខុសត្រូវរបស់បទល្មើសក៏ជាកត្តាចម្បងដែលជនល្មើសត្រូវតែទទួលខុសត្រូវ។ តាមអត្ថន័យនៃយុត្តិធម៌ដែលសង្គមជាតិ និងអន្តរជាតិចង់បាន តើត្រូវធ្វើឡើងត្រឹមកម្រិតណា? គឺត្រឹមកម្រិតមួយ ដែលគូវិវាទទទួលបាននូវប្រព្រឹត្តកម្មស្មើភាពគ្នា។ ផ្ទុយទៅវិញ អស្ថិរភាពសង្គមកម្ពុជា ក៏ដូចជាអ្វីដែលសហព្រះរាជអាជ្ញាបានលើកឡើង ពិតជាមិនអាចផ្តល់យុត្តិធម៌ដល់ជនជាប់ចោទ និងជនរងគ្រោះបានឡើយ។ យុត្តិធម៌មិនមែនត្រឹមតែជនជាប់ចោទប៉ុណ្ណោះទេ តែក៏

ត្រូវតែមានចំពោះជនរងគ្រោះដែរ។ ហេតុនេះ យុត្តិធម៌សង្គមដែលច្បាប់ព្រហ្មទណ្ឌមួយ អាចផ្តល់ជូនដល់ភាគីដ៏មានប្រសិទ្ធភាពបាន គឺជាការកំណត់ឲ្យបាននូវអ្នកទទួលខុសត្រូវចំពោះបទល្មើស។ នេះជាហេតុផលដែលមាត្រា៣ នៃច្បាប់របស់ អ.វ.ត.ក បានពន្លាតអាជ្ញាយុកាលនៃបទល្មើសជាតិ ក្នុងក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ ដល់ទៅ៣០ឆ្នាំ បន្ថែមលើអាជ្ញាយុកាលមុនដែលមានតែ១០ឆ្នាំ។ ម្យ៉ាងទៀត អានុភាពនៃមាត្រា៣ របស់ អ.វ.ត.ក គឺនៅថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០០១ ក្រុមប្រឹក្សាធម្មនុញ្ញក៏បានបកស្រាយមាត្រា៣ នៃច្បាប់ អ.វ.ត.ក ថាមិនមានអ្វីផ្ទុយនឹងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាទេ។ ហេតុនេះ មាត្រា៣ នៃច្បាប់ អ.វ.ត.ក ដែលពន្យារអាជ្ញាយុកាលលើបទល្មើសនៃការបំពារបំពានក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ៥៦ គឺគ្រាន់តែការសម្រួលផ្នែកនីតិវិធី ដើម្បីផ្តល់អំណាចឲ្យ អ.វ.ត.ក អាចអនុវត្តយុត្តាធិការរបស់ខ្លួនលើបទល្មើស និងជនល្មើសតែប៉ុណ្ណោះ។ វាមិនមានអ្វីប៉ះពាល់ដល់សារធាតុនៃច្បាប់ព្រហ្មទណ្ឌកម្ពុជាឡើយ។

[១៣:៤៨:៤០]

ម្យ៉ាងទៀត ការអនុវត្តមាត្រា៣ នៃច្បាប់របស់ អ.វ.ត.ក គឺជាការចូលរួមចំណែកក្នុងការធ្វើឲ្យមានការរីកចម្រើន ដល់ការទទួលខុសត្រូវព្រហ្មទណ្ឌជាតិ និងអន្តរជាតិ។ ជាពិសេស ការនាំយកអ្នកទទួលខុសត្រូវខ្ពស់បំផុត ចំពោះឧក្រិដ្ឋកម្មក្នុងរបបកម្ពុជាប្រជាធិបតេយ្យមកកាត់ទោស គឺជាការរួមចំណែកមិនអាចខ្វះបានរបស់ អ.វ.ត.ក ក្នុងការធ្វើឲ្យច្បាប់ព្រហ្មទណ្ឌជាតិ និងអន្តរជាតិ វិវឌ្ឍន៍និងរីកចម្រើន។ កាលបើ អ.វ.ត.ក យកចិត្តទុកដាក់លើអ្នកទទួលខុសត្រូវព្រហ្មទណ្ឌជាជាងយកចិត្តទុកដាក់លើអាជ្ញាយុកាលនៃបទល្មើសនានា។ នេះមានន័យថា វាគឺជាតុល្យភាព ចំពោះមុខច្បាប់ រវាងភាគីជនជាប់ចោទ និងជនរងគ្រោះ។

[១៣:៤៩:៣០]

ផ្ទុយទៅវិញ បើមានជនជាប់ចោទ ដោយហេតុផលផុតអាជ្ញាយុកាលនៃបទល្មើស នោះច្បាស់ជាមិនមានភាគីទទួលខុសត្រូវឡើយ ហើយសមភាពនៅតែជាទ្រឹស្តីមិនអាចអនុវត្តបាន។

សរុបមក ការអនុញ្ញាតឲ្យមានការផុតរលត់អាជ្ញាយុកាលនៃបទល្មើសព្រហ្មទណ្ឌកម្ពុជា មិនអាចនាំមកយុត្តិធម៌ដល់ជនរងគ្រោះបានឡើយ។ បទល្មើសមិនអាចគ្មានអ្នកទទួលខុសត្រូវបានជាដាច់ខាត។

ហេតុនេះការនាំយកជនជាប់ចោទ ដែលទទួលខុសត្រូវខ្ពស់បំផុតមកកាត់ទោសនេះជាហេតុផល

ដ៏យុត្តិធម៌បំផុតសម្រាប់សង្គមដែលមាននីតិរដ្ឋ និងជាការផ្សះរបួសផ្លូវចិត្តរបស់ជនរងគ្រោះ ដែលឈឺចាប់ និងរងការខូចខាត។ សូមអរគុណ។

[១៣:៥០:២០]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោក ពេជ អង្គ!

**លោក ពេជ អង្គ៖**

សូមគោរពលោកចៅក្រមប្រធាន សូមអង្គសវនាការ សូមថ្វាយបង្គំព្រះអង្គដែលមានវត្តមាន និងព្រះវត្តមាននៅពេលនេះ។ ខ្ញុំបាទ ពេជ អង្គ ជាមេធាវីជាតិនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី សូមធ្វើការឆ្លើយតបខ្លីប្រហែលជាប្រាំពីរនាទីទេ ទៅនឹងខាងភាគីការពារក្ដី ហើយជាពិសេសឆ្លើយតបទៅនឹងអ្វីដែលលោកមេធាវី ស សូវាន ដែលលោកមានប្រសាសន៍ថា អាជ្ញាយុកាល គឺជាពេលវេលាមួយដែលផុតរយៈពេលនោះ គួរតែទុកឲ្យមិនគួរផ្ដន្ទាទោស ឬក៏ចោទប្រកាន់ ហើយទុកឲ្យគេបំភ្លេចនូវអ្វីដែលកើតឡើង។ ហើយកន្លែងនេះជាការពិត គឺខាងដើមបណ្ដឹងរដ្ឋប្បវេណី សុំមិនឯកភាពជាមួយនឹងអ្វីដែលបានលើកឡើងដោយលោកមេធាវី ស សូវាន ហើយក៏សូមជម្រាបថា អាជ្ញាយុកាលនេះវាមានសារៈសំខាន់ណាស់ ដែលថាត្រូវតែកំណត់នៅក្នុងរយៈពេលមួយវែងសមរម្យ ដើម្បីទុកឲ្យមានការផ្ដន្ទាទោស ដើម្បីកុំឲ្យមាននិទ្ទណ្ឌភាពកើតឡើងជាបន្តទៅទៀត ហើយក៏អាចធ្វើឲ្យស្ងប់ទៅដល់ជនរងគ្រោះ ដែលបានរងគ្រោះដោយសារអ្វីដែលបានកើតឡើងផងដែរ។

[១៣:៥១:៥២]

អាជ្ញាយុកាលនេះជាការពិត បើអាចហួសអាជ្ញាយុកាល ប្រសិនបើមានការខ្ចីខ្ចាតីអាជ្ញាធរមានសមត្ថកិច្ច ក៏ប៉ុន្តែករណីយើងនេះ កន្លងមកដូចខាងព្រះរាជអាជ្ញាបានលើកអ៊ីចឹងគឺ ជាអលទ្ធភាពនៅក្នុងការចោទប្រកាន់។ ដូច្នេះ អាជ្ញាយុកាលប្រសិនបើត្រូវបានបន្លាយពន្យារពេលនេះ គ្មានអ្វីដែលថាគ្មានមូលដ្ឋានត្រឹមត្រូវទេ។ អាជ្ញាយុកាលនេះទៀតសោត ក៏ជាមូលដ្ឋានក្នុងការកំណត់ពីពេលវេលាដែលថា ជនរងគ្រោះកំពុងតែមានការឈឺចាប់ ហើយទុកឱកាសឲ្យតុលាការកាត់ក្ដីចេញពីសាលក្រមឬក៏សាលដីការបស់តុលាការ ដែលអនុញ្ញាតឲ្យប្រជាជនគាត់បានឃើញនូវអ្វីដែលជាការពិត ហើយគាត់បានស្ងប់អារម្មណ៍ទៅវិញ។

អ៊ីចឹងហើយការបន្លាយរយៈពេលនៃអាជ្ញាយុកាលនេះ ជារយៈពេលមួយដែលអាចទទួលយក

បាន។ អាជ្ញាយុកាលនេះទៀតសោត ជាធម្មតានៅក្នុងប្រទេសមួយចំនួនគាត់ទុកឱកាសឲ្យមាន-- អាជ្ញាយុកាលនេះគឺជារយៈពេលមួយដែលថា ប្រសិនបើបុគ្គលហ្នឹងគាត់បានរត់គេចខ្លួនហើយគាត់ពួននៅកន្លែងណាមួយ ហើយគាត់បានស្ងប់ស្ងាត់ មានវិប្បដិសារីនឹងអ្វីដែលគាត់បានធ្វើខុស ហើយប្រសិនបើថា ផុតរយៈពេលអាជ្ញាយុកាលហ្នឹងគេផ្តន្ទាទោសគាត់ទៅ ហាក់ដូចជារឿងហួសហេតុ។

[១៣:៥៣:១៧]

អ៊ីចឹងហើយបានគេចាត់ទុកថា ឲ្យគាត់ហាក់ដូចជាគាត់ថា បានទទួលនូវទណ្ឌកម្មរបស់គាត់ក្នុងរយៈពេលដែលគាត់បានរត់គេចហ្នឹង ហើយដែលគាត់-- យើងគួរតែកុំផ្តន្ទាទោសគាត់ទោសគាត់ទៀត។ អ៊ីចឹងក្នុងរយៈពេលអាជ្ញាយុកាល គឺគេធ្វើក្នុងរយៈពេលនេះ។ ក៏ប៉ុន្តែចំពោះករណីយើងនេះ ពួកគាត់គឺជាមេដឹកនាំគ្មានពីណាគេ មានលទ្ធភាពទៅចាប់គាត់យកមកផ្តន្ទាទោស ហើយក៏គាត់មិនដែលមានវិប្បដិសារីដែរ។ អ៊ីចឹងអាជ្ញាយុកាលគួរតែនៅមានសុពលភាពនៅឡើយ។ ហើយមួយទៀតអាជ្ញាយុកាលនេះ គេគិតគឺសម្រាប់រយៈពេលដែលថា ខ្លាចផុតអាជ្ញាយុកាលហ្នឹងទៅ ភស្តុតាងក៏វាខូចខាត ហើយអ្នកដែលជាសាក្សីក៏បានភ្លេចភ្លាំងទៅ អ៊ីចឹងហួសរយៈពេលអាជ្ញាយុកាលហ្នឹង មិនគួរកាត់ទោសទេ។ ក៏ប៉ុន្តែក្នុងករណីយើងនេះ ភស្តុតាងមានការរក្សាបានច្រើន ហើយជាក់ស្តែងគឺយើងមានភស្តុតាងជាច្រើនសែនទំព័រ ហើយមានសាក្សីជាច្រើន ហើយមានអ្នកប្តឹងដែលមានព័ត៌មានជាច្រើនដែលផ្តល់ជូនតុលាការសម្រាប់កាត់ក្តី ដើម្បីចៀសវាងការភ័ន្តច្រឡំនៅក្នុងតុលាការ។

[១៥:៥៤:២០]

ហើយជាបញ្ចប់ ខ្ញុំសូមធ្វើការកត់សម្គាល់ថា ចំណុចសំខាន់មួយចំនួនគឺថា យុត្តិធម៌សម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីនេះគឺជា អ្វីដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញដែលជាតម្លៃមួយដ៏ខ្ពស់ ហើយដែលត្រូវតែរកឲ្យបាននូវយុត្តិធម៌នេះសម្រាប់អ្នកដែលជាជនរងគ្រោះ។ ហើយជាពិសេសទៀត ក្រុមប្រឹក្សាធម្មនុញ្ញក៏បាននិយាយថា វាមិនមានការផ្ទុយនឹងរដ្ឋធម្មនុញ្ញទេ ហើយកន្លងមកដូចបានជម្រាបអ៊ីចឹងគឺគ្មានលទ្ធភាពពិតប្រាកដ នៅក្នុងការចោទប្រកាន់ជនជាប់ចោទទាំងនោះទេ តាំងពីដើមរហូតមកដល់ពេលឆ្នាំ៩០ជាង ហើយរហូតដល់មានកិច្ចព្រមព្រៀងក៏អត់មានលទ្ធភាពនៅក្នុងចោទប្រកាន់ដែរ។

កន្លែងនេះខ្ញុំសូមមិននិយាយដដែលអំពីអ្វីដែលគេលើកទេ ហើយសូម្បីតែបញ្ហាភស្តុតាងអីផ្សេងៗដូចខ្ញុំបានជម្រាបអម្បាញ់មិញគឺថា គឺសុទ្ធត្រូវតែបានរក្សាបានច្រើន។ អ៊ីចឹងហើយគឺថា អាជ្ញាយុកាលដូចព្រះរាជអាជ្ញាគាត់បានលើកអ៊ីចឹង គឺត្រូវបានព្យួរពិតប្រាកដ ហើយការបន្ថយដោយសារច្បាប់នេះ

ទៀតក៏ឆ្លើយតបទៅនឹងអ្វីដែល ជាចេតនារបស់ប្រជាជាតិខ្មែរ នៅក្នុងការរកឲ្យឃើញថា តើអ្នកណាជាអ្នកទទួលខុសត្រូវពិតប្រាកដនៅក្នុងរបបដែលមានការកាប់សម្លាប់នេះ។

អ៊ីចឹងហើយបានការពន្យារអាជ្ញាយុកាលនេះ--

*(ឧបករណ៍ថតសំឡេងមិនដំណើរការ)*

[១៣:៥៦:០៦]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីបន្តទៀត!

**លោក ពេជ អង្គ៖**

ដូច្នេះការពន្យារអាជ្ញាយុកាលដោយច្បាប់នេះ គឺមានការសមហេតុផលឆ្លើយតបទៅនឹងអ្វីដែលជាតម្រូវការនៅក្នុងកាត់ក្តីនេះពិតប្រាកដ ហើយខ្ញុំសូមសំណូមពរថា អង្គជំនុំជម្រះមានហេតុផលគ្រប់គ្រាន់នៅក្នុងការយកច្បាប់នោះយកមកប្រើប្រាស់ ដោយមិនឲ្យមានការហួសអាជ្ញាយុកាលឡើយ។

សូមអរគុណ។

[១៣:៥៦:៤៥]

**ប្រធានអង្គជំនុំ៖**

សូមអរគុណលោក លោកស្រីមេធាវី។ ហើយជាកិច្ចបន្ត អង្គជំនុំជម្រះផ្តល់វេទិកាទៅមេធាវីការពារក្តី ដើម្បីមានឱកាសក្នុងការឆ្លើយតបចុងក្រោយ ទៅនឹងសេចក្តីថ្លែងការណ៍របស់សហព្រះរាជអាជ្ញា និងមេធាវី។

**លោក ម៉ៃខល កាណាវាស៖**

សូមជម្រាបសួរលោក លោកស្រីចៅក្រមជាទីគោរព និងសាធារណជន ហើយនិងព្រះថេរានុថេរៈ។ ខ្ញុំមានការឆ្លើយតបទៅវិញ ដោយសារថាមានទឡ្ហីករណ៍ផ្សេងៗជាច្រើន គឺថាទឡ្ហីករណ៍ខ្លះបានច្រំដែលត្រួតលើគ្នា ហើយខ្ញុំមិនផ្តល់ការឆ្លើយតបជារួមនោះទេ ប៉ុន្តែខ្ញុំនឹងឆ្លើយតបទៅលើចំណុចជាក់លាក់មួយៗ ដែលបានលើកឡើងនោះឯង។

[១៣:៥៧:៤៤]

ចំណុចទីមួយ ខ្ញុំសូមចាប់ផ្តើមដោយលើកឡើងនូវចំណុចមួយចំនួន ដែលជាទឡ្ហីករណ៍មួយចំនួនដែលយើងបានឮពីមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដែលយើងឃើញថា យើងយល់ថានេះជា

តុលាការពិសេសបង្កើតឡើងដោយច្បាប់ពិសេស។ យើងក៏ឯកភាពគ្នាដែរថា ភាពយុត្តិធម៌សម្រាប់ទាំងអស់គ្នា ហើយច្បាប់គប្បីតែបានបកស្រាយ ដើម្បីធានាថាភាគីទាំងអស់ទទួលបានផលស្មើគ្នានៅក្រោមច្បាប់ ហើយយើងក៏ទទួលស្គាល់គោលការណ៍នេះ ចំពោះភាគីមួយចំនួនវាមានសិទ្ធិខុសៗ ប៉ុន្តែគប្បីតែមានការការពារស្មើៗគ្នាចំពោះមុខច្បាប់។

[១៣:៥៨:៣៤]

យើងមិនឯកភាពចំពោះគំនិតដែលថា ជនរងគ្រោះ ហើយនិងដើមបណ្តឹងរដ្ឋប្បវេណីថា ត្រូវទទួលបានផល ដោយហេតុតែ ប្រសិនបើច្បាប់អនុវត្តទៅប្រឆាំងនឹងពួកគេ ពេលនោះមិនមានសំណាងហើយមិនមានយុត្តិធម៌ចំពោះពួកគេទេ។ យើងមិនបានលើកឡើងថា គេមិនមានទទួលអត្ថប្រយោជន៍នោះទេ យើងគ្រាន់តែនិយាយថា មិនមានហេតុផលអ្វីដើម្បីនឹងមានការព្រួយបារម្ភ ប៉ុន្តែអ្វីដែលយើងនិយាយនេះ ក្នុងឋានៈជាជនរងគ្រោះនោះ មិនមែនជាមូលហេតុមួយដែលថា មិនត្រូវយកច្បាប់មកអនុវត្តទេ មិនថាលទ្ធផលនោះវាមានលក្ខណៈយ៉ាងណានោះទេ។ អ្វីដែលយើងនិយាយនៅទីនេះថ្ងៃនេះ ហើយពីរថ្ងៃកន្លងមកនោះ ហើយនឹងអាចពីរថ្ងៃទៅខាងមុខទៀតនោះ យើងនឹងស្វែងរកមធ្យោបាយណាមួយនៅក្នុងច្បាប់ដែលមាន ហើយដែលត្រូវយកមកអនុវត្តចំពោះតុលាការនេះ។ ពីព្រោះនេះជាតុលាការពិសេស ដែលបង្កើតដោយតុលាការពិសេស។ នេះហើយអ្វីដែលយើងកំពុងធ្វើ យើងធ្វើការងាររបស់យើងដើម្បីធានាថា តើច្បាប់មានអត្ថន័យយ៉ាងដូចម្តេចមុននឹងយើងដំណើរការទៅមុខទៀត ដើម្បីកុំឲ្យមានការបដិសេធទៅលើសិទ្ធិរបស់បុគ្គលណាម្នាក់។ នេះហើយជាមធ្យោបាយដែលច្បាប់ដែលត្រូវអនុវត្ត ដែលថាភាគីគ្រប់គ្នាបានយល់ពីមូលហេតុហ្នឹង ហើយយើងជាមេធាវីការពារលោក អៀង សារី ហើយយើងបានទទួលនូវសារណាជាលាយលក្ខណ៍អក្សរយ៉ាងច្រើន។ មិនមែនគោលបំណងដែលថារំខានដល់ ជាយុទ្ធសាស្ត្ររំខាននោះទេ គឺថាដើមបណ្តឹងរដ្ឋប្បវេណីពីម្សិលមិញ ឬក៏ពីម្សិលម៉្ងៃនោះ គឺបានលើកឡើងថា “យើងចង់រំខាន” ប៉ុន្តែមិនមែនទេ។

[១៤:០០:៣៣]

ចំណុចមួយដែលយើងចង់លើកឡើងនោះ គឺថាមូលហេតុមួយក្នុងចំណោមមូលហេតុទាំងនោះ ឬក៏យុត្តិកម្ម ដែលខ្ញុំអាចនិយាយថាជាយុត្តិកម្មនោះ។ អ្វីដែលបានបង្ហាញឡើងដោយសហព្រះរាជអាជ្ញា និងតំណាងដើមបណ្តឹងរដ្ឋប្បវេណី ថាប្រព័ន្ធតុលាការនៃកាលនោះមិនមានដំណើរការនោះ ហើយគាត់បានជូនជាឧទាហរណ៍ជាមូលហេតុមួយចំនួន ដូចជាកម្ពុជាប្រជាធិបតេយ្យបានបំផ្លាញប្រព័ន្ធតុលាការ

ហើយនិងបំផ្លាញចៅក្រម បន្ទាប់ពី១៩៩៩-- ៧៩នោះ គឺថាមានតែក្រឹត្យច្បាប់ ហើយអ្នកធ្វើសេចក្តីព្រាងច្បាប់សុទ្ធតែអ្នកគ្រូបង្រៀន អត់មានអ្នកអាជីព មិនមានសិទ្ធិទទួលមេធាវី មិនមានសិទ្ធិប្តឹងឧទ្ធរណ៍ រហូតទាល់តែឆ្នាំ៨៥ មិនមានគណៈមេធាវី...។ល។

[១៤:០១:៣៤]

ព័ត៌មានទាំងអស់នេះ គឺយើងទទួលបានទាំងអស់ ហើយខ្ញុំយល់ឃើញថា វាមានលក្ខណៈស្រដៀងនឹងអ្វីដែលយើងខ្ញុំបានលើកឡើង។ នេះគឺជាអ្វីដែលមានលើកឡើងនៅក្នុងសារណារបស់ភាគីដែលគាត់លើកឡើងដូច្នោះ។ ប៉ុន្តែវាជាគ្រោះថ្នាក់ប្រសិនបើលើកឡើងដូច្នោះ ជាពិសេសសម្រាប់សហព្រះរាជអាជ្ញាដែលបានលើកឡើងថា "ក្នុងនាមលោក លោកស្រីជាចៅក្រម ត្រូវតែពិចារណានៅពេលនុំងថាតើបទពិសោធន៍យ៉ាងម៉េច?"។ វាមិនសមស្របទេ ប្រសិនបើលើកឡើងដូច្នេះ។ ហេតុអ្វីបានជាខ្ញុំលើកឡើងដូច្នេះ វាមិនសមស្របដោយសារតែយើងត្រូវតែសម្រេចរឿងក្តីនេះដោយផ្អែកទៅលើភស្តុតាង គឺភស្តុតាងទាំងឡាយមកពីសាក្សី ឯកសារទាំងឡាយដែលទទួលស្គាល់។

លោក លោកស្រីចៅក្រមប្រហែលជាមានបទពិសោធន៍ និងចំណេះដឹងពិចារណាទៅលើចំណុចនេះ។ ដូច្នេះ មិនមានភាគីណាមួយបង្គាប់ឲ្យចៅក្រមសម្រេចនោះទេ។ ដូច្នេះ ភាគីអាចបង្ហាញអំពីអង្គហេតុ គំនិតយោបល់តែប៉ុណ្ណោះ។ ហើយមតិយោបល់ ព័ត៌មានទាំងអស់នោះ គឺយកមកដេញដោល។

[១៤:០២:៤៥]

ខ្ញុំមិនមែនស្នើថាឲ្យចៅក្រមជាអ្នកដេញដោលនោះទេ។ មិនមែន យើងមិនអាចនិយាយថា លោក លោកស្រីចៅក្រមដឹងអស់ហើយ គឺអាចសម្រេចតែម្តងដោយមិនចាំបាច់ពិចារណាទៅលើអ្វីទៀតទេ។

ទាំងអស់នោះគឺជាអង្គហេតុ។ ខ្ញុំមកប្រទេសកម្ពុជាក្នុងឆ្នាំ៩២-- ៩៤, ៩៥, ៩៦ ខ្ញុំមកទីនេះដើម្បីចូលរួមវគ្គបណ្តុះបណ្តាលមេធាវី។ ខ្ញុំជួបជាមួយនឹងចៅក្រម មេធាវី និងធ្វើការបណ្តុះបណ្តាល។ ប៉ុន្តែវាមិនមែនជាសិទ្ធិ ខ្ញុំមិនមានសិទ្ធិក្នុងការផ្តល់ភស្តុតាងនោះទេ ដោយសារតែតុលាការនេះ គឺមានប្រព័ន្ធច្បាប់ មានតុលាការដែលតម្រូវឲ្យមានសាក្សីទៅតាមការចាត់តាំង។

ដូច្នេះផ្អែកទៅតាមបទពិសោធន៍របស់លោក លោកស្រីចៅក្រម គឺលោក លោកស្រីចៅក្រមត្រូវពិចារណារឿងក្តីនេះដោយផ្អែកទៅលើភស្តុតាង។

[១៤:០៣:៤៤]

ក្រឹត្យច្បាប់លើកទីមួយ នៅក្នុងរឿងក្ដីរបស់យើងខ្ញុំនេះ គឺក្រឹត្យច្បាប់លេខមួយ ដែលបង្កើតសាលាក្ដីធ្វើការកាត់ទោសលោក ប៉ុល ពត និងអៀង សារី។ យើងនិយាយបញ្ហាហ្នឹងកាលពីម្សិលមិញ ខ្ញុំមិននិយាយផ្ដោតឡើងវិញម្ដងទៀតនោះទេ។ រយៈពេលក្រោយមក យើងនឹងឃើញនៅក្នុងរបាយ-ការណ៍ ហើយយើងបានបង្ហាញរបាយការណ៍នេះជូនតុលាការរួចហើយ។ ក្នុងរយៈកាលបន្ទាប់មក យើងឃើញមានការជំនុំជម្រះកើតឡើង។ សហព្រះរាជអាជ្ញា និងភាគី បានលើកឡើងទទ្បីករណ៍នានា ដែលថាវាមានភាពបត់បែននៅពេលនោះ ហើយមិនមានប្រព័ន្ធតុលាការដំណើរការនោះឡើយនៅក្នុងប្រទេសកម្ពុជា។ គេអាចនិយាយថាវិធាននៃច្បាប់ គឺអាចអនុវត្តពីឆ្នាំ១៩៨១, ៨២ និង៨៦ តែប៉ុណ្ណោះ។ ក្រោយមកនៅក្នុងឆ្នាំ១៩៨៦ គឺយើងមានប្រព័ន្ធតុលាការ ក្រៅពីនោះយើងអត់មានទេ ដោយសារតែសង្គ្រាម។

[១៤:០៤:៥២]

កាលពីម្សិលមិញ យើងបានលើកឡើងឯកសារមួយ ដែលសហព្រះរាជអាជ្ញាបានលើកឡើង ដែលសហព្រះរាជអាជ្ញាព្យាយាមបង្ហាញចំណុចមួយបំភ្លឺទៅលើករណីនេះ។ គាត់បានលើកឡើងអំពីក្រឹត្យច្បាប់លេខ២៨ គឺក្រុមប្រឹក្សារដ្ឋរបស់កម្ពុជា យើងបាននិយាយកាលពីម្សិលមិញអំពីការលើកលែងទោស និងការអនុគ្រោះទោស និងភាពខុសគ្នា។

សហព្រះរាជអាជ្ញាលើកឡើងក្រឹត្យ២៨ ហើយបាន-- ក្រឹត្យ២៨ នេះដាក់ជូនកាលពីថ្ងៃសុក្រ។ ហើយសហព្រះរាជអាជ្ញា បានបង្ហាញថា លោក លោកស្រីចៅក្រម គួរតែធ្វើការបកស្រាយពាក្យនៅក្នុងនោះថាតើវាមានន័យយ៉ាងម៉េច?

[១៤:០៥:៣៤]

ហើយសហព្រះរាជអាជ្ញាលើកឡើងថា នៅពេលនោះមិនមានប្រព័ន្ធតុលាការ ដូច្នេះគឺថាគាត់ហាក់ដូចជានិយាយជាន់គ្នា ហើយដោយផ្អែកទៅលើឯកសារមួយនេះ។ នៅក្នុងឆ្នាំ១៩៨៨ គាត់ថានេះជាក្រឹត្យច្បាប់មួយដែលយើងគួរតែទទួលស្គាល់។

សហព្រះរាជអាជ្ញា និងដើមបណ្ដឹងរដ្ឋប្បវេណី មិនបានបង្ហាញភស្តុតាងណាគួរឲ្យជឿជាក់ ដែលបង្ហាញថាមិនមានប្រព័ន្ធតុលាការណាមួយកើតឡើងនៅពេលនោះឡើយ។ យើងខ្ញុំសូមលើកឡើងថា ការលើកឡើងទាំងអស់នោះគឺជាការលើកឡើងដោយខុស និងដោយច្រឡំ។ ជាការពិតគឺនៅក្នុងប្រទេសកម្ពុជាយើងមានប្រព័ន្ធតុលាការនៅពេលនោះ។ បានន័យថា អំឡុងពេលនោះមកគឺយើងមាន

ប្រព័ន្ធតុលាការរហូតមដល់ឆ្នាំ១៩៨៦។

[១៤:០៦:៣០]

សហព្រះរាជអាជ្ញាបានលើកឡើងហេតុផល ហេតុអ្វីបានជាការលើកលែងទោសវាមានភាពចាំបាច់ ហើយសហព្រះរាជអាជ្ញាបានលើកឡើងអំពីយុទ្ធសាស្ត្ររបស់សម្តេចនាយករដ្ឋមន្ត្រី ដែលជាយុទ្ធសាស្ត្រមួយបានបង្កើតឡើង។ នៅពេលនេះគឺខ្ញុំមិនចង់លើកឡើង នូវការលើកឡើងរបស់សហព្រះរាជអាជ្ញាទាក់ទងទៅនឹងហេតុផល ស្ថានភាពដែលកើតឡើងនៅពេលនោះ ហើយហេតុអ្វីបានជាការលើកលែងទោស និងការអនុគ្រោះទោស វាមានភាពចាំបាច់ត្រូវធ្វើឡើងនៅពេលនោះ។ ដោយសារតែទឡ្ហីករណ៍ទាំងអស់នោះ វាលើកឡើងរួចមកហើយ ថាហេតុអ្វីបានជាចាំបាច់ត្រូវប្រគល់នឹងធ្វើការផ្តល់ជូននូវការលើកលែង និងការអនុគ្រោះទោស។ ដូច្នេះ ខ្ញុំមិនលើកឡើងសាជាថ្មីនោះឡើយ។

[១៤:០៧:២២]

ចំណុចមួយទៀតពាក់ព័ន្ធទៅនឹងប្រព័ន្ធតុលាការ សហព្រះរាជអាជ្ញាលើកឡើងថា ចៅក្រមដែលបំពេញការងារនោះមិនមានភាពអព្យាក្រឹត។ ប៉ុន្តែនៅពេលជាមួយគ្នានោះដែរ នៅក្នុងពេលនោះការជំនុំជម្រះទាំងឡាយ គឺមិនមាននូវការជឿជាក់ឡើយ។ យើងខ្ញុំសូមលើកឡើងថា យើងមានអង្គការសហប្រជាជាតិ និងអង្គការផ្សេងៗដែលធ្វើការរិះគន់កិច្ចការទាំងឡាយរបស់រដ្ឋាភិបាល ដែលកាលពីម្សិលមិញតាមប្រភពព័ត៌មានគឺថា រដ្ឋាភិបាលបានធ្វើការប្រារព្ធខួបលើកទី៦០ នៃគណៈបក្សរបស់ខ្លួន។ យើងមិនមានភស្តុតាងផ្សេងទៀតដែលបង្ហាញទៅលើចំណុចនេះ ហើយវាគ្រាន់ជាការអះអាងប៉ុណ្ណោះ ពីខាងសហព្រះរាជអាជ្ញា។

[១៤:០៨:២២]

ជាការពិតទៅតុលាការនៅពេលនោះ គឺពិតជាមានដំណើរការ ហើយចៅក្រមទាំងអស់នោះពិតជាមានភាពអព្យាក្រឹត។ ចៅក្រមគាត់នឹងមានភាពអព្យាក្រឹត ហើយនិងមានភាពឯករាជ្យ។ ប៉ុន្តែយើងសួរថាតើស្ថានភាពនោះ វាជាស្ថានភាពដែលល្អឥតខ្ចោះ ឬក៏ណា? គឺមិនអាចនោះទេ ហើយប្រសិនបើយើងមើលស្ថានភាពនៅពេលបច្ចុប្បន្នគឺវាដូចតែគ្នានោះទេ គ្មានស្ថានភាពមួយណាល្អឥតខ្ចោះនោះឡើយ។ ថាតើមានឯករាជ្យភាពដែរ ឬទេ? មានការជ្រៀតជ្រែកដែរឬទេ? គឺយើងគិតឃើញថានៅតែមាន។

សហព្រះរាជអាជ្ញាបានបង្ហាញថា ក្រមឆ្នាំ១៩៥៦ មិនអាចអនុវត្តបានទេនៅពេលនោះ ហើយសហព្រះរាជអាជ្ញាបានបង្ហាញហេតុផលរបស់គាត់។ ខ្ញុំសូមឆ្លើយតបដូចតទៅះ

យើងខ្ញុំសូមលើកឡើងថា ក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ នៅតែមានសុពលភាពដោយសារតែមិនមានច្បាប់ណាមួយនិរាករណ៍ឡើយនៅពេលនោះ។ ដូច្នេះ ប្រសិនបើយើងគិតថាច្បាប់នោះវាអនុវត្តក្រោយឆ្នាំ១៩៧៩ នោះ ច្បាប់ដែលយើងត្រូវតែអនុវត្ត យើងក៏ឯកភាពគ្នាផងដែរ។ ច្បាប់ដែលត្រូវអនុវត្តនោះគឺច្បាប់ទាំងឡាយណាដែលចែងអំពីបទល្មើសដែលកើតឡើង។ ជាពិសេសគឺយើងត្រូវពិចារណាទៅលើច្បាប់ អ.វ.ត.ក របស់យើងផងដែរ ដែលចំណុចមួយចំនួនយើងបានតវ៉ា។

[១៤:០៩:៥៨]

សេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញបានពិចារណាថា តើការពន្យារអាជ្ញាយុកាលនេះ គឺរួមទាំងឆ្នាំ១៩៥៦ នៃក្រមព្រហ្មទណ្ឌដែរឬទេ? ហើយ វាជាការផ្ទុយទៅនឹងរដ្ឋធម្មនុញ្ញដែរឬទេ? យើងដឹងហើយថានៅពេលនោះ វាជាច្បាប់ ហើយសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញគឺជាសេចក្ដីសម្រេចមួយដែលយើងត្រូវពិចារណា។

[១៤:១០:២៤]

ខ្ញុំសូមលើកឡើងអំពីក្រុមប្រឹក្សាធម្មនុញ្ញម្ដង នៅពេលដែលខ្ញុំធ្វើសេចក្ដីថ្លែងបើកនៅក្នុងថ្ងៃនេះ ខ្ញុំបានបង្ហាញថា យើងយល់ឃើញថាសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ គឺមិនត្រឹមត្រូវឡើយ។ ក៏ប៉ុន្តែយើងទទួលស្គាល់ថា អង្គជំនុំជម្រះនេះ និងស្ថាប័ននេះគ្មានអំណាច ណាមួយលើក្រុមប្រឹក្សាធម្មនុញ្ញ ហើយមិនអាចចេញសេចក្ដីសម្រេចទាត់ចោលសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញនោះឡើយ។ យើងត្រូវតែអនុវត្តច្បាប់ឲ្យមានលក្ខណៈសមភាពគ្នា។ ស្ថានភាពរបស់ យើងគឺដូច្នេះនៅក្នុងថ្ងៃនេះ។ សេចក្ដីសម្រេចនោះគឺជាសេចក្ដីសម្រេចយើងមិនអាចជំទាស់គ្នា យើងឯកភាពគ្នាទៅលើចំណុចហ្នឹងទាំងអស់គ្នា។ ដូច្នេះហើយចំណុចនេះគឺថា លោក លោកស្រីចៅក្រមត្រូវ ពិចារណាទៅលើសេចក្ដីសម្រេចនោះឡើងវិញ ដោយមិនពិចារណាសម្រេចទៅលើបញ្ហា ធម្មនុញ្ញភាពនោះឡើងវិញនោះឡើយ។

[១៤:១១:៣៣]

ដូច្នេះនៅពេលនេះអនុញ្ញាតឲ្យខ្ញុំធ្វើការលើកឡើងនូវចំណុចដទៃទៀត ហើយខ្ញុំនឹងមិនចំណាយពេលច្រើននោះទេ។ មាត្រា៣(ថ្មី) នេះគឺជាចំណុចដែលខ្ញុំនឹងលើកឡើង។ នៅក្នុងនោះ គឺគេបានពន្យារអាជ្ញាយុកាលចំពោះមនុស្សឃាត ការធ្វើទារុណកម្ម និងការធ្វើទុក្ខបុកម្នេញទៅតាមក្រមឆ្នាំ១៩៥៦ ដែលជាបទល្មើសចោទប្រកាន់នៅ អ.វ.ត.ក។ ខ្ញុំលើកឡើងថា ការពន្យារអាជ្ញាយុកាលនេះគឺជាការ

រំលោភមាត្រា៣១ នៃរដ្ឋធម្មនុញ្ញ, មាត្រា៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, មាត្រា៧ នៃសេចក្តីប្រកាសសិទ្ធិមនុស្ស, មាត្រា២៦ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ។

យើងខ្ញុំសូមលើកឡើងថា ទោះបីជាខុសឬត្រូវក៏ដោយអស់ លោក លោកស្រីចៅក្រមជាអ្នកពិចារណា។ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញគឺមិនបានពិចារណាទៅលើបញ្ហានេះឡើយ នៅពេលដែលគេពិចារណាថាមាត្រា៣ នោះស្របទៅនឹងរដ្ឋធម្មនុញ្ញ ឬក៏យ៉ាងណានោះ។ ក្រុមប្រឹក្សាធម្មនុញ្ញមានកំហុសនៅពេលមិនបានពិចារណាទៅលើច្បាប់ អ.វ.ត.ក ជាពិសេស ធម្មនុញ្ញភាព ថាតើវាជាការប្រព្រឹត្តមួយសមភាពនៅចំពោះមុខច្បាប់ដែរឬទេ? ដូច្នេះ វាមិនមានន័យថា អ.វ.ត.ក មិនអាចអនុវត្តមាត្រា៣(ថ្មី) នោះឡើយ។ នេះជាចំណុចដែលវាចុចទៅលើទឡ្ហីករណ៍របស់យើងខ្ញុំ។

[១៤:១៣:២២]

ដូច្នេះ ទឡ្ហីករណ៍ទាំងអស់ដែលបានលើកឡើង គឺវាមានលក្ខណៈចង្អៀត ដូច្នេះហើយយើងត្រូវតែធ្វើការពិចារណាទៅលើច្បាប់។ ក្នុងនាមជាតុលាការជាតិ អ.វ.ត.ក ត្រូវតែគោរពសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញថាច្បាប់ អ.វ.ត.ក ស្របនឹងធម្មនុញ្ញ យើងឯកភាពជាមួយនឹងចំណុចហ្នឹង ក៏ប៉ុន្តែ អ.វ.ត.ក ក៏មានកាតព្វកិច្ចគោរព១ច្បាប់ និងបទប្បញ្ញត្តិទាំងឡាយណាជាពិសេសរដ្ឋធម្មនុញ្ញ និងច្បាប់អន្តរជាតិនានា។

ដូច្នេះហើយទើបយើងនៅទីនេះ លើកឡើងទឡ្ហីករណ៍របស់យើងជូនអស់លោក លោក ស្រីចៅក្រម មិនមែនថាយើងបដិសេធសិទ្ធិរបស់ភាគីណាមួយនោះទេ ប៉ុន្តែហេតុផលរបស់យើង គឺដូច្នេះឯង។ មាត្រា៣(ថ្មី) គឺរំលោភសិទ្ធិរបស់លោក អៀង សារី ដែលទទួលបានការប្រព្រឹត្តស្មើគ្នាដោយសារតែលោក អៀង សារី បានចោទប្រកាន់ទៅលើឧក្រិដ្ឋកម្មមួយដែលវាមានលក្ខណៈស្រដៀងគ្នាហើយត្រូវបានកាត់ទោសម្តងរួចទៅហើយក្នុងប្រទេសកម្ពុជា។

[១៤:១៤:៤១]

ដូច្នេះហើយទើបយើងខ្ញុំសូមរក្សាជំហររបស់យើងខ្ញុំថា វាមិនមានការការពារណាមួយសមភាពចំពោះកូនក្តីរបស់ខ្ញុំ។ អង្គបុរេជំនុំជម្រះរកឃើញថា នៅក្នុងកថាខណ្ឌ២៨៩ ដល់ ២៩១ នៃសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ។ ទឡ្ហីករណ៍នោះគឺបានបង្ហាញអំពីការប្រព្រឹត្តស្មើគ្នាចំពោះការតវ៉ា អ.វ.ត.ក គឺកម្រិតយុត្តាធិការពេលវេលារបស់ខ្លួន ហើយ អ.វ.ត.ក ត្រូវសម្រេចថា តើខ្លួនមានយុត្តាធិការកម្រិតដែរឬទេ? ហើយថាតើខ្លួនគោរពទៅតាមការប្រព្រឹត្តដោយស្មើភាពគ្នា

ចំពោះភាគីដែរឬទេ? នេះគឺជាការបកស្រាយរបស់អង្គបុរេជំនុំជម្រះទាក់ទងទៅនឹងទឡ្ហីករណ៍របស់យើង។

អង្គបុរេជំនុំជម្រះៗរកឃើញថាតុលាការវិសាមញ្ញ ឬតុលាការពិសេសមានយុត្តាធិការកម្រិតតាមលក្ខណៈរបស់វា គឺមានសិទ្ធិក្នុងការការពារទៅលើសិទ្ធិសមភាព។ អង្គបុរេជំនុំជម្រះបានពិចារណាថា តើការបង្កើតតុលាការនេះដែលមានយុត្តាធិការពិសេសនេះ គឺជាការរំលោភទៅលើសិទ្ធិសមភាពដែរឬទេ? ខ្ញុំលើកឡើងថា ចំណុចនេះវាមិនពាក់ព័ន្ធ។ យើងខ្ញុំមិនតវ៉ាថា កម្ពុជាមិនអាចបង្កើតតុលាការពិសេសនោះឡើយ ប្រសិនបើយើងគិតថាដូច្នោះមែន។ ខ្ញុំសូមបញ្ជាក់ថាយើងប្រាកដជាដាក់សារណារបស់យើងហើយ ប្រសិនបើខ្ញុំលើកដូច្នោះនោះ។ នេះជាចំណុចមួយដែលខ្ញុំសូមបញ្ជាក់។

[១៤:១៦:៣០]

យើងខ្ញុំសូមបញ្ជាក់ថា តុលាការនេះមិនអាចអនុវត្តច្បាប់សារភាព-- ច្បាប់សារធាតុផ្សេងណាមួយឡើយ ក្រៅពីអ្វីដែលយើងបានលើកឡើង។ អង្គបុរេជំនុំជម្រះលើកឡើងថា អ.វ.ត.ក ត្រូវតែគោរពទៅតាមលក្ខខណ្ឌនៃការជំនុំជម្រះៗដោយយុត្តិធម៌ក្នុងមាត្រា១៤ នៃកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ។ ដោយសារតែការជំនុំជម្រះដោយយុត្តិធម៌បានចែងនៅក្នុងច្បាប់បង្កើត អ.វ.ត.ក និងវិធានផ្ទៃក្នុង។ ជាការពិតយើងទទួលស្គាល់ចំណុចទាំងអស់នេះ។ យើងមិនមែន-- យើងមិនបានតវ៉ាទៅលើចំណុចនេះទេ ការធានាទាំងអស់នេះគឺពិតជាមានចែងនៅក្នុងច្បាប់ អ.វ.ត.ក និងវិធានផ្ទៃក្នុង។ ខ្ញុំលើកឡើងថា សិទ្ធិទាំងអស់នេះវាមាននៅក្នុងវិធានផ្ទៃក្នុង ប៉ុន្តែយើងត្រូវតែពិចារណាតើមានការគោរពសិទ្ធិទាំងអស់នេះដែរឬទេ?

វាហាក់ដូចជាទឡ្ហីករណ៍ថ្មីមួយសម្រាប់អស់លោក លោកស្រី។ ជាថ្មីម្តងទៀត ខ្ញុំសូមបំភ្លឺ និងឆ្លើយតបអង្គជំនុំជម្រះ កុំឱ្យសាធារណជនគាត់យល់ច្រឡំទៅលើការដាក់ឯកសាររបស់យើងខ្ញុំ។ ការដាក់ឯកសាររបស់យើងខ្ញុំ គឺដើម្បីធានាឱ្យអង្គជំនុំជម្រះទទួលបាននូវឯកសារសម្ភារៈគ្រប់គ្រាន់មុនពេលដែលយើងពិចារណាទៅលើភស្តុតាង ជាពិសេសឱ្យយើងយល់ទៅលើច្បាប់។

[១៤:១៨:០០]

ទាំងអស់នេះហើយគឺ ឯកសារទាំងអស់នេះហើយ គឺជាចំណុចដែលយើងចាប់អារម្មណ៍។ យើងខ្ញុំត្រៀមខ្លួនពិនិត្យទៅលើច្បាប់ដែលអនុញ្ញាតឱ្យយើងខ្ញុំដាក់ទៅលើឯកសារទាំងអស់នេះ។ យើងខ្ញុំសង្ឃឹមថាច្បាប់នឹងអនុញ្ញាតឱ្យយើងខ្ញុំដាក់ឯកសារទាំងអស់នេះ ហើយបន្តអនុញ្ញាតឱ្យយើងដាក់ឯកសារ។

យើងមិនមែនព្យាយាមបង្អាក់នីតិវិធីនោះទេ ប៉ុន្តែយើងព្យាយាមពិចារណាថាយើងអាចដាក់ឯកសារដោយសារតែបញ្ហាទាំងអស់នេះវាមានលក្ខណៈស្មុគស្មាញ។

ដូច្នេះហើយខ្ញុំសូមអនុញ្ញាតពីអង្គជំនុំជម្រះធ្វើការឲ្យខ្ញុំបង្ហាញ និងដាក់ជូននូវឯកសារនេះរបស់ខ្ញុំដើម្បីឲ្យយើងយល់ទាំងអស់គ្នា មិនមែនថាខ្ញុំព្យាយាមធ្វើអ្វីដាក់ឯកសារអ្វីដែលថ្មីនោះទេ។

សូមអរគុណ។

[១៤:១៨:៥២]

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវី។ សូមអញ្ជើញលោកមេធាវី ផាត់ ពៅស៊ាង!

**លោក ផាត់ ពៅស៊ាង៖**

សូមគោរពអង្គជំនុំជម្រះ ក្រុមប្រឹក្សាអង្គជំនុំជម្រះសាលាដំបូង សូមគោរពអង្គសវនាការទាំងមូល។ ខ្ញុំបាទឈ្មោះ ផាត់ ពៅស៊ាង ជាមេធាវីជាតិដែលការពារឲ្យអ្នកស្រី អៀង ធីរិទ្ធ សូមអនុញ្ញាតធ្វើការឆ្លើយតបទៅនឹងសេចក្តីថ្លែងការណ៍របស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី និងសហព្រះរាជអាជ្ញាជាតិ និងអន្តរជាតិដែលបានលើកឡើងជុំវិញបញ្ហាប្រធានបទដែលបានពិភាក្សា គឺអាជ្ញាយុកាល។ ជុំវិញបញ្ហានេះគឺថា ខ្ញុំបាទបានកត់សម្គាល់ឃើញថា មេធាវីដើមបណ្តឹងរដ្ឋប្បវេណីបានលើកអំពីយុត្តិធម៌ គឺខ្ញុំសូមអនុញ្ញាតជម្រាបជូនថា យុត្តិធម៌ត្រូវការទាំងសងខាង គឺថាខាងជនរងគ្រោះក៏ត្រូវការយុត្តិធម៌ ខាងជនជាប់ចោទក៏ត្រូវការយុត្តិធម៌។

[១៤:២០:០៦]

បើត្រូវការយុត្តិធម៌ទាំងអស់គ្នាយ៉ាងដូច្នេះ យើងត្រូវយកអ្វីធ្វើជាគោល គឺយើងត្រូវយកច្បាប់។ បើយើងមិនយកច្បាប់មកធ្វើជាគោលទេ យើងចេះតែនិយាយទៅតាមចិត្ត ការលើកឡើងថា អាជ្ញាយុកាលត្រូវផុត១០ឆ្នាំ តាំងពីឆ្នាំ១៩៧៩ រហូតដល់ឆ្នាំ ១៩៩៣ អត់មានច្បាប់ អត់មានបទប្បញ្ញត្តិ អត់មានតុលាការណាមួយអីអ៊ីចឹងទៅ រកយុត្តិធម៌ជូនប្រជាពលរដ្ឋបាននុំង គឺថាអាជ្ញាយុកាលត្រូវពន្យារ។

ខ្ញុំសូមជម្រាបជូនថា បើយើងនិយាយអត់មានមូលដ្ឋានសំអាងអ៊ីចឹង គឺយើងអនុវត្ត ខ- ត ហើយ *ឡាយ អេន ខ្វស* គឺ ខ -ត ថាអីក៏បានដែរ។ ធ្វើអ៊ីចឹងអត់ត្រូវ យើងត្រូវយកគោលមួយជាកម្រិតមួយថា នៅក្នុងក្រមព្រហ្មទណ្ឌនាឆ្នាំ១៩៥៦ បានកំណត់ថា អាជ្ញាយុកាលនៃបទល្មើសឧក្រិដ្ឋ គឺមាន១០ឆ្នាំ។

សួរថាតើបទល្មើសដែលជនជាប់ចោទបានប្រព្រឹត្តហ្នឹង ជាបទល្មើសភ្លាមៗ ឬក៏មួយជាបទ

ល្មើសនិរន្តរ៍? បើជាបទល្មើសនិរន្តរ អាហ្នឹងវាអូសបន្លាយនៅក្នុងកាលមួយរហូតដល់ថ្ងៃណាដែលគេដឹង អាហ្នឹងគេរាប់ពីថ្ងៃដែលដឹង។ ប៉ុន្តែ បទល្មើសនេះ គឺជាបទល្មើសភ្លាមៗ ដូច្នេះរាប់ពីថ្ងៃប្រព្រឹត្ត គឺឆ្នាំ ១៩៧៩ ត្រូវចប់អាជ្ញាយុកាលនៅឆ្នាំ១៩៨៩។

ហើយចំណុចមួយទៀត ដែលហៅថាមេធាវីដើមបណ្តឹងរដ្ឋប្បវេណីបានថា អ.វ.ត.ក គួរតែយកចិត្តទុកដាក់នៅលើ ហៅថា ការទទួលខុសត្រូវជាជាងការគិតដល់អាជ្ញាយុកាល។ ខ្ញុំបាទ សូមអនុញ្ញាតជម្រាបជូនថា បើមិនគិតដល់អាជ្ញាយុកាលហ្នឹងខុសហើយ គឺយើងមិនយកច្បាប់មកអនុវត្ត។

[១៤:២១:៥៣]

ហើយអាជ្ញាយុកាលហ្នឹង គឺថាខាងមេធាវីដើមបណ្តឹងរដ្ឋប្បវេណីលោក ពេជ អង្គ បានឲ្យនិយមន័យរួចហើយ ឆ្លើយតបទៅនឹងអ្វីដែលលោក ស សូវាន បានលើកឡើងហ្នឹង គឺថាជុំវិញបញ្ហាអាជ្ញាយុកាលនេះ យើងបានពិនិត្យមើលថា នៅឆ្នាំ១៩៩២ ពេលហ្នឹង អ៊ុនតាក់ បានចូលស្រុក។ អ៊ុនតាក់ បានចូលស្រុក អ៊ុនតាក់ បានតាក់តែងនូវច្បាប់មួយគេហៅថា "ច្បាប់ព្រហ្មទណ្ឌអន្តរកាល" នៅថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៩២ បើខ្ញុំចាំមិនភ្លេចទេ គឺថាត្រង់មាត្រាចុងក្រោយបានចែងថាម៉េច? ចែងថា បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយជាមួយនឹងច្បាប់នេះត្រូវទុកជានិរាករណ៍។

ដូច្នេះ ច្បាប់ អ៊ុនតាក់ បានបដិសេធនូវក្រមព្រហ្មទណ្ឌអន្តរ-- ក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ចោលហើយថា រាល់បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយជាមួយនឹងបទប្បញ្ញត្តិច្បាប់ អ៊ុនតាក់ នេះត្រូវទុកជានិរាករណ៍ គឺគេបានបដិសេធរួចទៅហើយ។

[១៤:២២:៤៩]

បើច្បាប់ អ៊ុនតាក់ បានបដិសេធរួចទៅហើយ ហេតុអីបានយើងរើយកមកនិយាយជជែកគ្នាទៀត? លុះដល់ឆ្នាំ២០០៤ បានមានច្បាប់ស្តីពីការបង្កើត អ.វ.ត.ក។ ដល់ឆ្នាំ២០០៤ មានច្បាប់ស្តីពីការបង្កើត អ.វ.ត.ក បានពន្យារនូវហៅថា រយៈពេលនៃអាជ្ញាយុកាល៣០ឆ្នាំ។ បានន័យថា រយៈពេលនៃអាជ្ញាយុកាលបានផុតរលត់ទៅហើយ បានមានការពន្យារ។ ខ្ញុំអត់បកស្រាយថា សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ឬមួយក៏រដ្ឋសភាខុសអីនោះ ខ្ញុំអត់មានបានបកស្រាយទេ។ ក៏ប៉ុន្តែបើយើងពិនិត្យមើលអាជ្ញាយុកាលផុតហើយ បានមានការពន្យារ តើកន្លែងហ្នឹងត្រឹមត្រូវអត់? វាអត់ត្រឹមត្រូវ។

[១៤:២៣:៣៣]

ទន្ទឹមនឹងនោះ គឺថាខាងសហព្រះរាជអាជ្ញាជាតិ និងអន្តរជាតិបានលើកឡើងថា គឺចាប់តាំងពីឆ្នាំ៧៩មក រហូតដល់ឆ្នាំ៩៣ គឺយើងមានតែគ្រូបង្រៀន អត់មានអ្នកចេះច្បាប់ មានតែក្រឹត្យច្បាប់ មានតែអីហ្វូរហែ។

ខ្ញុំសូមជម្រាបជូនថានាពេលហ្នឹងស្រុកយើងខ្ញុំហ្នឹងមានអីចឹង មានតែប៉ុណ្ណឹង ពីព្រោះអីយើងខ្ញុំហ្នឹងនាពេលហ្នឹងមានលទ្ធភាពតែប៉ុណ្ណឹង គឺថាអ្នកដែលចេះហ្នឹង គឺគាត់ស្លាប់អស់ហើយ គឺមានតែគ្រូបង្រៀន។ បើមិនយកគ្រូបង្រៀនមកធ្វើតុលាការ មាននរណាចេះអានច្បាប់? ពីព្រោះសុភាសិតបារាំងបាននិយាយថាម៉េច? និយាយថា *លួសស្កុងណាប៉ា សឺកុងណែម អែមស៊ីកុងណា* (និយាយភាសាបារាំង) នៅពេលដែលយើងគ្មានអ្វី យើងស្រលាញ់តែអ្វីដែលយើងមាន។ នៅពេលហ្នឹងមានតែអាវខ្មៅទៅស្រលាញ់អាវក្រហមឯណា មានអាវក្រហមឯណាពាក់? ពីព្រោះលទ្ធភាពស្រុកខ្ញុំតែប៉ុណ្ណឹង។ ហើយខ្ញុំសូមអនុញ្ញាតជម្រាបជូនថា ក្រឹត្យច្បាប់គឺចេញដោយក្រុមប្រឹក្សារដ្ឋ។ ក្រុមប្រឹក្សារដ្ឋចេញហើយយកមកអនុវត្តក្រោយពីនៅចន្លោះសម័យប្រជុំសភា ពីព្រោះក្រុមប្រឹក្សារដ្ឋនាពេលហ្នឹង បើខ្ញុំចាំមិនភ្លេចទេ នៅក្នុងរដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋប្រជាមានិតកម្ពុជាបានកំណត់ថា “ក្រុមប្រឹក្សារដ្ឋគឺជាសមាជិកអចិន្ត្រៃយ៍របស់រដ្ឋសភា”។ បើជាសមាជិកអចិន្ត្រៃយ៍របស់រដ្ឋសភា នៅចន្លោះសម័យប្រជុំសភា គាត់ចេញក្រឹត្យច្បាប់យកមកអនុវត្ត ក្រោយពីសម័យប្រជុំសភា គាត់ដាក់ជូនសភាអនុម័ត។

[១៤:២៤:៥៩]

ដូច្នេះ អត់មានខុសទេ អត់មានទិតៀនថាក្រឹត្យច្បាប់ហ្នឹង វាមិនពេញលេញ ក្រឹត្យច្បាប់ហ្នឹងមិនត្រឹមត្រូវ មិនមែនទេ។ ពីព្រោះនាពេលហ្នឹងស្រុកយើងខ្ញុំហ្នឹងអនុវត្តនូវលទ្ធិសង្គមនិយម គឺសាធារណរដ្ឋប្រជាមានិតកម្ពុជា។ ហើយបើយើងខ្ញុំចាំមិនភ្លេចទេនៅឆ្នាំ១៩៨០ ស្រុកយើងខ្ញុំហ្នឹងមានក្រឹត្យច្បាប់លេខ០២ គឺជាច្បាប់ព្រហ្មទណ្ឌសម្រាប់អនុវត្តនៅប្រទេសកម្ពុជា។ ហើយមានតុលាការ បង្កើតតុលាការនៅឆ្នាំ១៩៨២ មានច្បាប់ស្តីពីការចាត់តាំងនូវសកម្មភាពរបស់សាលាជម្រះក្តីបង្កើតនៅឆ្នាំ១៩៨២ គឺថាជំនុំជម្រះរាល់បទល្មើសទាំងឡាយដែលកើតឡើងមានបទល្មើសឆក់ប្លន់ ប៉ុន្តែតិចណាស់ មានច្រើនជាងគេគឺបទល្មើសបដិវត្តន៍។

ដូច្នេះ ស្រុកយើងខ្ញុំមានតុលាការ មិនមែនអត់តុលាការទេ មាន គឺថារហូតទៅដល់មានទោសប្រហារជីវិតទៀត ក្រោយពីសម្រេចសេចក្តីហើយ ដើម្បីឲ្យវាមានលទ្ធភាព គឺទុករយៈពេលប្រាំពីរថ្ងៃឲ្យតវ៉ាទៅក្រុមប្រឹក្សារដ្ឋ។ ក្រុមប្រឹក្សារដ្ឋ ជាអ្នកត្រួតពិនិត្យឡើងវិញនូវសាលក្រមដែលយកទៅប្រហារ

ជីវិតទៀត។ រហូតដល់សព្វថ្ងៃហ្នឹងមានបទប្បញ្ញត្តិស្តីពីការប្រហារជីវិត គឺសរសេរលម្អិតនៅក្នុងហ្នឹងតែម្តង។

[១៤:២៦:១៩]

ដូច្នេះ ស្រុកយើងខ្ញុំមានតុលាការ ប៉ុន្តែគ្រាន់តែថាតុលាការខាងយើងខ្ញុំនេះវាមានកម្រិតទាប ដែលវាមិនចូលស្តង់ដារ ដែលអស់លោកៗនៅប្រទេសរីកចម្រើនទៅមានស្តង់ដារខ្ពស់អីយ៉ាងណាៗនោះ។

ដូច្នេះនៅក្នុងករណីនេះ នៅឆ្នាំ១៩៨១ ស្រុកយើងខ្ញុំហ្នឹងក៏មានរដ្ឋធម្មនុញ្ញ។ ដូច្នេះនៅក្នុងករណីហ្នឹងរដ្ឋធម្មនុញ្ញ ហើយបើយករដ្ឋធម្មនុញ្ញរបស់យើងខ្ញុំឆ្នាំ៨១ យកទៅប្រៀបធៀប៩៣ វាអត់ត្រឹមត្រូវទេ វាមិនខុសអំពីយកដើមត្នោតយកទៅប្រៀបធៀមជាមួយនឹងមនុស្ស វាខុសគ្នា។ គឺបានសេចក្តីថាមួយអនុវត្តនូវរបបសង្គមនិយមសរសេរនាពេលនុំង គឺអីចឹង ហើយដល់ក្រោយមកអនុវត្តនូវហៅថារបបប្រជាធិបតេយ្យ អាហ្នឹងរឿងមួយផ្សេងទៀត វាជាណាចក្រទីពីរហ្នឹង។

ដូច្នេះ នៅក្នុងករណីនេះ ខ្ញុំបាទសូមអនុញ្ញាតជម្រាបជូនថា ស្រុកខ្ញុំនាពេលហ្នឹងគឺមានច្បាប់មានតុលាការ មានអីត្រឹមត្រូវ។ ថ្វីត្បិតតែក្រឹត្យច្បាប់ វាមានឈ្មោះខុសពីគេបន្តិចមែន ក៏វាជាច្បាប់ដែរ ដោយសារអី ដោយសារហៅថា ក្រុមប្រឹក្សារដ្ឋហ្នឹង គឺជាសមាជិកអចិន្ត្រៃយ៍របស់រដ្ឋសភា។ ទន្ទឹមនឹងនោះដែរៗ គឺថាស្រុកយើងខ្ញុំហ្នឹងនាពេលហ្នឹងគឺបានបង្កើតតុលាការ បានបង្កើតអីហូរហែអីចឹង បង្កើតអីហូរហែ រហូតទៅដល់មានហៅថាកាត់ទោសប្រហារជីវិតទៀត យកទៅប្រហារជីវិតនៅកាំបូលនេះ គឺនៅពេលហៅថាសាលក្រមចូលជាស្ថាពរ យកទៅប្រហារជីវិត។

[១៤:២៧:៤៤]

ដូច្នេះ ក្នុងករណីនេះ ខ្ញុំសូមបំភ្លឺជូនអង្គសវនាការថា នាពេលហ្នឹងគឺមានៗហៅថាតុលាការមានអីត្រឹមត្រូវ មិនមែនថាមិននេះទេ ហើយទោះបីជាយ៉ាងណាក៏ដោយ គឺថានៅឆ្នាំ១៩៧៩ គឺយើងមានហៅថា គឺថារណសិរ្សសង្គ្រោះ គឺថាក្រុមប្រឹក្សាសង្គ្រោះប្រជាពលរដ្ឋហ្នឹង គឺកើតនៅឆ្នាំ១៩៧៩ យើងបានហៅថា រំដោះប្រជាពលរដ្ឋចេញពីក្រញ៉ាំ ហើយថាពួកខ្មែរក្រហមអីច្បាំងគ្នាហូរហែទៅ គឺយើងយើងបានកំណត់មានច្បាប់មានអីត្រឹមត្រូវ បើមិនអីចឹងទេ ស្រុកខ្ញុំចលាចលងាប់ហើយ។ ហើយខ្ញុំបាទហ្នឹងរស់តាំងពីពេលហ្នឹងមក តាំងពីសម័យណាមកគឺរស់តាំងរបបខ្មែរក្រហមបីឆ្នាំប្រាំបីខែក៏នៅទីហ្នឹងដល់ឆ្នាំ១៩៧៩ ខ្ញុំបាទក៏នៅទីហ្នឹង រហូតដល់សព្វថ្ងៃហ្នឹង ខ្ញុំបាទក៏នៅទីហ្នឹង។ គឺខ្ញុំច្បាប់លាស់ណាស់អារឿងបញ្ហាហ្នឹង។

[១៤:២៨:៤៤]

ហើយទន្ទឹមនឹងហ្នឹង គឺខ្ញុំបាទសូមអនុញ្ញាតជម្រាបជូនថា បើយើងពិនិត្យមើលអំពីភាពប្រតិសកម្ម សួរថានៅក្នុងនីតិព្រហ្មទណ្ឌមានភាពប្រតិសកម្មឬអត់? បើយើងកំណត់ក្នុងករណីដែលហៅថាកាលដែលហៅថាអាជ្ញាយុកាលត្រូវផុតរលត់ហើយ ហើយបែទៅជាមានហៅថា ការពន្យារពេលអ៊ីចឹងទៅ ហើយនាំឲ្យមានអានុភាពប្រតិសកម្ម គឺថាខ្ញុំបាទយល់ឃើញថាមិនត្រឹមត្រូវទេ។

ដូច្នេះ ជុំវិញបញ្ហាអាជ្ញាយុកាល គឺខ្ញុំបាទយល់ឃើញថាជាការផុតរលត់ទៅហើយ។ ការផុតរលត់យ៉ាងដូច្នេះ គឺមិនអាចធ្វើការចោទប្រកាន់បានទៀតទេ។

ចំពោះខ្ញុំសូមអរគុណ ចំពោះហៅថាការត្រង់ត្រាប់ស្តាប់។ សូមអរគុណ។

[១៤:២៩:២៩]

**ប្រធានអង្គជំនុំ៖**

សូមអរគុណលោកមេធាវី។

ឥឡូវនេះមានបញ្ហាបច្ចេកទេស អ៊ីនធឺណេត ដែលមិនដំណើរការ ហើយខាងអ្នកបច្ចេកទេសត្រូវការពេលវេលាដើម្បីរៀបចំឲ្យដំណើរការឡើងវិញ ហើយម្យ៉ាងទៀត ក៏ពេលវេលឈប់សម្រាកក៏សមល្មម សមស្របហើយដែរ។ អ៊ីចឹង អង្គជំនុំជម្រះប្រកាសសម្រាកម្ភៃនាទី ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបីខ្វះដប់នាទីសូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង១៤:៣១នាទី ដល់ម៉ោង១៤:៥២នាទី)*

[១៤:៥៣:៣៣]

**ប្រធានអង្គជំនុំ៖**

សូមព្រះតេជគុណនិមន្តគង់ ហើយសូមអស់លោក លោកស្រីអង្គុយចុះ!

អង្គជំនុំជម្រះសាលាដំបូង ប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។

មុននឹងឈានចូលដល់របៀបវារៈបន្ទាប់ អង្គជំនុំជម្រះសូមធ្វើការណែនាំដល់ភាគីដូចខាងក្រោមនេះ៖

អង្គជំនុំជម្រះសាលាដំបូង សូមជម្រាបដល់ភាគីទាំងអស់ថា នៅពេលចាប់ផ្ដើមពិភាក្សាអំពីបញ្ហាបញ្ជីឈ្មោះសាក្សី អ្នកជំនាញ និងដើមបណ្ដឹងរដ្ឋប្បវេណីសូមភាគីទាំងអស់ចងចាំថា មិនមានសាក្សី អ្នកជំនាញ ដើមបណ្ដឹងរដ្ឋប្បវេណីណាមួយត្រូវបានបដិសេធនោះទេ រហូតដល់មានសេចក្ដីសម្រេចជាក់លាក់របស់អង្គជំនុំជម្រះសាលាដំបូង។ អង្គជំនុំជម្រះសាលាដំបូង សូមជម្រាបផងដែរថា សូមភាគីទាំងអស់និយាយកម្រិតទៅលើតែសាក្សី អ្នកជំនាញ និងដើមបណ្ដឹងរដ្ឋប្បវេណីដែលមានឈ្មោះនៅក្នុងបញ្ជីបណ្ដោះអាសន្ន ដែលអង្គជំនុំជម្រះបានផ្ដល់ជូនតែប៉ុណ្ណោះ ហើយក៏សូមជម្រាបផងដែរថា បញ្ជីនេះគឺសម្រាប់តែដំណាក់កាលដំបូងនៃការជំនុំជម្រះអង្គសេចក្ដីតែប៉ុណ្ណោះ។

[១៤:៥៥:២៣]

ជាកិច្ចបន្តឈានចូលដល់របៀបវារៈ ការបញ្ជាក់បឋមអំពីខ្លឹមសារនៃសំណងរដ្ឋប្បវេណី ដែលសហមេធាវីនាំមុខតំណាងឲ្យដើមបណ្ដឹងរដ្ឋប្បវេណី មានបំណងទាមទារនៅក្នុងបណ្ដឹងទាមទារចុងក្រោយសម្រាប់សំណងសមូហភាព និងសំណងផ្លូវចិត្ត ដោយអនុលោមតាមវិធាន២៣ស្ទួន៤ អនុវិធាន ៣ ចំណុច ខ នៃវិធានផ្ទៃក្នុង អ.វ.ត.ក។ អនុលោមតាមវិធានផ្ទៃក្នុង ដែលត្រូវបានធ្វើវិសោធនកម្ម សហមេធាវីនាំមុខតំណាងឲ្យដើមបណ្ដឹងរដ្ឋប្បវេណី អាចទាមទារសំណងក្នុងទម្រង់ចំនួនពីរ ប្រសិនបើមេធាវីនាំមុខតំណាងឲ្យដើមបណ្ដឹងរដ្ឋប្បវេណី ធ្វើការជ្រើសរើសខ្លួនអាចសុំទាមទារសំណងជាទម្រង់នៃការទាមទារសំណងរដ្ឋប្បវេណី ប្រឆាំងទៅនឹងជនជាប់ចោទ។ នេះគឺជាទម្រង់នៃសំណងរដ្ឋប្បវេណីតែមួយគត់ ដែលមាននៅក្នុងសំណុំរឿងលេខ០០១ នៅចំពោះមុខ អ.វ.ត.ក ហើយទម្រង់នេះត្រូវបានរក្សាទុកដដែលនៅក្នុងវិធាននាពេលបច្ចុប្បន្ន។

ដូចបានបញ្ជាក់នៅក្នុងសាលក្រមករណី កាំង ហ្កេកអ៊ាវ ហៅ ឌុច សំណងទាំងនេះត្រូវជាបន្ទុករបស់ជនជាប់ចោទ ប្រសិនបើជនជាប់ចោទត្រូវបានសម្រេចថាមានទោស ហើយត្រូវអនុវត្តដោយតុលាការជាតិកម្ពុជាបើចាំបាច់។ ប្រសិនបើទម្រង់សំណងមួយនេះត្រូវបានពិចារណាឃើញថា មិនទំនងជាអាចផ្ដល់លទ្ធផលជាសំណងដ៏មានន័យមួយដល់ជនរងគ្រោះទេនោះ ឥឡូវនេះវិធានផ្ទៃក្នុងដែលត្រូវបានកែប្រែ បានអនុញ្ញាតឲ្យសហមេធាវីនាំមុខតំណាងឲ្យដើមបណ្ដឹងរដ្ឋប្បវេណី ស្នើសុំជាគម្រោងផ្ដួចផ្ដើមសំណង ដែលអាចត្រូវបានសម្របសម្រួលដោយអង្គភាពគាំពារជនរងគ្រោះ តាមរយៈការគ្រប់គ្រងគម្រោង។

[១៤:៥៧:៥១]

គម្រោងផ្តួចផ្តើមទាំងនេះ មិនអាចជាការបង្ខំឲ្យជនជាប់ចោទជាអ្នកអនុវត្តនោះទេ។ ផ្ទុយទៅវិញ អាចសម្រេចទៅបាន ឬមិនបាននៃគម្រោងផ្តួចផ្តើមទាំងអស់នេះ នឹងផ្អែកទៅលើលទ្ធភាពរបស់អង្គភាពគាំពារជនរងគ្រោះ ក្នុងការស្វែងរកឲ្យបាននូវជំនួយហិរញ្ញវត្ថុគ្រប់គ្រាន់ សម្រាប់គម្រោងនីមួយៗ និងដើម្បីគ្រប់គ្រងការអនុវត្តគម្រោងនោះឲ្យបានជោគជ័យ។ សំណើទាមទារសំណងក្នុងទម្រង់ណាមួយក្នុងចំណោមទម្រង់ទាំងពីរ នៅចំពោះមុខ អ.វ.ត.ក ត្រូវមានលក្ខណៈជាសំណងផ្លូវចិត្ត និងជាសមូហភាព។ មានន័យថា សំណងនេះចាំបាច់ត្រូវមានលក្ខណៈជានិមិត្តរូប។ សំណងក្នុងទម្រង់ណាមួយក្នុងចំណោមទម្រង់ទាំងពីរនេះ មិនត្រូវបានរំពឹងថា ជាការសងជាថវិកាផ្ទាល់ឲ្យទៅដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ៗនោះឡើយ។ ដោយសារថា ជនរងគ្រោះមានចំនួនច្រើនលើសលប់ ហើយក៏ទំនងជាមិនមានលទ្ធភាពក្នុងការស្វែងរកថវិកាដែលមានចំនួនច្រើនបែបនេះនោះផងដែរ។

[១៤:៥៩:០៨]

ដូចបានបញ្ជាក់នៅក្នុងកិច្ចប្រជុំរៀបចំសវនាការ និងបញ្ជាក់ជាបន្តបន្ទាប់នៅក្នុងរបៀបវារៈសម្រាប់សវនាការបឋមនេះ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបានផ្តល់ឱកាសឲ្យដាក់ជូនអង្គជំនុំជម្រះនូវការបញ្ជាក់បឋម ស្តីពីខ្លឹមសារនៃសំណងដែលខ្លួនមានបំណងស្នើសុំនៅក្នុងពាក្យសុំចុងក្រោយរបស់ខ្លួនសម្រាប់សំណងផ្លូវចិត្ត និងជាសមូហភាព ដោយអនុលោមតាមវិធាន២៣ស្ទួន៤ អនុវិធាន៣ ចំណុច ខ នៃវិធានផ្ទៃក្នុង អ.វ.ត.ក។ ការបញ្ជាក់ជាមុនពីមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីអំពីលក្ខណៈនៃការទាមទារសំណង គឺជាព័ត៌មានដ៏មានសារៈសំខាន់សម្រាប់ អង្គជំនុំជម្រះសាលាដំបូង។ អង្គជំនុំជម្រះទទួលស្គាល់ថាលក្ខណៈជាក់លាក់នៃសំណងដែលបានស្នើឡើងអាចវិវឌ្ឍន៍ទៅតាមពេលវេលា ហើយការទាមទារសំណងទាំងនោះ ដែលត្រូវបង្ហាញជាចុងក្រោយអាចខុសទៅតាមចំណុចជាក់លាក់មួយចំនួន។

តទៅនេះ សូមអញ្ជើញអង្គជំនុំជម្រះផ្តល់វេទិកាទៅសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីធ្វើការបទបង្ហាញអំពីខ្លឹមសារនៃការបឋមនៃការទាមទារសំណង។ សូមអញ្ជើញ!

[១៥:០០:៥៨]

**លោក ពេជ អង្គ៖**

សូមគោរពលោកចៅក្រមប្រធាន សូមគោរពលោកស្រី លោកដែលជាចៅក្រមអង្គសវនាការ ព្រះអង្គគ្រប់អង្គ និងសាធារណជនដែលមានវត្តមាននៅទីនេះ ទាំងក្នុង និងក្រៅប្រទេស។ មេធាវីនាំមុខ

តាមវិធានផ្ទៃក្នុងត្រូវលើកអំពីខ្លឹមសារជាក់លាក់ជាបឋមស្ដីពីសំណង ដែលសហមេធាវីនាំមុខដើមបណ្ដឹងរដ្ឋប្បវេណីមានបំណងស្នើសុំនៅក្នុងពេលសវនាការចុងក្រោយ។ ពេលនេះ យើងខ្ញុំជាមេធាវីនាំមុខ មានខ្ញុំបាទ ពេជ អង្គ ជាមេធាវីជាតិ និងលោកស្រីមេធាវី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត និងធ្វើការលើកអំពីសំណងដែលយើងខ្ញុំមានបំណងស្នើសុំ ដែលបែងចែកពេលវេលាគ្នា។ ដោយជាបឋមគឺខ្ញុំបាទជាអ្នកចាប់ផ្ដើមជាបឋម បន្ទាប់មកលោកស្រីមេធាវី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត ហើយដោយឆ្លាស់គ្នាក្នុងរយៈពេលមួយម៉ោងនេះ។

[១៥:០២:២១]

ទាក់ទងទៅនឹងអ្វីដែលជាការផ្ដើមនៅក្នុងរឿងសំណងនេះ ជាការពិតនៅក្នុងពិភពលោកនេះ ការទទួលស្គាល់ភាពរងគ្រោះនៃឧក្រិដ្ឋកម្ម ឬក៏ការរំលោភសិទ្ធិមនុស្សនៅក្នុងបរិបទជាតិ និងអន្តរជាតិ គឺជាកង្វល់ដែលខ្លាំងនៃយុត្តិធម៌នាពេលបច្ចុប្បន្ននេះ ជនរងគ្រោះក៏ចូលរួមយ៉ាងសកម្មនៅក្នុងការស្វែងរកការពិតនិងយុត្តិធម៌។ ជនរងគ្រោះនៅក្នុងបរិបទនៃ អ.វ.ត.ក យើងនេះ បានស្នើសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីផង ខ្លះស្នើសុំជាអ្នកប្ដឹងធម្មតា ខ្លះចូលខ្លួនសុំជាសាក្សី។ ហើយអ្នកដែលសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី គឺមានបំណងក្នុងការសារស្វែងរកយុត្តិធម៌ ហើយក៏ចង់ស្វែងរកសំណងដែលជាសមាសធាតុចាំបាច់មួយក្នុងចំណោមសមាសធាតុមូលដ្ឋានយុត្តិធម៌សម្រាប់ជនរងគ្រោះ ក៏ដូចជាសម្រាប់សង្គមផងដែរ ថ្វីត្បិតថាមិនមែនគ្រប់ពេលទាំងអស់ទេ អ្វីដែលជាការស្នើសុំសុទ្ធតែនឹងទទួលបាននោះ យ៉ាងហោចណាស់ក៏មានសំណងមួយចំនួនដែលអាចផ្ដល់ជូនទៅដើមបណ្ដឹងរដ្ឋប្បវេណី ហើយក៏អាចទទួលផលដល់ជនរងគ្រោះផ្សេងៗទៀត ហើយដែលអាចឲ្យពួកគាត់ផ្សះផ្សាផ្នែកផ្លូវចិត្តបានផងដែរ។

[១៥:០៤:០៩]

ជាការពិតយុត្តិធម៌ និងសំណងដែលជនរងគ្រោះ ឬសមាជិកគ្រួសាររបស់គេទទួលបាន មិនមានន័យថា វាជួសជុលទាំងស្រុងនូវការឈឺចាប់របស់គេដោយសារតែឥទ្ធិពលឧក្រិដ្ឋកម្មនោះទេ ប៉ុន្តែយ៉ាងហោចណាស់ក៏វាអាចចូលរួមចំណែកក្នុងការជួយជនរងគ្រោះទាំងនោះឲ្យមានការធូរចិត្ត ដែលអាចឈានទៅដល់ការធ្វើឲ្យប្រសើរឡើងនូវផ្លូវអារម្មណ៍របស់គាត់បន្តិចម្ដងៗ។ នេះគឺជាសិទ្ធិរបស់ជនរងគ្រោះក្នុងការទទួលបាននូវការដោះស្រាយមួយយ៉ាងពិតប្រាកដ ដោយសារមានការរំលោភបំពានដែលនាំឲ្យប៉ះពាល់សិទ្ធិជាសារវន្តរបស់ពួកគាត់។

ក្នុងការដឹកនាំក្នុងរយៈពេល បីឆ្នាំប្រាំបីខែម្ភៃថ្ងៃ ត្រូវបានគេយល់ថា មានមេដឹកនាំ និងអ្នកដែលមានតួនាទីសំខាន់ៗមួយចំនួនក្នុងរបបនោះ មានជាប់ទាក់ទងនៅក្នុងឧក្រិដ្ឋកម្មជាច្រើន ហើយដែលនាំទៅដល់ការបាត់បង់ជីវិតរបស់ប្រជាពលរដ្ឋអស់ជាច្រើនលាននាក់។ អំពើនេះគឺជាការរំលោភសិទ្ធិមនុស្សដ៏ធ្ងន់ធ្ងរបំផុតក្នុងប្រវត្តិសាស្ត្រមនុស្សជាតិ ហើយវាបានបំពារបំពានផងដែរទៅលើច្បាប់ជាតិ និងច្បាប់អន្តរជាតិ។

[១៥:០៥:១២]

ព្រះរាជាណាចក្រកម្ពុជា ដោយសារមានជំនួយពីអង្គការសហប្រជាជាតិបានបង្កើតអង្គជំនុំជម្រះវិសាមញ្ញមួយ ដែលស្ថិតក្នុងរចនាសម័ន្ធនៃតុលាការកម្ពុជាដែលមានឈ្មោះថា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់ទោសឧក្រិដ្ឋកម្មដែលកើតឡើងក្នុងរយៈពេលនោះ។ ហើយដែលមានតួនាទីនៅក្នុងការផ្តល់សំណងផងដែរទៅដល់ដើមបណ្តឹងរដ្ឋប្បវេណី។

ថាតើអ្វីខ្លះដែលជាមូលដ្ឋានគតិយុត្តិក្នុងពាក់ព័ន្ធនឹងបញ្ហាសំណងនេះ?

នៅក្នុងបរិបទតុលាការ និងជាពិសេសក្នុងបរិបទនៃយុត្តិធម៌អន្តរជាតិ គេយល់ឃើញថា សំណងគឺគ្រប់វិធានការទាំងអស់ដែលអាចប្រើប្រាស់ក្នុងគោលដៅជួសជុលនូវព្យសកម្មផ្សេងៗដែលជនរងគ្រោះបានទទួលរង ហើយដែលជាព្យសនកម្មទាំងនេះហើយជាផលវិបាកនៃឧក្រិដ្ឋកម្មណាមួយ។

[១៥:០៦:១២]

បទដ្ឋានជាតិនានា ធានាសិទ្ធិនៅក្នុងការដោះស្រាយក្នុងរូបភាពជាសំណងសម្រាប់ជួសជុលការខូចខាតដល់ជនរងគ្រោះអំពីអំពើរំលោភបំពានទាំងឡាយដែលប៉ះពាល់ដល់ផលប្រយោជន៍ និងសិទ្ធិរបស់ជនរងគ្រោះ។ សិទ្ធិក្នុងការទទួលបានការដោះស្រាយនេះត្រូវធ្វើឡើងតាមយន្តការនៃប្រព័ន្ធតុលាការ។

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាត្រង់មាត្រា៣១ បានលើកឡើងថា ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្សដូចមានចែងក្នុងរដ្ឋធម្មនុញ្ញអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយដែលទាក់ទងនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ។ ប្រជាពលរដ្ឋមានសិទ្ធស្មើគ្នាចំពោះមុខច្បាប់ មានសេរីភាព និងករណីកិច្ចដូចគ្នាទាំងអស់ ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា និន្នាការនយោបាយ។ល។

[១៥:០៧:០២]

មាត្រា៣៩ នៃរដ្ឋធម្មនុញ្ញដដែល ក៏បានលើកអំពីសិទ្ធិរបស់ប្រជាពលរដ្ឋក្នុងការប្តឹងទាមទារការជួសជុលការខូចខាតចំពោះការបំពារបំពានលើច្បាប់ណាមួយដោយស្ថាប័នរដ្ឋក៏មន្ត្រីរបស់រដ្ឋ ឬក៏សង្គមតាមរយៈតុលាការផងដែរ។ លើសពីនេះទៅទៀត ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧ ក៏បានបញ្ជាក់យ៉ាងច្បាស់ថែមទៀតអំពីសិទ្ធិ និងគោលបំណងនៃបណ្តឹងទាមទារជួសជុលការខូចខាតដល់ជនរងគ្រោះ ព្រមទាំងលក្ខណៈនៃសំណងដែលស្ថិតនៅក្នុងបរិបទនៃបទល្មើសព្រហ្មទណ្ឌ។

[១៥:០៧:៣៨]

ក្រមរដ្ឋប្បវេណី ដែលបានប្រកាសឲ្យប្រើតាំងពីឆ្នាំ២០០៧ បង្កើតជាសិទ្ធិជាមូលដ្ឋានដល់ឯកត្តជនដែលសិទ្ធិបុគ្គលរបស់គេត្រូវបានរំលោភ ឬត្រូវបានរំលោកដោយ មានសិទ្ធិស្នើសុំឲ្យតុលាការបញ្ឈប់ការរំលោភ មានសិទ្ធិទាមទារឲ្យលុបចោលនូវផលនៃសកម្មភាពរំលោភ នោះប្រសិនបើមាន និងមានសិទ្ធិទាមទារសំណងការខូចខាតចំពោះអន្តរាយដែលបានទទួលរង។ សិទ្ធិបុគ្គលត្រូវបានកំណត់ន័យក្នុងមាត្រា១០ ថា "ជាសិទ្ធិដែលពាក់ព័ន្ធដល់បុគ្គល រួមទាំងសិទ្ធិមានជីវិត សុខភាព និងកិត្តិយស"។

នៅក្នុងបរិបទនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា យើងក៏មានវិធាន៨០ស្ទួន នៃវិធានផ្ទៃក្នុងដែលពាក់ព័ន្ធនឹងសវនាការបឋម បញ្ជាក់នៅក្នុងវាក្យខណ្ឌទី៤ និងទី៥ ថា នៅក្នុងវាក្យខណ្ឌទី៤ "អង្គជំនុំជម្រះអាចតម្រូវឲ្យសហមេធាវីនាំមុខ តំណាងដើមបណ្តឹងរដ្ឋប្បវេណីបញ្ជាក់ជាបឋមអំពីខ្លឹមសារនៃសំណងសមូហភាព និងផ្លូវចិត្ត ដោយសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីមានបំណងទាមទារជាចុងក្រោយ ដោយអនុលោមតាមវិធាន២៣ ស្ទួនបី អនុវិធាន៣(ខ) នៃវិធានផ្ទៃក្នុង"។

[១៥:០៨:៥៥]

អង្គជំនុំជម្រះកំណត់ជាចុងក្រោយនូវកាលបរិច្ឆេទឲ្យមេធាវីនាំមុខដើមបណ្តឹង-- តំណាងដើមបណ្តឹងរដ្ឋប្បវេណីត្រូវដាក់សំណើទាមទារសំណងសមូហភាព និងផ្លូវចិត្តជាចុងក្រោយរបស់ខ្លួន។

នៅក្នុងចំណុច៥ នៃវិធានដដែលនេះ ប្រសិនបើអាច សំណើទាមទារសំណងសមូហភាព និងផ្លូវចិត្តជាចុងក្រោយនេះអាចខុសពីការបញ្ជាក់ជាបឋមអំពីខ្លឹមសារនៃសំណងសមូហភាពនិងផ្លូវចិត្ត។ ផ្ទុយទៅវិញ ទោះជាយ៉ាងណាក៏ដោយសំណើទាមទារត្រូវបញ្ជាក់អំពីប្រភេទ និងបែបបទនៃការអនុវត្តសំណងនីមួយៗដែលបានទាមទារ។

ដោយឡែកវិធាន២៣ស្ទួនបី អនុវិធាន៣(ខ) នៃវិធានផ្ទៃក្នុងពាក់ព័ន្ធទៅនឹងការទាមទារជាចុងក្រោយ និងតម្រូវឲ្យបញ្ជាក់បន្ថែមផ្សេងៗទៀតដូចជា៖ ដោយសម្រេចអំពីបែបបទនៃការអនុវត្តសំណង

ពាក់ព័ន្ធទៅនឹងសំណងនីមួយៗ អង្គជំនុំជម្រះអាច៖

ក) បង្គាប់ថាសោហ៊ុយនៃសំណងត្រូវតែជាបន្ទុករបស់ពិរុទ្ធជន ឬ

ខ) ទទួលស្គាល់នូវទម្រង់ជាក់លាក់ដែលមានលក្ខណៈសមស្របឆ្លើយតបទៅនឹងសំណងដែលទាមទារដោយសហមេធាវីនាំមុខដើមបណ្ដឹងរដ្ឋប្បវេណី ហើយអាចអនុវត្តបាន។

គម្រោងបែបនេះនឹងត្រូវបានគេបង្កើតឡើង ឬបង្ហាញច្បាស់លាស់ដោយសហការជាមួយអង្គភាពគាំពារជនរងគ្រោះ ហើយបានធានានូវការផ្ដល់មូលនិធិគ្រប់គ្រាន់ពីខាងក្រៅ។ នេះជាអ្វីដែលសិទ្ធិនៅក្នុងវិធានជាតិ និងក្នុងបរិបទនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

ចំណែកឯវិធានអន្តរជាតិក៏មានបញ្ជាក់អំពីសិទ្ធិនៅក្នុងការទាមទារសំណងនេះដែរ។ ហើយដែលខ្ញុំសូមអនុញ្ញាតប្រគល់ជូនលោកស្រីមេធាវី អេលីហ្សាបេត ស៊ីម៉ុណ្ណូហ្វត ដើម្បីបន្ត។

[១៥:១០:៥៥]

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

តើច្បាប់អន្តរជាតិនោះចែងយ៉ាងម៉េចខ្លះទាក់ទងទៅនឹងសំណង-- សិទ្ធិដែលទទួលបានសំណងនេះ។ សិទ្ធិទទួលសំណងនេះត្រូវទទួលស្គាល់នៅក្នុងច្បាប់អន្តរជាតិតាមរយៈយុត្តិសាស្ត្រអន្តរជាតិ តាមអង្គភាពមួយចំនួនរបស់អង្គការសហប្រជាជាតិ និងប្រព័ន្ធការពារសិទ្ធិមនុស្សថ្នាក់តំបន់។ បើយើងជាបឋមនោះ គឺថាយើងអាចយោងទៅលើសេចក្ដីប្រកាសជាសកលស្ដីអំពីសិទ្ធិមនុស្សដែលជាប្រភពនៃមូលដ្ឋានលិខិតុបករណ៍ និងយុទ្ធសាស្ត្រដទៃទៀតដែលពាក់ព័ន្ធនឹងបញ្ហាសំណងនេះ។

[១៥:១១:២៦]

សេចក្ដីប្រកាសនេះ លើកឡើងថា មនុស្សគ្រប់រូបមានសិទ្ធិទទួលដំណោះស្រាយជាក់ស្ដែងចំពោះមុខសាលាជំនុំជម្រះជាតិ ដែលមានសមត្ថកិច្ចចំពោះអំពើទាំងឡាយណាដែលរំលោភសិទ្ធិជាមូលដ្ឋានរបស់ខ្លួនដែលត្រូវបានទទួលស្គាល់ដោយរដ្ឋធម្មនុញ្ញ ឬដោយច្បាប់។

កតិកាសញ្ញាអន្តរជាតិសិទ្ធិ ស្ដីពីសិទ្ធិពលរដ្ឋ ហើយនិងសិទ្ធិនយោបាយនៅឆ្នាំ១៩៩៦ ត្រង់ប្រការ ២(៣)(ក) ចែងថា រដ្ឋភាគីនៃកតិការសញ្ញានេះ សន្យាធានាជនដែលត្រូវបានរំលោភសិទ្ធិ និងសេរីភាពរបស់ខ្លួនដែលទទួលស្គាល់ដោយកតិកាសញ្ញានេះ ជននោះមានសិទ្ធិឲ្យមានដំណោះស្រាយដោយស័ក្តិសិទ្ធចំពោះ-- ទោះបីជាការរំលោភបំពាននោះប្រព្រឹត្តដោយជនដែលបំពេញតួនាទីផ្លូវការក៏ដោយ។

[១៥:១២:២១]

ជនណាក៏ដែលរងគ្រោះដោយសារការឃាត់ខ្លួន ឬការឃុំខ្លួនដោយខុសច្បាប់ មានសិទ្ធិទាមទារសំណង។ បន្ទាប់មកទៀត ពាក់ព័ន្ធនឹងអំពើរំលោភសិទ្ធិមនុស្ស ឬឧក្រិដ្ឋកម្មទៅលើប្រជាពលរដ្ឋ និងការទទួលស្គាល់ព្យសនកម្មដែលទទួលរង ឬក៏អាចដែលអាចទទួលរងនោះ។ នៅឆ្នាំ១៩៨៥ មហាសន្និបាតអង្គការសហប្រជាជាតិបានអនុម័តសេចក្តីប្រកាសស្តីអំពីគោលការណ៍ជាមូលដ្ឋាននៃយុត្តិធម៌សម្រាប់ជនរងគ្រោះដោយឧក្រិដ្ឋកម្ម និងការរំលោភអំណាច។

សេចក្តីប្រកាសនេះ បង្កើតគោលការណ៍ជាមូលដ្ឋានសំដៅជួយដល់រដ្ឋាភិបាល និងសហគមន៍អន្តរជាតិ ក្នុងកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនដើម្បីការពារយុត្តិធម៌ និងជួយជនរងគ្រោះពីឧក្រិដ្ឋកម្ម និងជនរងគ្រោះពីការរំលោភអំណាច ដោយធានាថាជនរងគ្រោះទាំងនោះមានសិទ្ធិទទួលបានយុត្តិធម៌និងសិទ្ធិទទួលបានបដិទាន និងសំណងជាប្រាក់។

[១៥:១៣:៣០]

សេចក្តីប្រកាសនេះណែនាំថា ប្រសិនបើសំណងជាប្រាក់មិនត្រូវបានបង់ដោយពេញលេញដោយជនល្មើស ឬក៏ប្រភពផ្សេងទៀតនោះទេ រដ្ឋគួរតែខ្នះខ្នែងផ្តល់សំណងជាប្រាក់នោះដល់--

ចំណុច ក) ជនរងគ្រោះដែលទទួលរងរបួសធ្ងន់រាងកាយ ឬក៏ខូចសរីរាង្គ ឬក៏សុខភាពផ្លូវចិត្តដែលបណ្តាលមកពីឧក្រិដ្ឋកម្មដ៏ធ្ងន់ធ្ងរនេះ។ ខ) ទៅក្រុមគ្រួសារជាពិសេស សមាជិកគ្រួសាររបស់ជនដែលបានស្លាប់ ឬក៏ក្លាយខ្លួនជាពិការរាងកាយ ឬក៏ផ្លូវចិត្តដែលបណ្តាលមកពីការធ្វើឲ្យក្លាយជាជនរងគ្រោះបែបនេះ។ ជាបញ្ចប់គេគួរតែជំរុញឲ្យលើកទឹកចិត្តដល់ការបង្កើតដល់ការពង្រឹង ឬក៏ពង្រីកមូលនិធិជាតិសម្រាប់សំណងដល់ជនរងគ្រោះ។

តាមតម្រូវការត្រូវតែបង្កើតមូលនិធិផ្សេងៗទៀត ដើម្បីជួយបង្កើតឲ្យមាន ប្រសិនបើសមស្របរួមទាំងករណីទាំងឡាយណាដែលជនរងគ្រោះជារបស់រដ្ឋ តែរដ្ឋនោះមិនមានលទ្ធភាពសងអន្តរាយដល់ជនរងគ្រោះ។ បន្ទាប់មកទៀត យើងដើម្បីវាយតម្លៃសិទ្ធិមនុស្សទទួលបានសំណងរបស់ជនរងគ្រោះនៃការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើច្បាប់អន្តរជាតិស្តីពីសិទ្ធិមនុស្ស និងច្បាប់មនុស្សធម៌អន្តរជាតិ ជាការចាំបាច់ត្រូវយោងទៅលើគោលការណ៍ផ្សេងៗដែលកំណត់ដោយ *វ៉ាន់បូវែន, បាស្សូនី, និង ហ្សូនែណោត* (និយាយភាសាបារាំង)។

[១៥:១៥:០៨]

ទាញចេញពីគោលការណ៍ទាំងនេះនៅថ្ងៃទី២១ មីនា ឆ្នាំ២០០៩ មហាសន្និបាតអង្គការសហ

ប្រជាជាតិបានអនុម័តចេញសេចក្តីសម្រេចមួយពាក់ព័ន្ធនឹងគោលការណ៍ជាមូលដ្ឋាន និងសេចក្តីណែនាំស្តីពីសិទ្ធិទទួលបានដំណោះស្រាយ និងការជួសជុលសំណងព្យសនកម្មដល់ជនរងគ្រោះដោយការរំលោភបំពានដ៏កំរោលលើសិទ្ធិមនុស្សអន្តរជាតិ និងការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើច្បាប់មនុស្សធម៌អន្តរជាតិ។ គោលការណ៍ជាមូលដ្ឋាននេះអនុម័តទស្សនៈមួយដោយចាត់ទុកជនរងគ្រោះជាអ្នកដែលទទួលខុសត្រូវដែលគួរតែត្រូវយកចិត្តទុកដាក់បំផុតយ៉ាងពិស្តារអំពីវិធី ដែលជនរងគ្រោះគួរទទួលបានការជួសជុលសំណងពីព្យសនកម្មឲ្យបានគ្រប់គ្រាន់ ឲ្យមានប្រសិទ្ធភាព និងឆាប់រហ័ស។ តាមសមាមាត្រទៅនឹងភាពធ្ងន់ធ្ងរនៃការរំលោភបំពាននិងអន្តរាយដែលទទួលរង។

[១៥:១៦:១២]

ម្យ៉ាងវិញទៀតគោលការណ៍ ១៥ ដល់១៨ រំឭកពីសំណង បំណងនៃសំណង ហើយធានាដល់ជនរងគ្រោះនូវសំណងពេញលេញដោយមានប្រសិទ្ធភាព។ ប្រភេទសំណងដែលចែងនិងរៀបរាប់យ៉ាងលម្អិតនៅក្នុងគោលការណ៍១៩-២៩ ដូចជាបដិទាន សំណងជាប្រាក់ ជាការស្តារនិតិសម្បទា និងការបំពេញចិត្ត ឬការធានាមិនឲ្យមានការកើតឡើងម្តងទៀតនោះ។ ឥឡូវនេះ ខ្ញុំសូមផ្អាកត្រឹមនេះទាក់ទងទៅនឹងយុត្តាធិការអន្តរជាតិ ហើយខ្ញុំនឹងនិយាយអំពីសញ្ញាណនៃខ្លឹមសារជាក់លាក់ ការចង្អុលបង្ហាញដំបូងទាក់ទងទៅនឹងខ្លឹមសារជាក់លាក់នៃសំណង។

វិធានផ្ទៃក្នុងនៃអ.វ.ត.ក ចែងថា សំណងរបស់ដើមបណ្តឹងរដ្ឋប្បវេណីត្រូវដាក់ជាពីរដំណាក់កាល។ អ្វីដែលយើងចាប់អារម្មណ៍នៅថ្ងៃនេះគឺថាដំណាក់កាលដំបូង។ ទាក់ទងទៅនឹងដំណាក់កាលដំបូងនេះ វិធាន៨០ស្ទួន តម្រូវឲ្យតែបញ្ជាក់ជាបឋម អំពីខ្លឹមសារជាក់លាក់នៃសំណងសមូហភាពដែលមិនផ្លូវការ ដែលមេធាវីនាំមុខចង់ស្នើសុំនៅក្នុងពាក្យសុំចុងក្រោយដែលមិនចាំបាច់បញ្ជាក់អំពីទម្រង់ ឬក៏អត្ថន័យពិតប្រាកដនៃសំណើទាំងនោះទេ។ បើជាការប្រៀបធៀបទាំងច្បាប់កម្ពុជា ទាំងទម្លាប់អនុវត្តរបស់តុលាការ ពិសេស ឬក៏ទម្លាប់អនុវត្តតុលាការសិទ្ធិមនុស្សអន្តរអាមេរិកាំង មិនចែងអំពីនីតិវិធីបែបនេះជាពីរដំណាក់កាលឡើយ។ ចំពោះមុខតុលាការព្រហ្មទណ្ឌអន្តរជាតិយោងតាមវិធាននីតិវិធីនិងភស្តុតាងសំណើសុំសំណងមិនចាំបាច់បំពេញ-- មិនចាំបាច់ពេញលេញនោះទេ ហើយត្រូវបញ្ជាក់តែអំពីសំណើសុំការប៉ះប៉ូវស្តារនិតិសម្បទាឬក៏សំណងក្រោមទម្រង់ផ្សេងទៀត។ អាស្រ័យហេតុដូច្នេះវាមានការលំបាកក្នុងការផ្អែកទៅលើយុទ្ធសាស្ត្រអន្តរជាតិដើម្បីបញ្ជាក់អំពីទ្រង់ទ្រាយនៃការបញ្ជាក់បឋមនៃខ្លឹមសារជាក់លាក់អំពីសំណងនេះ។

[១៥:១៨:៤៥]

ប្រហែលជាមានតែយន្តការនៃការពាក្យបណ្តឹងអន្តរជាតិរបស់តុលាការសិទ្ធិមនុស្សអឺរ៉ុបប៉ុណ្ណោះនោះទេ ដែលទំនងជាអាចផ្តល់នូវការបំភ្លឺមួយចំនួនទៅលើសញ្ញាណនៃការបញ្ជាក់ជាបឋម អំពីខ្លឹមសារជាក់លាក់នៃសំណងនេះ។ ដូច្នេះ តុលាការអឺរ៉ុបនោះបានតម្រូវឱ្យរដ្ឋផ្តល់នូវបទដ្ឋាន ការណែនាំសំខាន់ៗ អំពីសំណើសុំបំពេញខ្លួនដោយយុត្តិធម៌។ ដូចគ្នាចំពោះដើមបណ្តឹងរដ្ឋប្បវេណីនៅ ចំពោះមុខអ.វ.ត.ក ដែរ ម្ចាស់សំណើនៅតុលាការអឺរ៉ុបត្រូវបានផ្តល់ព័ត៌មានសំណងដែលស្នើសុំ។

នៅរឿងក្តី ហ្សូកហ្ស៊ី ដែលប្រឆាំងនឹងប្រទេសរុស្ស៊ី ការចង្អុលបង្ហាញជាបឋមរបស់រដ្ឋាភិបាលម្ចាស់សំណើ បានទាមទារតុលាការឱ្យផ្តល់ឱ្យខ្លួននូវការបំពេញចិត្តដោយយុត្តិធម៌យោងទៅតាមមាត្រា៤១ គឺ ការប៉ះប៉ូវ ការជួសជុលជំងឺចិត្ត បដិទានស្តារនិតិសម្បទា សោហ៊ុយ និងប្រាក់ប្រដាប់ក្តី ឬវិធានកែប្រែសម្រួលផ្សេងទៀត ដែលត្រូវបញ្ជាក់សម្រាប់គ្រប់ការខូចខាតខាងសម្ភារៈ និងខាងផ្លូវចិត្តដែលជនរងគ្រោះបានជួបប្រទះ ក្រោយពីភាគីរងគ្រោះ និងដោយសារតែអំពើរំលោភបំពាននៃការបន្តនីតិវិធីនេះ។ គឺក្នុងបរិបទនៃយុត្តិសាស្ត្រនេះ ដែលមិនទាន់ពេញលេញនៅឡើយនេះហើយ ដែលសហសហមេធាវីនាំមុខដាក់ខ្លឹមសារជាបឋមអំពីសំណងសមូហភាព និងផ្លូវចិត្តនេះ។

ដូច្នេះ ខ្ញុំសូមផ្អាកត្រឹមនេះសិនបន្តិចសិនលើ និងដើមបណ្តឹងរដ្ឋប្បវេណី ហើយនិងសញ្ញាណដើមបណ្តឹងរដ្ឋប្បវេណី ព្រោះថាមិនទាន់សំណាងលើដើមបណ្តឹងរដ្ឋប្បវេណីនេះនោះទេ ហើយខ្ញុំចង់និយាយបន្តិចបន្តួច វិធានផ្ទៃក្នុងនៃ អ.វ.ត.ក ដកស្រង់ចេញពីក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ហើយដែលក្រមនេះផ្ទាល់ដកស្រង់ចេញពីគំនិតច្បាប់បារាំង ហើយនិយាយឱ្យទូលាយទៅ គឺដកស្រង់ចេញពីគំនិតប្រព័ន្ធច្បាប់ស៊ីវិលឡូ បានបញ្ចូលដើមបណ្តឹងរដ្ឋប្បវេណីជាភាគីមួយនៃដំណើរការនីតិវិធី។ វិធាន២៣(១)(ខ) បញ្ជាក់ថា ដើមបណ្តឹងរដ្ឋប្បវេណីមានគោលដៅសុំសំណងសមូហភាព និងផ្លូវចិត្តស្របតាមវិធាន២៣ស្ទួន។

[១៥:២១:២៥]

វត្តមានដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសវនាការមិនត្រូវចាត់ទុកថា គ្រាន់តែឆ្លើយតបទៅនឹងក្តីព្រួយបារម្ភដើម្បីឱ្យជនរងគ្រោះចូលរួមនៅក្នុងការបង្ហាញការខឹងសម្បា សោកស្តាយ ឬការឈឺចាប់ក្នុងពេលវេលាក្របខ័ណ្ឌ និងទម្រង់រឹតត្បិតនោះទេ។ គ្មានអ្វីដែលហាមឃាត់ឱ្យជនរងគ្រោះមិនឱ្យបង្ហាញអារម្មណ៍ទាំងអស់នេះនោះទេ ហើយវាអាចជាការលាតត្រដាង-- ការលាតត្រដាងបែបនេះវាអាចជា

មធ្យោបាយមួយក្នុងការជួយស្វែងរកការពិត ក៏ប៉ុន្តែទាំងនោះមិនអាចគ្រប់គ្រាន់ទេក្នុងការឆ្លុះបញ្ចាំងតួនាទីរបស់ដើមបណ្តឹងរដ្ឋប្បវេណីនោះ។

ដើមបណ្តឹងរដ្ឋប្បវេណីមិនមែនជាភ្ញៀវគេអញ្ជើញមកចូលរួមក្នុងការជម្រះសេចក្តីដើម្បីបំពេញចិត្តជនរងគ្រោះ ពីព្រោះថាគាត់ជាជនរងគ្រោះផងដែរ។ ធ្វើមើលតែផ្តល់ជូនគាត់នូវប្រាក់រង្វាន់ ឬក៏សំណងជាមុនអ៊ីចឹង។ ដើមបណ្តឹងរដ្ឋប្បវេណីមិនមែនគ្រាន់តែជាមធ្យោបាយធ្វើឲ្យជនរងគ្រោះមានអារម្មណ៍ថា គាត់ត្រូវបានគេផ្សារភ្ជាប់ទៅនឹងការជំនុំជម្រះ ហើយនិងចូលរួមបានបន្តិចបន្តួចនោះទេ។

[១៥:២២:៤០]

គ្រប់រាល់នីតិវិធីព្រហ្មទណ្ឌ ដែលអនុញ្ញាតឲ្យដើមបណ្តឹងរដ្ឋប្បវេណីចូលរួមក្នុងការជំនុំជម្រះមិនឆ្លើយតបទៅនឹងតម្រូវការក្នុងការសម្តែងនូវកាយវិការយកចិត្តទុកដាក់ និងការយោគយល់ប្រកបដោយមនសិការល្អចំពោះជនរងគ្រោះនោះទេ។ ដើមបណ្តឹងរដ្ឋប្បវេណីមិនមែនជាភ្ញៀវទេ គាត់មានសិទ្ធិដែលទទួលស្គាល់និងកំណត់ដោយវិធានជាតិ និងអន្តរជាតិ និងសិទ្ធិស្មើគ្នានឹងជនជាប់ចោទដែរ។ សិទ្ធិនេះកើតចេញច្បាប់សមហេតុសមផល និងមានមូលដ្ឋានត្រឹមត្រូវក្នុងការជំនុំជម្រះក្តីព្រហ្មទណ្ឌ នៅចំពោះមុខ អ.វ.ត.ក ដែលមានលក្ខណៈពិសេសក្នុងយុត្តិសាស្ត្រព្រហ្មទណ្ឌអន្តរជាតិ ដើម្បី-- ដើមបណ្តឹងរដ្ឋប្បវេណីដូចគ្នានឹងជនជាប់ចោទ ព្រះរាជអាជ្ញា មានសិទ្ធិគ្រប់យ៉ាងដែរ ដូចជាសិទ្ធិទាមទារឲ្យបំពេញកិច្ច សិទ្ធិបញ្ចេញយោបល់តាមរយៈសារណាជាអក្សរ ឬក៏ផ្ទាល់មាត់ សិទ្ធិធ្វើឧបាស្រ័យ ជាពិសេសចំពោះដើមបណ្តឹងរដ្ឋប្បវេណី គឺសិទ្ធិទាមទារសំណង។

[១៥:២៣:៤៦]

កាលណាវិធានផ្ទៃក្នុងលើកឡើងនូវសិទ្ធិរបស់ភាគី ក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ សមភាពនៃមធ្យោបាយតទល់ក្តីជាដើម។ វិធានផ្ទៃក្នុងនិយាយសំដៅដល់ដើមបណ្តឹងរដ្ឋប្បវេណី ក៏ដូចជាភាគីដទៃទៀត។

ដើមបណ្តឹងរដ្ឋប្បវេណីគឺជាភាគីដែលពាក់ព័ន្ធនឹងអង្គហេតុដែលលើកឡើង ដូចគាត់បានទទួលរងព្យសនកម្ម អំពីអំពើទាំងអស់នេះប្រឈមមុខគ្នានឹងចារីត្រូវបានស្វែងរក គាត់គឺជាជនរងគ្រោះនៃបទល្មើស ជាកម្មវត្ថុនៃបទល្មើស ហើយច្បាស់ណាស់គាត់ជាធាតុមួយក្នុងចំណោមធាតុផ្សំផ្សេងទៀតយ៉ាងសំខាន់នៃបទល្មើស។ បើគ្មានជនរងគ្រោះ ក៏គ្មានឧក្រិដ្ឋកម្មទាំងឡាយដែលចោទប្រកាន់ ក៏មិនមាននោះដែរ។

[១៥:២៤:៣៥]

ដូច្នេះ ជនរងគ្រោះក៏មិនមែនត្រឹមតែជាសាក្សីនោះទេ គាត់ជាតួអង្គចាំបាច់បំផុតម្នាក់នៃអង្គហេតុដែលវិនិច្ឆ័យ។ ក្នុងន័យនេះទស្សនៈរបស់គាត់ គឺជាសារៈសំខាន់ណាស់ ហើយការវិភាគទាន និងការចូលរួមចំណែកស្វែងរកការពិតដ៏ចាំបាច់។ គាត់មានសិទ្ធិទាមទារសំណង ហើយប៉ុន្តែជាឋមគាត់ត្រូវរង់ចាំរហូតដល់ពេលពិរុទ្ធភាពត្រូវបានរកឃើញ។ គាត់ថែមទាំងអាចចូលរួមចំណែកក្នុងការលាតត្រដាងពិរុទ្ធភាពទៀតផង។ ដោយសារតែភាគីមួយដែលទទួលរងនូវអំពើដែលកើតឡើង ជនរងគ្រោះអាចចូលរួមចំណែកក្នុងការលាតត្រដាងការពិត។ ហេតុនេះហើយបានគោលបំណងទីមួយ គឺស្វែងរកការពិតនិងពិរុទ្ធភាពដែលធ្វើឲ្យគាត់ក្លាយទៅជាជនរងគ្រោះ។ សំណងត្រូវបាន-- លិខិតបទដ្ឋានអន្តរជាតិចាត់ទុកជាសិទ្ធិ ការទាមទារសំណងនៅក្នុងការជំនុំរឿងព្រហ្មទណ្ឌ គឺអនុញ្ញាតឲ្យមានទំនាក់ទំនងរវាងសំណងនិងអំពើដែលត្រូវបានជំនុំជម្រះ។ នេះគឺជាការផ្តល់អត្ថន័យចំពោះសិទ្ធិទទួលបានសំណង។ វាក៏ផ្តល់អត្ថន័យដល់ទណ្ឌកម្មផងដែរ ដោយសារតែទំនាក់ទំនងរវាងវាទាំងអស់នេះមានធូន់ធូរនៃអង្គហេតុ។

**លោក ពេជ អង្គ៖**

*(មិនឮសំឡេង)*

**ប្រធានអង្គជំនុំ៖**

បើកៗក្បាលមេក្រូសិន! ម៉េច?

[១៥:២៦:១៨]

**លោក ពេជ អង្គ៖**

វិធានផ្ទៃក្នុងបានតម្រូវឲ្យមានទំនាក់ទំនងជាមួយអង្គហេតុដែលត្រូវបានផ្តន្ទាទោសចំពោះដើមបណ្តឹងរដ្ឋប្បវេណី។ ជាការពិត វិធានផ្ទៃក្នុងបានចែងថា អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋ-ប្បវេណី ត្រូវបង្ហាញជាលទ្ធផលដោយផ្ទាល់ពីបទឧក្រិដ្ឋយ៉ាងហោចណាស់មួយនៃបទឧក្រិដ្ឋជាច្រើនដែលត្រូវបានចោទប្រកាន់ទៅលើជនត្រូវចោទ ថាខ្លួនពិតជាបានទទួលរងនូវព្យសនកម្មខាងរូបកាយ ខាងផ្លូវចិត្ត ខាងសម្ភារៈ ដែលជាមូលដ្ឋានសម្រាប់ទាមទារសំណង ផ្លូវចិត្ត និងសមូហភាព។

ដូច្នេះ ចាំបាច់ត្រូវតែមានការបង្ហាញអំពីទំនាក់ទំនង រវាងសំណងដែលទាមទារ និង ព្យសនកម្មដែលបានទទួលរង ហើយព្យសនកម្មនេះទៀតសោតក៏ត្រូវមានទំនាក់ទំនងជាមួយអង្គហេតុដែលត្រូវបានចោទប្រកាន់ផងដែរ។

[១៥:២៧:១៣]

អត្ថិភាពនៃព្យសនកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណី និងទំនាក់ទំនងរបស់វាទៅនឹងអង្គហេតុដែលមាននៅក្នុងវិសាលភាពនៃការស៊ើបអង្កេត ត្រូវបានជឿទុកចិត្តថា មានតាមរយៈសេចក្ដីសម្រេចរបស់ចៅក្រមស៊ើបអង្កេត។ ដោយចៅក្រមអង្កេតថា បានសម្រេចថា បណ្ដាអ្នកប្ដឹងទាំងអស់បានផ្ដល់ភស្ដុតាងគ្រប់គ្រាន់ដើម្បីឲ្យជឿទុកចិត្តថា ពួកគេបានទទួលព្យសនកម្មជាលក្ខណៈបុគ្គលនៅក្នុងយុត្តាធិការនៃអង្គជំនុំជម្រះ។ ចំណែកឯទំនាក់ទំនងអង្គហេតុ និងបច្ច័យរវាងព្យសនកម្ម និងឧក្រិដ្ឋកម្មទាំងឡាយដែលបានចោទប្រកាន់ទៅលើជនជាប់ចោទ ចៅក្រមស៊ើបអង្កេតក៏បានអះអាងថា ក្រោយពីបានពិនិត្យព័ត៌មានផ្សេងៗរបស់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី។ ដើមបណ្ដឹងរដ្ឋប្បវេណីដែលត្រូវបានទទួលដែលគាត់បានទទួលនោះ សុទ្ធតែបានភ្ជាប់ជាមួយនូវភស្ដុតាងគ្រប់គ្រាន់ ហើយដែលក្រោយពីបានពិនិត្យជាបឋមអាចឲ្យយើងឃើញថា ព្យសនកម្មរបស់ពួកគាត់ចេញពីផលវិបាកដោយផ្ទាល់ទៅនឹងអំពើដែលជាកម្មវត្ថុនៃការស៊ើបអង្កេត តាមផ្លូវតុលាការដូចមានចែងក្នុងដីកាបញ្ជូនរឿងឲ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញា។

[១៥:២៨:២៦]

អ្នកដែលត្រូវទទួលបានសំណងសម្ភូហភាពនិងផ្លូវចិត្ត តាមវិធានផ្ទៃក្នុងបានកំណត់ថា អង្គជំនុំជម្រះអាចសម្រេចផ្ដល់សំណងផ្លូវចិត្ត និងសំណងសម្ភូហភាពទៅដល់ភាគីដើមបណ្ដឹងរដ្ឋប្បវេណីតែប៉ុណ្ណោះ។ ការពិគ្រោះយោបល់ជាមួយដើមបណ្ដឹងរដ្ឋប្បវេណីត្រូវបានធ្វើ។ នៅក្នុងដំណើរការពិគ្រោះយោបល់របស់ខ្លួន ដើមបណ្ដឹងរដ្ឋប្បវេណីបានបង្ហាញអំពីសំណងដែលខ្លួនចង់បាន ដល់មេធាវីរបស់ខ្លួន ហើយក៏បានបញ្ជូនមកមេធាវីនាំមុខតំណាងឲ្យដើមបណ្ដឹងរដ្ឋប្បវេណីដើម្បីច្របាច់បញ្ចូលគ្នា បន្ទាប់ពីបានពិភាក្សាជាមួយមេធាវីទាំងអស់។

ហើយពេលនេះ នៅពេលដែលយើងទើបតែបានទទួលនូវសេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះនៅថ្ងៃ២៤ ខែមិថុនា ឆ្នាំ២០១១នេះ យើងក៏បានទទួលនូវដើមបណ្ដឹងរដ្ឋប្បវេណីដែលត្រូវទទួលថ្មីដោយអង្គបុរេជំនុំជម្រះចំនួន១.៧២៨នាក់ ហើយជាការចាំបាច់ដែរដែលត្រូវមានការពិគ្រោះយោបល់ជាមួយដើមបណ្ដឹងរដ្ឋប្បវេណីថ្មីដែលទើបតែទទួលដោយអង្គបុរេជំនុំជម្រះនេះ ដើម្បីធានាឲ្យគាត់បានបញ្ចេញនូវយោបល់របស់គាត់ អំពីអ្វីដែលគាត់ចង់បានចំពោះសំណងនេះ។ ហើយបន្ទាប់មក នឹងរៀបចំប្រមូលគំនិតដើម្បីបង្កើតជាសំណើរួមបញ្ជូនមកអង្គជំនុំជម្រះដើម្បីឲ្យមានការទទួលស្គាល់។

[១៥:២៩:៥៥]

ជាការពិតតាមផ្លូវច្បាប់ សំណងគឺសម្រាប់តែដើមបណ្ដឹងរដ្ឋប្បវេណី ក៏ប៉ុន្តែសម្រាប់សភាពជាក់ស្តែង វាក៏អាចផ្តល់ជាផលប្រយោជន៍ផងដែរទៅដល់ជនរងគ្រោះ និងពលរដ្ឋដទៃទៀត។ ហើយសំណងនេះ ដើមបណ្តឹងរដ្ឋប្បវេណីមិនអាចទទួលក្នុងនាមជាបុគ្គលបានឡើយ។ ហើយក៏មិនមែនក្នុងនាមជានីតិបុគ្គល ដែលមានទទួលស្គាល់បុគ្គលភាពគតិយុត្តិដោយអាជ្ញាធរសាធារណៈឡើយ។ គឺទទួលក្នុងនាមជាក្រុមរួមតែមួយ ហើយដែលសំណងនោះត្រូវតែឆ្លើយតបទៅនឹងតម្រូវការរបស់សមាជិកនៃក្រុមរួម ព្រមទាំងលក្ខណៈដោយឡែកនៃសមាជិកនៃក្រុមរួមផងដែរ។ ដូចជា ក្រុមជនរងគ្រោះដែលជាជនជាតិវៀតណាម ឬក៏ជនរងដែលជាព្រះសង្ឃ ឬក៏ជាជនជាតិចាមជាដើម។

[១៥:៣០:៤៧]

សម្រាប់សំណងបញ្ហានេះ វិធានផ្ទៃក្នុងនិយាយសំដៅទៅលើតុលាការ សម្រេចបញ្ហាទៅទណ្ឌិត ឬក៏ទទួលស្គាល់គម្រោងដែលទាមទារដោយមេធាវីនាំមុខ។ យោងតាមវិធាននេះ គឺមេធាវីនាំមុខ ជាអ្នកលើកអំពីសំណងដែរខ្លួនចង់បាន។ សំណងនេះ មេធាវីនាំមុខត្រូវទទួលយោបល់អំពីមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ដែលជាអ្នកពិគ្រោះយោបល់ជាមួយកូនក្តីរបស់ខ្លួន ហើយនិងលើកសំណើនេះមកមេធាវីនាំមុខ។ ដោយរៀបចំជាមួយអង្គភាពគាំពារជនរងគ្រោះ ហើយបច្ចុប្បន្ននេះ អង្គភាពគាំពារជនរងគ្រោះបានធ្វើការយ៉ាងសកម្ម ពាក់ព័ន្ធទៅនឹងការប្រមូលផ្តុំ អ្វីដែលជាយោបល់ដែលលើកឡើងដោយក្រុមមេធាវី ក៏ដូចជាអង្គការក្រៅរដ្ឋាភិបាលផ្សេងៗ។ ហើយនិងបន្តការសិក្សាដើម្បីបង្កើតជាគម្រោងឲ្យមានលក្ខណៈជាក់លាក់ និងអាចទទួលយកបាន។

សំណងដែលមានបំណងស្នើសុំដោយមេធាវីនាំមុខគឺត្រូវផ្អែកទៅលើអ្វី ដែលជាគម្រោងដែលនឹងរៀបចំឡើងដោយអង្គភាពគាំទ្រជនរងគ្រោះ ហើយនិងត្រូវឆ្លងនូវការពិភាក្សាជាច្រើនលើកច្រើនសាដើម្បីឲ្យរៀបចំឲ្យបានត្រឹមត្រូវ។

សំណងនេះបន្ទាប់ពីបានពិភាក្សាជាមួយក្រុមមេធាវី ដែលជាមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីកន្លងមក ឃើញថាមានប្រភេទធំៗ ចំនួនបួន នៅក្នុងនោះ។

ទីមួយ គឺពាក់ព័ន្ធទៅនឹងការចងចាំ និងការរំឭក។ ទីពីរ គឺពាក់ព័ន្ធទៅនឹងការស្តារនីតិសម្បទាឡើងវិញ។ ទីបី គឺពាក់ព័ន្ធទៅនឹងការចងក្រងឯកសារ និងការអប់រំ។ និងបញ្ហាចុងក្រោយ មានសំណងផ្សេងៗទៀត។

[១៥:៣២:៤៦]

ទន្ទឹមនឹងនេះអនុលោមតាមវិធាន៨០ស្ទួន នៃវិធានផ្ទៃក្នុង ក្រោយពីមានសេចក្ដីណែនាំរបស់អង្គជំនុំជម្រះលើខ្លឹមសារនៃសំណង។ មេធាវីដើមបណ្ដឹងរដ្ឋប្បវេណីនឹងលើកទម្រង់នៃសំណងស្នើសុំ ដើម្បីរៀបចំឱ្យបានត្រឹមត្រូវតាមតម្រូវការរបស់អង្គជំនុំជម្រះ។

ដូចបានជម្រាបនៅក្នុងជំពូក៤ ដែលបានលើកអម្បាញ់មិញ មានសំណង-- នៅក្នុងជំពូក៤នោះគឺថាជាលម្អិតមានដូចតទៅៈ

នៅក្នុងជំពូកពាក់ព័ន្ធទៅនឹងការចងចាំ ហើយនិងការរំឭកវិញ្ញាណក្ខន្ធ គឺថាភាគីដើមបណ្ដឹងរដ្ឋប្បវេណីមានបំណងស្នើសុំ ឱ្យមានការទទួលស្គាល់នូវថ្ងៃមួយសម្រាប់រំឭកនូវការចងចាំ ហើយដែលថ្ងៃនេះមិនទាន់បានកំណត់ថាជាថ្ងៃណាទេ។ ហើយក៏អាចជាថ្ងៃមួយសម្រាប់នៅក្នុងប្រទេស ដែលជាថ្ងៃដែលមានលក្ខណៈជាតិ ឬក៏អាចជាថ្ងៃចងចាំអំពីពាក់ព័ន្ធទៅនឹងអំពើប្រល័យពូជសាសន៍ នៅក្នុងកម្រិតអន្តរជាតិផងដែរ។

មានសំណើសុំផងដែរ ទាក់ទងទៅនឹងការបង្កើតឱ្យមានស្តូប ហើយនិងចេតិយដែលអាចរៀបចំឡើងនៅតាមទីកន្លែងណាដែលអាចសមស្រប ហើយអាចមានស្តូបដែលសម្រាប់គ្រប់អ្នកដែល-- គ្រប់សាសនាផ្សេងៗ ដែលអាចមកធ្វើពិធីផ្សេងៗ ដោយមិនមានការប្រកាន់នូវសាសនា នូវពូជសាសន៍ ជាតិពណ៌សម្បុរអ្វីឡើយ។ ហើយពាក់ព័ន្ធទៅនឹងចំនួន គឺមិនបានកំណត់ថា មានចំនួនប៉ុន្មាននោះទេ។

[១៥:៣៤:៥៤]

ដើមបណ្ដឹងរដ្ឋប្បវេណី ក៏មានបំណងផងដែរ នៅក្នុងការស្នើសុំឱ្យមានការរក្សានូវទីកន្លែងដែលជាទីកន្លែងពិឃាតមនុស្ស។ ហើយពាក់ព័ន្ធនៅចំណុចនេះ ទាមទារឱ្យមានការចាំបាច់នៅក្នុងសិក្សាឱ្យបានជាក់លាក់ថា តើកន្លែងណាខ្លះ ដែលជាកន្លែង ដែលមនុស្សជាច្រើនត្រូវបានពិឃាត ហើយនៅក្នុងកម្រិតណាដែលយើងគួរតែទទួលឱ្យមានការរក្សា។

នៅក្នុងជំពូកទីពីរ ទាក់ទងទៅនឹងស្ដារនីតិសម្បទា មានចំណុចពីរនៅក្នុងទីនោះ។ ទីមួយ គឺមានការបង្កើតឱ្យមានរចនាសម្ព័ន្ធផ្នែកសេវាសុខភាពផ្លូវចិត្ត និងសុខភាពផ្នែកស្មារតី ហើយក៏មានការស្នើសុំឱ្យមានការទទួលបាននូវសេវាទាំងអស់នោះ ដោយមិនគិតថ្លៃ ព្រមទាំងមានការបង្កើតមជ្ឈមណ្ឌលនានាផងដែរ នៅក្នុងការព្យាបាលសុខភាព។ ចំណុចទីពីរ ក៏ពាក់ព័ន្ធទៅនឹងការស្ដារនីតិសម្បទានេះ ក៏ចង់ស្នើសុំឱ្យមាននូវកម្មវិធីក្រុមពិភាក្សា ដែលនៅក្នុងនោះគឺអ្នកដែលជាជនរងគ្រោះ គាត់អាចពិភាក្សាគ្នាដើម្បី

កាត់បន្ថយនូវការឈឺផ្លូវចិត្តរបស់ពួកគាត់។ នៅពេលដែលគាត់ជួបគ្នា គាត់អាចបន្ធូរ ធូរចិត្តនូវអ្វី ដែលគាត់បានបៀមនៅក្នុងចិត្តរបស់គាត់។

[១៥:៣៦:៣៥]

ពាក់ព័ន្ធនឹងប្រភេទការចងក្រងឯកសារ ហើយនិងការអប់រំ នៅក្នុងនោះមានបីចំណុចគឺៈ មានកម្មវិធីអប់រំ ដែលនៅក្នុងនោះមានទាំងការអប់រំអំពីប្រវត្តិនៃរបបកម្ពុជាប្រជាធិបតេយ្យផងដែរ ហើយដែលមានចំនួនហើយ ដែលត្រូវបានអនុវត្តនៅពេលនេះ។

ទីពីរ គឺមានការស្នើសុំឲ្យមានការបង្កើតឡើងនូវមជ្ឈមណ្ឌលមួយដែលមានលក្ខណៈជាសារមន្ទីរផង ជាកន្លែងបណ្ណសារផង ឬក៏ជាបណ្ណាល័យដែលអាចគេចូលទស្សនានៅក្នុងនោះ។ ហើយដែលទំហំនៃអ្វីដែលស្នើសុំនេះ អាចធំទៅតូចទៅតាមសមត្ថភាព ហើយនិងទៅតាមទីកន្លែងដែលអាចធ្វើទៅបាន។ ហើយក៏ចង់ស្នើឲ្យមានបង្កើតសារមន្ទីរធំមួយដែលចងក្រងនូវសៀវភៅប្រវត្តិសាស្ត្រ ហើយនិងអ្វីទាំងអស់ដែលពាក់ព័ន្ធនឹងរបបខ្មែរក្រហមនៅក្នុងសារមន្ទីរដ៏ធំនោះ ដែលនឹងចង់ស្នើសុំឲ្យមាននៅក្នុងទីក្រុងភ្នំពេញ។ ចំណុចទីបី-- ចំណុចមួយទៀត ក៏ចង់ស្នើសុំឲ្យមាននូវការចងក្រងនូវបញ្ជីរបស់ជនរងគ្រោះផងដែរ។

[១៥:៣៨:០១]

ជាចុងក្រោយ ពាក់ព័ន្ធទៅនឹងប្រភេទដែលយើងខ្ញុំទទួលពីដើមបណ្តឹងរដ្ឋប្បវេណីតាមរយៈមេធាវី ហើយយើងខ្ញុំពុំទាន់បានពិភាក្សាឲ្យលម្អិត ដោយសារប្រភេទទាំងអស់នោះមានលក្ខណៈស្មុគស្មាញ។ នៅក្នុងនោះ គឺថាមានគម្រោងទាក់ទងទៅនឹងការផ្តល់សញ្ជាតិសម្រាប់ជនរងគ្រោះក្នុងសម័យខ្មែរក្រហមដែលជាជនជាតិវៀតណាម។ មានគម្រោងអប់រំសម្រាប់កុមារ ឬក៏កូនដែលកើតអំពីគ្រួសារដែលត្រូវបានបង្ខំរៀបអាពាហ៍អាពិពាហ៍នៅក្នុងសម័យខ្មែរក្រហម។ មានគម្រោងបង្កើតឲ្យមានមូលនិធិស្វយ័តមួយ "*ត្រាសប្បាន់*"។ មានការស្នើសុំឲ្យមានគម្រោងនៅក្នុងការត្រួតពិនិត្យការអនុវត្តមូលនិធិ ដូចដែលបានលើកឡើងនេះ។ ជាពិសេស ពាក់ព័ន្ធនឹងមូលនិធិសម្រាប់សំណង និងអនុវត្តសំណង។ ហើយក៏មានគម្រោងនៅក្នុងការស្នើសុំឲ្យមានការផ្សព្វផ្សាយនូវសាលក្រម នៅក្នុងករណី០០២ នេះផងដែរ ដើម្បីឲ្យសាធារណជនបានជ្រាប។

[១៥:៣៩:៣០]

ទាំងអស់នេះ គឺជាគម្រោងដែលបានលើកឡើង ហើយបានពិចារណាមួយចំនួនធំ រវាងមេធាវី

ដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីនាំមុខ ក៏ដូចជា បន្ទាប់ពីបានពិគ្រោះជាមួយនឹងដើមបណ្តឹងរដ្ឋប្បវេណី ហើយជាការពិតនឹងត្រូវមានការពិគ្រោះបន្ថែមទៀត ជាមួយដើមបណ្តឹងរដ្ឋប្បវេណីថ្មីដែលទើបតែទទួលស្គាល់ដោយអង្គបុរេជំនុំជម្រះ មានចំនួន១.៧២៨ រូបនេះ។ ហើយនិងមានការស្នើសុំកែប្រែ ទាក់ទងទៅនឹងអ្វីដែលជាសំណងដែលមានបំណងស្នើសុំនេះ។

ហើយសម្រាប់ជាចុងក្រោយ ខ្ញុំបាទសូមអនុញ្ញាតអង្គជំនុំជម្រះ អនុញ្ញាតឲ្យលោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត ដើម្បីធ្វើការថ្លែងការបញ្ចប់ពាក់ព័ន្ធទៅនឹងសំណើរសុំបឋមអំពីសំណងនេះ។ សូមអរគុណ។

[១៥:៤០:៤៥]

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

ខ្ញុំគ្រាន់តែនិយាយបន្តិចប៉ុណ្ណោះ ដើម្បីទាក់ទាញអារម្មណ៍អស់លោក លោកស្រី ទាក់ទងទៅនឹងសេចក្តីពិចារណាដើម្បីបញ្ចប់សេចក្តីថ្លែងការណ៍ខ្ញុំនេះ បើយើងបានធ្វើបង្ហាញអំពីការចង្អុលបង្ហាញបឋមទាក់ទងទៅនឹងខ្លឹមសារជាក់លាក់នៃសំណងដែលយើងនឹងសុំនោះ យើងពុំមានសំណូមពរអីធំដុំនោះទេ ហើយយើងមានលទ្ធភាពក្នុងការកែប្រែ ហើយឬបន្ថែម ឬក៏បន្ថយដកចេញនោះ ហើយដូច្នេះវាជាការចាំ គឺថាយើងមានកាតព្វកិច្ចក្នុងការធ្វើនេះ ពីព្រោះថា យើងមានដើមបណ្តឹងរដ្ឋប្បវេណីជាច្រើនទៀតដែលយើងត្រូវពិគ្រោះជាមួយនោះ ហើយក៏ព្រោះថា យើងមានកំហិតទាក់ទងទៅនឹងការធ្វើការតាក់តែងវិធានការនៃការសងសំណងនេះ។

[១៥:៤១:៣៨]

ទាំងអស់នេះធ្វើ ហើយធ្វើឲ្យខ្ញុំ ធ្វើឲ្យយើងបង្ហាញនូវការចង្អុលបង្ហាញដំបូង គឺថាយើងមានការតម្រូវលក្ខខណ្ឌតម្រូវហ្មត់ចត់ជាងនេះ ដែលហៅថា ការកំណត់ដែលថា វាមានកំហិតខ្លាំង ពីព្រោះថាយើងត្រូវបានគេសុំឲ្យ ទីមួយ គឺថាប្រឆាំងទៅនឹងជាប់ចោទ ជួននោះគឺថា យើងត្រូវធ្វើខ្លួនយើងបង្កើតនូវគម្រោងពិសេស។ ដូច្នេះគឺថាត្រូវបង្ហាញពីលក្ខណៈពិសេសនៃគម្រោងនេះ ហើយនិងផ្តល់គម្រោងនេះនូវការភាពជាក់លាក់ទាក់ទងទៅនឹងរបៀបធ្វើ ហើយបន្ទាប់មកទៀតគឺថា នាំយកមកនូវការធានាផ្នែកហិរញ្ញវត្ថុគ្រប់គ្រាន់នោះ។ ហើយកម្រិតបង្ខំនេះ នៅក្នុងប្រព័ន្ធតុលាការជាតិ និងអន្តរជាតិមានតែមួយគត់ ហើយនិងវាអាចជាការដាក់ទណ្ឌកម្មដល់ដើមបណ្តឹងរដ្ឋបវេណី។ ដូច្នេះហើយក៏វាអាចក្លាយទៅជាឧបសគ្គដ៏សំខាន់ដែលទាក់ទងទៅនឹងសិទ្ធិទទួលបានសំណង ហើយមេធាវីដើមបណ្តឹងរដ្ឋប្បវេណី

នឹងធ្វើយ៉ាងណាដើម្បីកុំឲ្យករណីបែបនេះកើតឡើង។

[១៥:៤២:៥៧]

គំនិតរបស់ខ្ញុំមួយទៀតនោះគឺថា នៅពេលដែលយើងបានចាកចេញពីនេះ ហើយនៅពេលដែលតុលាការបានបញ្ចប់ការងាររបស់ខ្លួននោះ អ្វីដែលនៅសល់នៅទីនោះគឺថា មានការផ្តន្ទាទោសមួយ គឺការដាក់ទណ្ឌកម្មមួយ ហើយគឺការផ្តល់សំណងនេះឯង។ សហមេធាវីនាំមុខសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី ហើយនិងមេធាវីដើមបណ្តឹងរដ្ឋប្បវេណី សូមគូសបញ្ជាក់ពីសារៈសំខាន់ជានិមិត្តរូប ហើយនិងស្របច្បាប់ដែលជាសិទ្ធិសំខាន់បំផុត ដែលយើងមិនអាចកាត់ផ្តាច់ពីដើមបណ្តឹងរដ្ឋប្បវេណី ហើយវិសាលភាពនិងលក្ខណៈបង្ខំរបស់សាលក្រម ដែលផ្តន្ទាទោសផង ហើយនិងផ្តល់សំណងផងនោះជាលក្ខណៈជាក់លាក់ ហើយនិងផ្តល់តម្លៃដល់សំណងតាមផ្លូវការ ដែលមិនអាចដូចធៀបទៅនឹងវិធានការក្រៅតុលាការដែលជាបន្ទាប់បន្សំនោះទេ ពីព្រោះថា តាមធម្មតាវិធានក្រៅផ្លូវតុលាការមិនអាចពាក់ព័ន្ធនឹងសេចក្តីសម្រេចព្រហ្មទណ្ឌនោះទេ។

[១៥:៤៤:០៩]

ជម្រើសនៃការជំនុំតម្រូវឲ្យមានសិទ្ធិរបស់ភាគីនីមួយៗ ត្រូវតែគោរពនិងអនុវត្ត ហើយគោលការណ៍នានា ដែលគ្រប់គ្រងលើដំណើរការនីតិវិធីជំនុំជម្រះក្តីព្រហ្មទណ្ឌត្រូវបានគោរព។

ខ្ញុំសូមជម្រាបថា យើងសុំឲ្យអង្គជំនុំជម្រះកត់សម្គាល់អំពីការចង្អុលបង្ហាញដំបូងរបស់យើងទាក់ទងនឹងខ្លឹមសារជាក់លាក់របស់សំណងនេះ ហើយជាពិសេសនោះសុំឲ្យអង្គជំនុំជម្រះធ្វើការសម្រេចថា ទោះបីជាយ៉ាងណាក៏ដោយ សុំឲ្យសំណងនេះក្លាយជាសិទ្ធិ ក៏ប៉ុន្តែមិនមែនជាបន្ទុកនោះទេ។

សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សូមអរគុណ លោកស្រី លោក លោកស្រីមេធាវី។ ជាកិច្ចបន្ត តើភាគីដទៃទៀតណាមានបំណងចង់លើកឡើងនូវសេចក្តីសង្កេតរបស់ខ្លួន ចំពោះបញ្ហាដែលសហមេធាវីនាំមុខតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីបានលើកឡើងអម្បាញ់មិញនេះដែរឬទេ? ប្រសិនបើមានសូមអញ្ជើញ!

[១៥:៤៥:៣៤]

បាទ, ឥឡូវនេះឃើញថា មិនមានទេ ហើយតាមរបៀបវារៈដែលគ្រោងនៅក្នុងកិច្ចដំណើរការនៃការទាញហេតុផលផ្ទាល់មាត់ ឃើញថាសមល្មមនឹងពេលវេលាផងដែរ គឺសមល្មមនឹងសម្រាកហើយ។

ដូច្នេះ អង្គជំនុំជម្រះសាលាដំបូង ប្រកាសផ្អាកដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ ហើយសវនាការនឹងលើកទៅបន្តនៅវេលាថ្ងៃស្អែក ចាប់ពីម៉ោងប្រាំបួន។ ហេតុដូច្នេះ សូមភាគី និងសាធារណជនជ្រាប។

អនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទ ទាំងបីរូបត្រឡប់ទៅកាន់មន្ទីរឃុំឃាំង នៃ អ.វ.ត.ក វិញ និងបង្គាប់ឲ្យនាំជនជាប់ចោទទាំងបួននាក់ មកទីនេះនៅថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួន៕

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៤:៤៧ នាទី)*